ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 19-Dec-2012, 14:57
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២**

**ម៉ោង ០៩: ០២នាទី**

**សវនាការលើកទី១៤១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP))*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ឃីត រេយ៍ន័រ *(Mr. Keith RAYNOR)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

កញ្ញា សុង ឆវ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក គឹម ម៉េងឃី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយធ៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក ខាំ ផាន់ ហៅ ផាន វ៉ាន (TCW-307) | ខ្មែរ |
| លោក សួន កានិល (TCW-695) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ខាំ ផាន់ ហៅ ផាន វ៉ាន** (TCW-307)
សួរបន្តដោយលោក គង់ សំអុន ផ្ដើមពី៖ .......... ទំព័រ ២
សួរដោយលោក អាកទួរ វែកគែន ផ្ដើមពី៖ .......... ទំព័រ ៨
សួរដោយលោក ម៉ៃខល កាណាវាស ផ្ដើមពី៖ .......... ទំព័រ ១៤

**ការសួរសំណួរទៅសាក្សី៖ លោក សួន កានិល** (TCW-695)
សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖ .......... ទំព័រ ២៨
សួរដោយកញ្ញា ស៊ុង ឆវ័ន្ត ផ្ដើមពី៖ .......... ទំព័រ ៣២
សួរដោយលោក ឃីត រេយ៍ន័រ ផ្ដើមពី៖ .......... ទំព័រ ៧០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:០៣]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សី ផាន វ៉ាន ហៅ ខាំ ផាន់ ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្ដីពីរក្រុមទៀត ហើយនិងបន្ត ផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-695។

លោក ឌុច ផារី ឡើងរាយការណ៍អំពីសកម្មភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរព និងសូមជម្រាបលោកប្រធាន នៅក្នុងសវនាការថ្ងៃនេះ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្ដីនេះ មានវត្តមានលើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមានពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ដោយមូលហេតុសុខភាព។ លោកមេធាវីជាតិការពារក្ដីឲ្យលោក អៀង សារី។ លោក អាង ឧត្តម បានជូនដឹងថា គាត់នឹងអវត្តមាននៅថ្ងៃនេះ ដោយមានធុរៈផ្ទាល់ខ្លួន។

[០៩:០៤:០៦]

នាព្រឹកនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់នូវសក្ខីកម្មរបស់សាក្សី លោក ខាំ ផាន់ ដែលមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ។ ហើយសម្រាប់សវនាការថ្ងៃនេះ អង្គជំនុំជម្រះមានសាក្សីបម្រុងមួយរូប គឺសាក្សីដែលមានរហស្សនាម TCW-695។ សាក្សីរូបនេះបានធ្វើសម្បថនៅចំពោះមុខរូបលោកតាដំបងដែកកាលពីព្រឹកមិញរួចហើយ។ ហើយសាក្សីក៏បានបញ្ជាក់ផងដែរថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីណាមួយនោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការសាជាថ្មី។

[០៩:០៥:២០]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក គង់ សំអុន៖**

**ស៖** លោក ផាន វ៉ាន សូមជម្រាបសួរម្តងទៀត ហើយខ្ញុំថ្ងៃនេះនឹងសួរបញ្ចប់នូវសំណួរដែលសេសសល់សម្រាប់លោក។ កាលពីល្ងាចម្សិលមិញ ខ្ញុំបានសួរលោកពាក់ព័ន្ធទៅនឹងមន្ទីរក-១៧ នៅតំបន់១០៥ ហើយនិងការរៀនសូត្ររបស់លោកនៅ ប-២០ ប៉ុន្តែខ្ញុំនឹងសួរលម្អិតបន្ថែមទៅលើបញ្ហានេះទៀត។ ជាបន្តនេះ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់អំពីអាយុរបស់លោកពិតប្រាកដ ថាតើឆ្នាំកំណើតដែលមាននៅក្នុងកំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេតទាំងបីនេះ ជាឆ្នាំកំណើតពិតប្រាកដរបស់លោក ឬមួយក៏លោក តាមពិតប្រាកដលោកមានឆ្នាំកំណើតផ្សេងទៀត? បាទ សូមលោកជួយបញ្ជាក់។

**លោក ផាន វ៉ាន៖**

**ផ៖** ឆ្នាំពិតប្រាកដអត់ចាំច្បាស់ទេបាទ ប៉ុន្តែប្រហែលនៅក្នុងហ្នឹងណា ក្នុងឯកសារហ្នឹងបាទ។

**ស៖** បាទ សូមអរគុណ។ តើលោកអាចចាំថា អាយុពិតប្រាកដរបស់លោកច្រើនជាងនេះ ឬមួយក៏តិចជាងនេះ?

[០៩:០៦:៥៨]

**ផ៖** មិនច្រើនទេបាទ។ អាចប្រហាក់ -- បើខុស ខុស១ឆ្នាំ បើលើស លើស១ឆ្នាំប៉ុណ្ណឹងឯង។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការរៀនសូត្ររបស់លោកនៅ ប-២០ ដែលលោកបានឆ្លើយជម្រាបអង្គជំនុំជម្រះកាលពីម្សិលមិញថា លោកបានរៀនអក្សរខ្មែរ ហើយនិងរៀនអង្គលីលេខ។ ចំណុចនេះ ខ្ញុំចង់បញ្ជាក់ទាក់ទងទៅនឹងរៀនអង្គលីលេខរបស់លោកហ្នឹង។ ថាតើលោករៀនពីអ្វីខ្លះនៅពេលនោះ?

**ផ៖** ខ្ញុំចង់បញ្ជាក់ថា អង្គុលីលេខ មិនមែនអង្គុលីលេខទេបាទ គឺសារ រៀនបកសារទូរលេខ គេហៅ អក្សរសម្ងាត់ ឬអក្សរសម្ងាត់។ តែប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណ--

**ផ៖** មិនមែនរៀនអង្គុលីលេខទេ អាហ្នឹងសូមបញ្ជាក់អ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ នៅក្នុងចម្លើយរបស់លោកកន្លងមកមានប្រើពាក្យ អង្គុលីលេខនេះញឹកញាប់ ហើយរហូតដល់ពេលខ្ញុំឆ្លើយ ក៏មានប្រើពាក្យ អង្គុលីលេខនេះដែរ។ ឥឡូវលោកសូមកែតម្រូវថាមិនមែនរៀនអង្គុលីលេខទេ គឺរៀនបកសារទូរលេខ។ អ៊ីចឹងទេបាទ?

[០៩:០៨:២១]

**ផ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមលោកជួយឆ្លើយម្តងទៀតបាទ។

**ផ៖** សារទូរលេខបាទ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា សារទូរលេខដែលលោកសិក្សានោះ លោករៀនមេរៀនអ្វីខ្លះនៅពេលនុ៎ង?

**ផ៖** អាហ្នឹងគេ ជំនាន់ហ្នឹងគេហៅ អាលេខ១០ខ្ទង់បាទ។

**ស៖** លោកអាចពន្យល់អង្គជំនុំជម្រះបន្តិចបានទេថា លេខ១០ខ្ទង់ដែលលោករៀននុ៎ង វាយ៉ាងម៉េចដែរ?

**ផ៖** លេខ១០ខ្ទង់ហ្នឹង គេគូសក្រឡាខ្វែង ដូចក្រឡារ៉ែកអ៊ីចឹងបាទ មានសរសេរលេខ១ ដល់១០ អ៊ីចឹងទៅ។ ១ ដល់១០ ជុំវិញបួនជ្រុងអ៊ីចឹង គេគូសខ្វែងអ៊ីចឹង ដូចក្រឡារ៉ែកបាទ។ ហើយមានតួអក្សរក្នុងហ្នឹងបានគេបែង យកអាលេខពីរខ្ទង់ៗហ្នឹង ដូចឧបមាដូចអក្សរ “ក” អ៊ីចឹង។ “ក” អ៊ីចឹងវាខ្ទង់លេខ១មក ១ឆ្វេងអ៊ីចឹង មកស្តាំ មកក្រោមអ៊ីចឹង លេខ១ ដែរ ឧទាហរណ៍អ៊ីចឹងបាទ។ សូមបញ្ជាក់ប៉ុណ្ណឹង។

[០៩:១០:០០]

**ស៖** បាទ សូមអរគុណ។ ក្រៅពីលេខ ១០ខ្ទង់នេះលោកមានសិក្សាមេរៀនអីផ្សេងទៀតទេ?

**ផ៖** អត់មានទេបាទ។

**ស៖** បាទ សូមអរគុណ។ រយៈពេលដែលលោកសិក្សាអំពីលេខ ១០ខ្ទង់នេះលោកចំណាយពេលប្រហែលប៉ុន្មានដែរនៅពេលហ្នឹង?

**ឆ៖** ប្រហែល ១ខែបាទ ។

**ស៖** បាទ សូមអរគុណ។ បន្ទាប់ពីការសិក្សារយៈពេល១ខែរបស់លោកនេះ តើលោកមានសមត្ថភាពអាចធ្វើការបកសារបានត្រឹមត្រូវទេ ហើយមានការវាយតម្លៃពីគ្រូរបស់លោកយ៉ាងម៉េចដែរពេលនុំង?

**ឆ៖** ជំនាន់ហ្នឹងអត់មានការវាយតម្លៃទេបាទ ចេះប្រើហើយខ្ញុំទៅតាមឪពុកខ្ញុំទៅនៅស្រុកបាទ។

**ស៖** បាទ សូមអរគុណ។ លោកមានចាំថា នៅពេលដែលលោកបកសារជាលើកដំបូងបន្ទាប់ពីរៀនចប់នេះ លោកបានទទួលការណែនាំយ៉ាងម៉េចដែរ?

**ឆ៖** ចាំអត់បានទេបាទ ។

[០៩:១១:៥៧]

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមសួរលោកទាក់ទងទៅនឹងក-១៧ មន្ទីរក-១៧ ដែលលោករស់នៅទីនោះ ដែលលោកបានឆ្លើយពីម្សិលមិញថា ឆ្នាំ១៩៧៤ រហូតមកដល់ឆ្នាំ៧៧ លោកបានរស់នៅមន្ទីរក-១៧ តំបន់១០៥។ ខ្ញុំចង់សួរបញ្ជាក់លោកថា នៅពេលដែលលោករស់នៅក-១៧នោះ មន្ទីរក-១៧នោះលោកធ្វើអ្វីខ្លះ? មានតួនាទីធ្វើអ្វីខ្លះនៅពេលនោះ?

**ឆ៖** នៅបកសារជាមួយឪពុកខ្ញុំ ហើយនិងចុះឡើងជាមួយគាត់ហ្នឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបញ្ជាក់សាជាថ្មីថា "ក្នុងចន្លោះឆ្នាំពី១៩៧៤ ដល់ ១៩៧៧នោះគឺលោកនៅធ្វើការជាអ្នកបកសារ និងនៅជាមួយឪពុកលោកជាប់រហូត" អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវបាទ ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់អំពីមន្ទីរផ្សេងៗទៀតដែលស្ថិតនៅក្រោមឱវាទរបស់មន្ទីរក-១៧ នៅតំបន់១០៥ នោះដែរឬទេ?

**ឆ៖** ខ្ញុំចាំអត់បានទេ ព្រោះវាយូរពេកហើយ។

[០៩:១៣:៣៦]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការងារផ្ទាល់របស់លោកក្នុងនាមជាអ្នកបកសារនេះ តើលោកមានប្រធានណាម្នាក់នៅពីលើលោកដែរទេ? ឬមួយក៏លោកមានអ្នកគ្រប់គ្រងដែលជាបុគ្គលិករបស់លោកដែរទេ?

**ឆ៖** មានប្រធានមន្ទីរបាទ។

**ស៖** ឈ្មោះមន្ទីរអ្វីទៅបាទ?

**ធ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមជួយឆ្លើយម្តងទៀត។

**ធ៖** មន្ទីរក-១៧ហ្នឹងបាទ។

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់សាឡើងវិញថា ឪពុករបស់លោកជាលេខាតំបន់ ហើយមានប្រធានមន្ទីរម្នាក់ទៀតនៅពីក្រោមឪពុករបស់លោក ជាអ្នកគ្រប់គ្រងលោក តើអ៊ីចឹងត្រឹមត្រូវទេ?

**ធ៖** ត្រឹមត្រូវបាទ។

[០៩:១៥:៤៩]

**ស៖** បាទ សូមអរគុណ។ នៅក្នុងក្រុមការងាររបស់លោកហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ ឬមួយក៏មានតែលោកម្នាក់ឯងទេ? លោកអាចជួយជម្រាបផង បើសិនជាចាំ។

**ធ៖** នេះលោកសួរក្នុងអ្នកបកសារទូរលេខហ្នឹងឬក៏ៗយ៉ាងណាបាទ អត់យល់?

**ស៖** បាទ សូមអរគុណ។ គឺនៅក្នុងក្រុមការងារអ្នកបកសារទូរលេខរបស់លោកបាទ សូមៗលោក ជួយបញ្ជាក់មានគ្នាប៉ុន្មាននាក់ដែរ?

**ធ៖** ដំបូង ជំនាន់ដំបូងមានតែខ្ញុំម្នាក់ឯងទេបាទ។

**ស៖** រហូតដល់ឆ្នាំណា? ហើយមានគ្នាថែមទៀតហ្នឹង មានគ្នាប៉ុន្មាននាក់ដែរ?

**ធ៖** ក្រោយមកបងខ្ញុំមកបានមានគ្នាច្រើន គ្នាពីរបីនាក់បាទ។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងផ្នែកផ្សេងទៀតនៃៗមន្ទីរក-១៧ ហ្នឹងមានអ្នកខាងវិទ្យុទាក់ទង ឬអ្នកដែលទទួលសញ្ញាតេឡេក្រាមសារទូរលេខហ្នឹងដែរទេ?

**ធ៖** អត់មានទេបាទ។

**ស៖** បាទសូមអរគុណ។ ចុះលោក អ៊ីចឹងបានន័យថាអត់មានអ្នកដែលកាន់វិទ្យុសម្រាប់ទទួលសញ្ញាហ្នឹងទេ ហើយអ្នកដែលទទួលសញ្ញាហ្នឹងជានរណាដែរ? លោកអាចប្រាប់ផងបានទេ? ជាលោកផ្ទាល់ ឬក៏ជាប្រធានមន្ទីរ?

[០៩:១៦:៤៦]

**ធ៖** សូមលោកបញ្ជាក់ម្តងទៀត? សំណួរហ្នឹងសួរអ្នកបកសារ ឬអ្នកៗកាន់វិទ្យុទាក់ទងបាទ?

**ស៖** ខ្ញុំសួរខាងផ្នែកផ្សេងទៀតនៅមន្ទីរក-១៧ មិនមែនអ្នកបកសារទេគឺអ្នកកាន់ខាងវិទ្យុ ពីព្រោះ

មុនអំមិញលោកឆ្លើយថា លោកជាអ្នកបកសារហើយពុំមានអ្នកណាផ្សេងទៀតទេ គឺរហូតដល់ក្រោមមក បានមានបងស្រីរបស់លោកមកជួយ។ អ៊ីចឹងខ្ញុំសួរថា តើមានអ្នកកាន់វិទ្យុដែលជាអ្នកទទួលសញ្ញារលកធាតុអាកាសនៃទូរលេខ សារទូរលេខនោះ ជាលោកផងដែរ ឬក៏ជាប្រធានមន្ទីរជាអ្នកទទួលខុសត្រូវ ឬមួយមានបុគ្គលណាផ្សេងទៀតជាអ្នកទទួលខុសត្រូវផ្នែកនេះ?

**ឆ៖** អ្នកវិទ្យុទាក់ទងផ្សេង មានអ្នកផ្សេងទៀត បុគ្គលិកគេដោយឡែក។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់លោកចំណុចមួយនៅលើឯកសារ E3/58 ដែលជាកំណត់ហេតុនៃការស្តាប់ចម្លើយរបស់លោក ជាមួយសហចៅក្រមស៊ើបអង្កេតត្រង់លេខ ERN 00239 936, ជាភាសាខ្មែរ ខ្ញុំជូនលេខ ERN ជាភាសាបរទេស--

*(សម្រាករយៈពេលខ្លី)*

[០៩:២០:០៦]

ខ្ញុំសូមអានជូនជាភាសាខ្មែរឲ្យលោកស្តាប់សិន ហើយខ្ញុំនឹងជូន ERN ជាភាសាអង់គ្លេស និងភាសាបារាំងពេលក្រោយ។ ខ្ញុំកំពុងតែរកមើល។ ខ្ញុំសូមអានជូនលោក ហើយលោកស្តាប់នេះសិន ហើយខ្ញុំនឹងជូន ERN ទៅសហភាគីក្រោយទៀត។ នៅក្នុងអត្ថបទនេះវាជាទំព័រទី៣ ដូច្នេះបើនៅក្នុងភាសាបរទេសក៏វាអាចស្ថិតនៅក្នុងទំព័រទី៣ បន្ទាប់នេះដែរ ខ្ញុំនឹងរកជូន។ នៅត្រង់ចំណុចនេះលោកបញ្ជាក់ថា ឆ្នាំមួយពាន់ -- ខ្ញុំសូមអានជូន "ឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៧ ខ្ញុំបានទៅភ្នំក្រោល ទៅនៅភ្នំក្រោលត្រង់មន្ទីរក-១៧ ដែលជាមន្ទីររបស់គណៈខេត្ត"។ ចំណុចដែលខ្ញុំចង់សួរបញ្ជាក់លោកហ្នឹង គឺត្រង់ពាក្យ "គណៈខេត្ត" ថាតើនៅក្នុងសម័យនុ៎ង ពេលនុ៎ងគេប្រើពាក្យ "គណៈខេត្ត" ឬមួយក៏គេប្រើជាតំបន់ ឬក៏ជាគណៈស្រុកអ្វីផ្សេងក្រៅពីនេះ? សូមលោកជួយបញ្ជាក់។

**ឆ៖** សម័យនុ៎ងជួនកាលអ្នកខ្លះគេហៅសម័យ -- គណៈតំបន់ អ្នកខ្លះគេហៅ លេខាតំបន់ លេខ ១០៥ អីអ៊ីចឹងទៅបាទ។ វាអត់មានភាសាណាជាផ្លូវការច្បាស់លាស់ទេ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។ តាមការនិយាយបាទ។

[០៩:២២:០៨]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបញ្ជាក់លេខ ERN ត្រង់ចំណុចដែលខ្ញុំអានអំមិញនេះ ភាសាអង់គ្លេស 00250088, ភាសាបារាំង 00283914។ បាទ សូមអរគុណ។ បាទ អ៊ីចឹងខ្ញុំសូមបញ្ជាក់ឡើងវិញថា ពាក្យថា "គណៈខេត្ត" នេះគឺមិនច្បាស់លាស់ទេ មិនប្រាកដថា ជាគណៈខេត្តទេ អាចជា

គណៈតំបន់ទៅវិញទេ។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមលោកជួយឆ្លើយម្ដងទៀត។

**ឆ៖** ជួនណាគេហៅទាំងពីរបាទ សម័យហ្នឹងបាទ។

**ស៖** បាទ សូមអរគុណ។ នៅត្រង់លេខ ERN ដដែលនេះ ទាំងភាសាខ្មែរ និងភាសាអង់គ្លេស បារាំង។ ចុះមកក្រោមបន្តិចមកនៅសំណួរបន្ទាប់ លោកបានឆ្លើយថា ខ្ញុំសូមអានជូន "ចំពោះបញ្ហា (សូមទោស) ចំពោះការបញ្ជាពីថ្នាក់មជ្ឈិមមកមន្ទីរក-១៧ ឲ្យចាប់ខ្លួនមិនដែលមានទេ"។ តើលោកនៅគាំទ្រចំពោះចម្លើយរបស់បែបនេះទេ?

**ឆ៖** បាទ ខ្ញុំគាំទ្រ អាហ្នឹងអត់មានទេ កាលជំនាន់ខ្ញុំនៅ។ មិនមានសារទូរលេខណាឲ្យមកចាប់ខ្លួនទេ អត់ទេ មានតែហៅទៅធ្វើការ។ ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង ហៅទៅធ្វើការទៅបាត់ខ្លួនបណ្ដោយទៅវាអ៊ីចឹង។

[០៩:២៤:១១]

**ស៖** បាទ សូមអរគុណ។ តើលោកអាចបញ្ជាក់ថា លោកដឹងច្បាស់ថាអត់មានសារទូរលេខក្នុងសម័យដែលលោកនៅធ្វើការមន្ទីរក-១៧ នោះបានយ៉ាងម៉េចដែរ លោកអាចអះអាងបែបនេះបានដោយសារអី? ឧទាហរណ៍ថា លោកជាអ្នកទទួលសារទាំងអស់ ឬមួយក៏មានសារខ្លះនៅក្នុងចន្លោះពេលនុ៎ងលោកមិនបានទទួលទេ ដោយអាចនាំឲ្យការអះអាងរបស់លោកនេះមានបញ្ហាដែរឬទេ?

**ឆ៖** កាលសម័យហ្នឹង ក្មេងៗខ្ញុំអត់ដឹងទេបាទ។ វាអក្សរសម្ងាត់គេ ដូចខ្ញុំបញ្ជាក់អ៊ីចឹង។ អក្សរសម្ងាត់ណាលេខសម្ងាត់ខ្លាំង គេដឹងតែរវាងខាងលើនិងខាងលើទេបាទ។ ហើយមួយទៀតវា គេហៅមកធ្វើការ អីយ៉ាងណាៗ ខ្ញុំម៉េចដឹងបាទ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** បាទ ប៉ុន្តែលោកអាចបញ្ជាក់ថា នៅក្នុងបទពិសោធន៍របស់លោក ដែលលោកបានធ្វើការជាអ្នកបកសារនៅពេលនោះ គឺពុំមានសារណាបញ្ជាឲ្យចាប់ខ្លួនទេ។ តើការដឹងរបស់លោកនេះ មានៗមូលដ្ឋានអ្វីដែលអាចឲ្យតុលាការជឿថាវាជាការពិតដែរទេ?

**ឆ៖** កាលដែលខ្ញុំនៅធ្វើការហ្នឹង បើថាមាន វាឃើញអក្សរ អានដឹងថាមានហើយបាទ។ បើវាអត់ហើយ។

[០៩:២៦:២១]

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ខ្ញុំអស់សំណួរហើយ សូមឱ្យសហភាតាបន្ត។ អនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** ជម្រាបលោក ខ្ញុំមានសំណួរបន្តិចបន្តួចទេ។ ខ្ញុំឈ្មោះ អាកឡូរ វែកគែន មេធាវីអន្តរជាតិការពារលោក ខៀវ សំផន។ ជាបឋម ខ្ញុំសូមអានចម្លើយរបស់លោក ដែលលោកបានផ្តល់ជូនទៅសហចៅក្រមស៊ើបអង្កេត ហើយចម្លើយនេះក៏ធ្លាប់បាន គេអាន ខាងសហព្រះរាជអាជ្ញាអានហើយនៅថ្ងៃដំបូងដែលលោកមកផ្តល់សក្ខីកម្មនៅទីនេះ គឺជាចម្លើយទី១របស់លោក ដែលលោកឆ្លើយទៅ -- ឆ្លើយនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ លេខ ERN គឺឯកសារ E3/58 គឺ ERN ជាភាសាខ្មែរគឺ 0020 -- បារាំង គឺថា 00283905 ហើយជាភាសាខ្មែរគឺ 002399--

**អ្នកបកប្រែ៖**

លោកប្រធាន ខ្ញុំតាម ERN ជាភាសាខ្មែរអត់ទាន់។ សូមឱ្យគាត់អានជាភាសាខ្មែរម្តងទៀត។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** បាទ ERN ជាភាសាខ្មែរគឺ 00239934, ERN ជាភាសាអង់គ្លេសគឺ 00250088។ ពេលនោះ អ្នកស៊ើបអង្កេតសួរលោកដូចតទៅនេះ ខ្ញុំសូមដកស្រង់ “តើលោកធ្វើការនៅ -- តើលោកបញ្ជូនតេឡេក្រាម -- តើការងារអង្គុលីលេខសម្ងាត់របស់លោកផ្ញើទៅខាងមជ្ឈិមនោះ មានផ្ញើទៅអ្នកណាខ្លះ? នៅមន្ទីរណា? ខ្ញុំច្រើនផ្ញើទៅមន្ទីរ៨៧០។ ក្នុងនោះប្រសិនបើមានការងារសម្ភារៈ និងសុខាភិបាល ឬក៏សង្គមកិច្ច និងខាងការងារក្រៅសន្តិសុខ ហើយត្រូវខាងវាយអក្សរលាតនិងសម្ងាត់ ទៅខៀវ សំផន ហៅ ហែម។ ហើយពេលដែលគាត់ណែនាំចាត់ចែងត្រឡប់ទៅវិញ គាត់ចុះហត្ថលេខា ហើយដាក់ឈ្មោះថា ហែម នេះដែរ។ ឧទាហរណ៍ដូចជាពេលដែលគាត់ចាត់ចែងមកតំបន់ខាង តំបន់ ក-១៧ ត្រូវចាត់ចែងទៅខាងពាណិជ្ជកម្ម ឬខាងសេដ្ឋកិច្ចឱ្យទៅយកសម្ភារៈនៅមជ្ឈិម ដូចជាប្រេង ឬក៏ -- ប្រេង និងគ្រឿងចក្រ ថ្នាំពេទ្យ ក្រណាត់។ ចំណែកខាងមជ្ឈិមវិញ ក៏មានស្នើពីខាងតំបន់ទៅវិញដូចជាស្រូវជាដើម”។ ហើយបន្ទាប់មកទៀត លោកនិយាយអំពីការងារសន្តិសុខ។ លោកបាននិយាយថា គាត់-- បាទ សំណួរខ្ញុំដូចតទៅនេះនៅក្នុងរយៈពេលដែលលោកធ្វើការនៅផ្នែកទូរលេខ តើលោកអាចបញ្ជាក់អំពីការបែងចែក

ការងាររបស់លោកនៅក្នុងចម្លើយ ដែលលោកបានផ្តល់ជូនទៅសហចៅក្រមស៊ើបអង្កេតនៃតុលាការយើងនេះដែរឬទេ?

[០៩:៣០:៥៩]

**លោក ផាន វ៉ាន់៖**

**ផ៖** អត់យល់សំណួរ បែងចែកយ៉ាងណាបាទ។ សូមលោកបញ្ជាក់ម្តងទៀត បែងចែកសម្ភារៈ ឬបែងចែកស្អីអត់យល់បាទ។

**ស៖** បាទ ខ្ញុំទើបតែអានចម្លើយរបស់លោកអម្បាញ់មិញនេះ ថាតើលោកយល់ស្របនឹងចម្លើយដែលសម្រង់ ដែលខ្ញុំអានជូនលោកអម្បាញ់មិញដែរឬទេ ហ្នឹងជាចម្លើយរបស់លោក?

**ផ៖** អំមិញលោកសួរថាបែងចែក ខ្ញុំអត់យល់ៗរឿងបែងចែក។ តាមចម្លើយហ្នឹងខ្ញុំឯកភាពហើយបាទ។

**ស៖** អ៊ីចឹងបានន័យថាលោកយល់ហើយ ព្រោះថាខ្ញុំគ្រាន់តែសួរលោកថា ឲ្យបញ្ជាក់ប៉ុណ្ណឹងទេ តើលោករក្សាចម្លើយហ្នឹងឬក៏អត់? បាទ ឥឡូវនេះខ្ញុំសូមឲ្យលោកបំភ្លឺឲ្យច្បាស់ជាងនេះបន្តិច តើនៅក្នុងរយៈពេលដែលលោកធ្វើការនៅផ្នែកទូរលេខ តើលោកចាំអំពីបញ្ហាដែលចេញដោយ ហែម ទាក់ទងទៅនឹងស្រូវដែរឬទេ?

**ផ៖** ខ្ញុំមិនចាំទេ ចាំបានតែត្រង់ថាមានបញ្ជូនស្រូវមក ដល់អ៊ីចឹងចាំបានថាឈ្មោះ ហែម បានតែប៉ុណ្ណឹងទេបាទ។

**ស៖** បាទ សូមអរគុណ។ តើ ខៀវ សំផន គាត់ៗមានធ្លាប់ផ្ញើទូរលេខទាក់ទងនឹងបញ្ហាសន្តិសុខដែរឬទេ? ឧទាហរណ៍គឺសន្តិសុខនៅក្នុងតំបន់របស់លោកជាដើមនេះ?

**ផ៖** អត់មានទេបាទ ជំនាន់ហ្នឹងអត់មានឈ្មោះគាត់អារឿងសន្តិសុខទេ។

**ស៖** នៅពេលដែលលោកឆ្លើយនៅក្នុងចម្លើយដែលខ្ញុំស្រង់អម្បាញ់មិញនេះ តាមការឆ្លងឆ្លើយទូរលេខជាមួយនឹង ហែម ហៅ ខៀវ សំផន នេះគឺថាមិនមានលក្ខណៈសម្ងាត់ទេ តើលោកចង់និយាយយ៉ាងម៉េចដែរពាក្យថា “ជាចំហ” នេះ “មិនមែនសម្ងាត់” នេះ លោកចង់និយាយយ៉ាងម៉េចដែរ?

[០៩:៣៤:២៦]

**ផ៖** គេអត់ប្រើលេខទេ គេប្រើតែអក្សរវ៉ៃជាអក្សរ បើលេខគេវ៉ៃជាលេខលាត អត់មានសម្ងាត់អីទេបាទ។ នេះចង់បញ្ជាក់ប៉ុនណោះ បើលោកអត់យល់លេខលាត បានន័យថាលេខដែលយើងរៀននៅ

សាលា អ្នកណាក៏ស្តាប់បានដែរអ៊ីចឹង។ អក្សរក៏អ៊ីចឹង វ៉ៃជាអក្សរអ៊ីចឹង អក្សរ “ក” អក្សរអី តារាងហ្នឹង អ្នកៗទូទៅក៏ដឹងដែរ អ្នករៀនខាងហ្នឹង ចង់បញ្ជាក់អ៊ីចឹង។ សម្ងាត់ គឺសូម្បីតែអ្នករៀនក៏អត់ដឹងដែរ។ នេះសូមបញ្ជាក់ប៉ុណ្ណឹង។

**សះ** តើលោកធ្លាប់ឃើញសំបុត្របែបហ្នឹងដែរឬទេ នៅពេលដែលលោកធ្វើការផ្នែកទូរលេខនៅពេលនោះនុះ? ចង់និយាយថា សំបុត្រដែលមិនសម្ងាត់របស់ ហែម ហៅ ខៀវ សំផន នេះ?

**ផះ** ឃើញដូចខ្ញុំបញ្ជាក់នៅឯកសារដែលផ្តល់ៗព័ត៌មានឲ្យអ្នកស្រាវជ្រាវនោះបាទ។

[០៩:៣៥:៥៧]

**សះ** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមការបំភ្លឺមួយទៀតទាក់ទងទៅនឹងចំណុចមួយដែលលោកគិតថាចម្លែក គឺថាទាក់ទងទៅនឹងពាក្យពេចន៍មួយ សំនួនវោហារមួយ គឺថានៅក្នុងទូរលេខដែលគេបានបង្ហាញជូនលោកនោះ គឺថា ចាប់ពាក្យ ចាប់ផ្តើមដំបូងនៅក្នុងទូរលេខទាំងអស់នោះគឺ “មន្ទីរ៨៧០ជាទីស្នេហា” ហើយជាពាក្យពេចន៍នេះជាភាសាបារាំងនេះមើលទៅដូចជាមិនទំនងទាល់តែសោះ គេថា “*ប៉ុយរ៉ូ ល្វីស្វាសង់ឌីស ប៊ីយេន-អេមមេ*” អាហ្នឹងគេថាមើលទៅដូចជាមនុស្សយ៉ាងម៉េចប្រើពាក្យហ្នឹង? តើលោកអាចបំភ្លឺបានទេអំពីខ្លឹមសារជាក់លាក់អំពីពាក្យដែលគេហៅនេះ “មន្ទីរ៨៧០ជាទីស្នេហា” នេះ?

**ផះ** ខ្ញុំអត់យល់ពីពាក្យវប្បធម៌ទេបាទ ប៉ុន្តែជំនាន់ហ្នឹង ជាទូទៅគេប្រើតែអ៊ីចឹងបាទ។ ក្នុងសារទូរលេខហ្នឹង អ្នកធំគេសរសេរមកឲ្យអ្នកធ្វើសារបញ្ជូនទៅហ្នឹង គេដាក់តែអ៊ីចឹងជាទម្រង់គេអ៊ីចឹង។ ឃើញ -- ឯន័យយ៉ាងណាៗ ខ្ញុំមិនបានដឹងដែរបាទព្រោះខ្ញុំមិនបានរៀនសូត្រវប្បធម៌ខ្ពង់ខ្ពស់ៗអី។ នេះសូមបញ្ជាក់ប៉ុណ្ណឹងបាទ។

[០៩:៣៨:០៦]

**សះ** បាទ អម្បាញ់មិញនេះ -- បាទ ខ្ញុំសូមយោងទៅពេលផ្សេងវិញ ហើយមិនមែនយោងទៅអម្បាញ់មិញទេ គឺសុំយោងទៅចម្លើយអ្នកផ្សេងទៀតក្រៅពីលោក ដែលមកផ្តល់សក្ខីកម្មនៅទីនេះ។ ហើយខ្ញុំធ្លាប់សួរទៅគាត់នូវសំណួរមួយទាក់ទងលើខ្លឹមសារពាក្យពេចន៍មួយចំនួន។ ហើយឥឡូវខ្ញុំសូមយោងទៅឯកសារ E1/851, ERN ជាភាសាបារាំងគឺ 00817423, ជាភាសាខ្មែរ 00816722 ជាភាសាអង់គ្លេសគឺ 00817536។ នេះគឺជាការផ្តល់សក្ខីកម្មរបស់សាក្សីម្នាក់ ដែលមានជំនាញខាងទូរលេខដែរ ហើយខ្ញុំធ្លាប់សួរទៅគាត់នូវខ្លឹមសារពាក្យពេចន៍មួយគឺថា “ជូនមន្ទីរ៨៧០ជាទីគោរពស្នេហា” ហើយរាល់ឧទាហរណ៍ដែលខ្ញុំបង្ហាញគាត់ គាត់ឆ្លើយតបមកខ្ញុំវិញថា “តាមការពិតទៅ ទូរលេខទាំងអស់

នេះ សុទ្ធតែផ្ញើទៅ ប៉ុល ពត ទេ”។ តើលោកយល់ស្របជាមួយសាក្សីនេះដែរឬទេ? ឬក៏លោកនៅតែមិនយល់អំពីខ្លឹមសារជាក់លាក់នៃពាក្យដែលថា “គោរពជូនមន្ទីរ៨៧០ ជាទីគោរពស្នេហា”?

**ឆ៖** ខ្ញុំមិនបានដឹងដែរបាទ អត់ដឹងថា ៨៧០ហ្នឹងជា ប៉ុល ពត ម្នាក់ ឬក៏ក្នុងនាមជាថ្នាក់ដឹកនាំរួមក៏ខ្ញុំអត់ដឹងដែរ។ ប៉ុន្តែខ្ញុំសន្និដ្ឋានខ្លួនឯងទេ ព្រោះមន្ទីរ៨៧០ហ្នឹង ជំនាន់ហ្នឹងអ្នកណាក៏ផ្ញើទៅហ្នឹងដែរ វារួមនៅហ្នឹង។ ដឹងតែប៉ុណ្ណឹងទេបាទ អ្នកនៅខាងតំបន់បាទ។

[០៩:៤១:០០]

**សៈ** បាទ យ៉ាងហោចណាស់ គឺលោកផ្ទាល់នេះ នៅពេលដែលលោកបំភ័ន្តអក្ខរៈទូរលេខដើម្បីផ្ញើជូនទៅ ខៀវ សំផន នេះ គឺថាលោកដាក់ឈ្មោះ ហែម មែនទេ?

**ឆ៖** ត្រឹមត្រូវបាទ។

**សៈ** បាទ ខ្ញុំមានសំណួរមួយចុងក្រោយ ដើម្បីសូមការបំភ្លឺពីលោក។ ខ្ញុំមានអារម្មណ៍ថា នៅក្នុងចម្លើយរបស់លោកមួយដែលលោកទើបតែឆ្លើយអម្បាញ់មិញនេះទៅសហភាតារបស់ខ្ញុំ លោកនិយាយថា លោកស្គាល់ -- លោកទទួលស្គាល់ថា លោកធ្លាប់ធ្វើការឲ្យឪពុកលោកដល់ឆ្នាំ១៩៧៧ ផ្នែកទូរលេខ គឺជាឆ្នាំដែលឪពុកលោកស្លាប់។ អ្វីដែលលោកបានឆ្លើយអម្បាញ់មិញនេះ ២, ៣នាទី មុននោះក៏ប៉ុន្តែដូចមិនសូវច្បាស់ទេ ទាក់ទងនឹងរយៈពេលដែលលោកធ្វើការខាងបំភ័ន្តអក្ខរៈទូរលេខនេះមិនដឹង -- លោកមិនច្បាស់ពីរយៈពេលរបស់លោកទេ។ តើលោកយល់ស្របដែរឬទេ ដែលលោកនិយាយអម្បាញ់មិញនេះថា លោកធ្វើការខាងទូរលេខនេះរហូតដល់ឆ្នាំ៧៧ លោកនៅរក្សាចម្លើយលោកនេះទេ?

[០៩:៤២:៣៥]

**ឆ៖** ខ្ញុំនៅជាមួយគាត់ដល់ឆ្នាំ៧៧ បាទ។ ខ្ញុំនៅបើកឡាន ខ្ញុំបកសារទូរលេខហ្នឹងដល់ឆ្នាំ -- វាក្រោយសង្គ្រាមបន្តិច ខ្ញុំចាំឆ្នាំមិនច្បាស់បាទ ដល់បងខ្ញុំមកជំនួស។ សូមបញ្ជាក់បណ្តឹងបាទ។ អត់ដល់៧៧ ទេ ខ្ទង់៧៦ ចុង៧៥ អី ឬក៏ដើម៧៦ ខ្ញុំនៅបកសារទូរលេខ។ ដល់ចូល៧៦ ហើយខ្ញុំអត់ដឹងទេបាទ។ ខ្ទង់ប៉ុណ្ណឹងអាហ្នឹង។ អាហ្នឹងវាកំណត់ឆ្នាំថ្ងៃខែវាមិនច្បាស់។ បើថា ចង់ច្បាស់ទាល់តែប្រើពេលវេលាស្រាវជ្រាវសួរអ្នកនេះ អ្នកនោះថែមទៀតបាទ។ សូមបញ្ជាក់ជូនប៉ុណ្ណឹងបាទ។ សូមបញ្ជាក់ម្តងទៀតថា មិនមែនបកសារទូរលេខដល់៧៧ទេ បាទ។ ប៉ុន្តែខ្ញុំនៅជាមួយគាត់ទាល់តែគាត់ស្លាប់នៅភ្នំពេញនេះ ៧៧ ក៏ឆ្នាំណាប្រាកដ ក៏ខ្ញុំអត់ច្បាស់ដែរ វាយូរពេកវាភ្លេច។ ប៉ុន្តែអ៊ំៗនោះគាត់អាចចាំ ឪពុកខ្ញុំស្លាប់ឆ្នាំណាខែណាប្រាកដនោះ ព្រោះអាចជាមានកត់ត្រាកត់អីទុកក៏មិនដឹង។ នេះសូមបញ្ជាក់ជូនលោកប៉ុណ្ណឹង។

[០៩:៤៤:១១]

**ស៖** លោកបានឆ្លើយជូនតុលាការថា គឺបងស្រីរបស់លោកដែលធ្វើការផ្នែកទូរលេខនេះបន្តពីលោក។ តើអ៊ីចឹងមែនទេ?

**ឆ៖** ត្រឹមត្រូវបាទ។

**ស៖** ហើយនៅពេលដែលគាត់មកជំនួសលោកនោះ លោកនៅតែធ្វើការខាងបំភ័ន្តអក្ខរៈដដែលឬក៏យ៉ាងម៉េចនៅពេលនោះ?

**ឆ៖** អត់ទេបាទ។ បងខ្ញុំគាត់អ្នកធ្វើ។

**ស៖** ក៏ប៉ុន្តែនៅពេលដែលគាត់មកដល់នោះ គឺថាលោកចេញ តើអ៊ីចឹងទេ ថាគាត់មកដល់ភ្លាមលោកចេញភ្លាម?

**ឆ៖** ត្រឹមត្រូវ បាទ។

**ស៖** បាទ ដើម្បីជួយរំឭកកាលបរិច្ឆេទដល់លោក។ មានទូរលេខមួយដែលបានបង្ហាញជូនលោក២ថ្ងៃមុននេះ ដោយសហព្រះរាជអាជ្ញា គឺទូរលេខទី៣ ដែលគាត់បានបង្ហាញលោក គឺថាឯកសារ E3/1195។ ERN ជាភាសាបារាំងគឺ 00531088, ជាភាសាខ្មែរគឺ 00057296 ហើយ ERN ជាភាសាអង់គ្លេសគឺ 00519519 គឺជាទូរលេខដែលចុះនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ សហព្រះរាជអាជ្ញាបានសួរលោកលើទូរលេខដែលផ្ញើជូនដោយសមមិត្ត ប៉ង់ ដែលលោកផ្ញើជូន -- ឪពុកលោកនោះផ្ញើជូនប៉ង់។ ហើយលោកបានឆ្លើយថា បងរបស់លោកឈ្មោះ បូផាន់ ទេដែលជំនួសលោកនៅពេលនោះធ្វើការនៅផ្នែកទូរលេខនេះ។ តើអ៊ីចឹងមែនទេ គឺបងស្រីលោកដែលឈ្មោះ បូផាន់ ហ្នឹង ឬមិនមែនទេ?

[០៩:៤៧:០២]

**ឆ៖** ត្រឹមត្រូវ ហើយបាទ។

**ស៖** ហើយនៅក្នុងទូរលេខនេះ ដែលចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ឪពុកលោកនោះប្រាប់ប៉ង់ ថាសុំឱ្យបងរបស់លោកនោះទៅរៀនទូរលេខ បើយើងជឿ -- ចុះទៅរៀនឯកសារសម្ងាត់នោះ។ អ៊ីចឹងបើយើងជឿនូវឯកសារនេះ គឺថានៅថ្ងៃ២៥ ខែ១១ ឆ្នាំ១៩៧៦នេះ បងស្រីរបស់លោកមិនទាន់ទទួលការបណ្តុះបណ្តាលផ្នែករៀនឯកសារសម្ងាត់នេះទេ។ តើនេះព័ត៌មានដែលខ្ញុំ អ្វីដែលខ្ញុំរៀបរាប់ប្រាប់អម្បាញ់មិញនេះអាចជួយរំឭកលោកបានទេ ឱ្យចាំពីកាលបរិច្ឆេទនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ ខ្ញុំសូមជំទាស់លើរបៀបចោទសំណួរនេះ។ បាទ នៅក្នុងឯកសារនេះពិតជាមានសរសេរមែនថា “ខ្ញុំឲ្យក្អួយ បូផាន់ ទៅរៀនឯកសារសម្ងាត់”។ នេះមិនមែនប្រាកដថា បាន មានន័យថា -- ប្រាកដថា មានន័យថា ទើបតែទៅរៀនទេ អាចថាបន្តរៀនទៀត។ ព្រោះពីមុនមក គាត់ប្រហែលជាអាចធ្លាប់បាន រៀនបកប្រែឯកសារសម្ងាត់នេះហើយ។ អ៊ីចឹងសូមឲ្យកែប្រែរបៀបសួរ។

[០៩:៤៨:៥២]

**លោក អាកឡូវ វែកគែន៖**

ខ្ញុំសូមជំទាស់នឹងការទំនាស់របស់គាត់។ គាត់ធ្វើដូចចង់ គាត់ថាខ្ញុំ -- គាត់និយាយអំមិញនេះ ដូចថាប្រាប់ចម្លើយទៅសាក្សីអ៊ីចឹងឯង។

បាទ ខ្ញុំសូមបន្តសំណួរទៅទៀត។ អ៊ីចឹងយើងនឹងសួរទៅបងស្រីគាត់ នៅពេលដែលបងស្រី គាត់មកផ្តល់ចម្លើយនៅទីនេះ។ ឥឡូវ ខ្ញុំសួរទៅសាក្សីនេះសិន។ អ៊ីចឹងសូមឲ្យគាត់ជួយធ្វើការសន្និដ្ឋាន ទាញការសន្និដ្ឋានពីទូរលេខនេះសិនទៅ។ ចាំពេលដែលបងស្រីគាត់មក ចាំសួរគាត់ទៀត។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនអាចផ្តល់ចម្លើយតាម -- ជាការសន្និដ្ឋានទេ។

លោករៀបចំសំណួរឡើងវិញ ដើម្បីសួរសាក្សីទៅតាមអង្គហេតុជាក់លាក់ដែលគាត់ដឹង។ សូមអញ្ជើញលោកមេធាវី រៀបចំសំណួរឡើងវិញ ហើយមិនតម្រូវឲ្យគាត់ឆ្លើយតបជាសេចក្តីសន្និដ្ឋានទេ។ គាត់ដឹង ឬក៏មិនដឹង។

[០៩:៥០:២៤]

**លោក អាកឡូវ វែកគែន៖**

បាទ លោកប្រធាន។

**សួរដោយលោក អាកឡូវ វែកគែន៖**

**ស៖** បាទ ខ្ញុំសូមសួរឡើងវិញ លោកៗសាក្សី កន្លងមកនេះលោក គេឲ្យលោកធ្វើអត្ថាធិប្បាយ

លើៗទូរលេខ ដែលក្នុងហ្នឹងឪពុកបាននិយាយអំពីការជូន -- សុំឲ្យបងរបស់លោកទៅរៀនឯកសារសម្ងាត់ តើលោកយល់យ៉ាងម៉េចដែរអំពីការចុះកាលបរិច្ឆេទថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ នេះ តើៗកាលបរិច្ឆេទនេះធ្វើឲ្យលោកយល់យ៉ាងម៉េចដែរ? លោកយល់ៗឃើញយ៉ាងម៉េចដែរ នៃកាលបរិច្ឆេទថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦នេះ ទាក់ទងនឹងការបណ្តុះបណ្តាលផ្នែកឯកសារសម្ងាត់ទៅកាន់បងស្រីលោកនេះ?

[០៩:៥១:២១]

**លោក ផាន វ៉ាន់៖**

**ផ៖** ខ្ញុំៗមិនបានដឹងទេបាទ ថាបងខ្ញុំមករៀនទៀត ឬក៏យ៉ាងម៉េច។ គ្រាន់តែថាបងខ្ញុំគាត់រៀនមកៗពីក្រៅមកបាទ។ គាត់ចេះមកតាំងពីយូរមកហើយ។ គាត់នៅក្រៅគាត់ចេះខាងអង្គុលីលេខហ្នឹង ខាងសារទូរលេខហ្នឹង។ មានតែប៉ុណ្ណឹង។

**លោក អាកទូរ វែកកែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរអស់លោក លោកស្រីទាំងក្នុងនិងក្រៅសាលសវនាការ។

[០៩:៥២:២៥]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ម៉ៃខល កាណាវាស ខ្ញុំគឺជាមេធាវីរួមជាមួយនឹងលោក អាង ឧត្តម ជាមេធាវីការពារក្តីលោក អៀង សារី។ ខ្ញុំសូមចាប់ផ្តើមដោយផ្តោតជាសំខាន់ទៅលើអាយុរបស់លោក។ ខ្ញុំមើលទៅលើចម្លើយរបស់លោក លោកបាននិយាយថា លោកបានប្រាប់អ្នកស៊ើបអង្កេតថា លោកកើតនៅឆ្នាំ១៩៦០ ប៉ុន្តែថ្ងៃនេះលោកនិយាយថាអាចលើសខ្វះ១ឆ្នាំ។ នៅពេលដែលលោកផ្តល់ចម្លើយទៅដល់អ្នកស៊ើបអង្កេត ដែលថាលោកកើតនៅឆ្នាំ១៩៦០ តើលោកពិតជាដឹងច្បាស់

អំពីឆ្នាំកំណើត ឬក៏ថ្ងៃខែឆ្នាំកំណើតលោកច្បាស់ដែរឬទេ? ថាតើលោកប្រាកដថាលោកកើតនៅឆ្នាំ៦០ ឬក៏កើតនៅឆ្នាំ៥៩ ឬក៏៦១នោះ?

**លោក ផាន វ៉ាន់៖**

**ផ៖** បាទ ចំពោះសំណួរហ្នឹងខ្ញុំ កាលទៅស៊ើបអង្កេតហ្នឹងក៏បានជជែកគ្នាដែរ តាំងពីជំនាន់ធ្វើអត្តសញ្ញាណបណ្ណម្ល៉េះ។ បានជជែកអត់ច្បាស់លាស់ទេ អារឿងអាយុប្រាកដប្រាជាហ្នឹងបាទ។ សួរបងក៏មិនច្បាស់ សួរអ្នកនៅជាមួយពីដើមមកក៏គេអត់ច្បាស់ដែរ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។ គ្រាន់តែដឹងថាក្នុងអំឡុងៗប្រហែលៗប៉ុណ្ណឹង។

[០៩:៥៤:00]

**ស៖** សូមអរគុណ។ នៅពេលដែលលោកសួរបងប្អូនលោកនៅក្នុងពេលសម្ភាស ឬក៏មុនការសម្ភាស ឬក៏ក្រោយការសម្ភាស គឺការសួរអំពីអាយុរបស់លោកនោះ?

**ផ៖** ធ្វើអត្តសញ្ញាណបណ្ណបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំបន្តទៅសំណួរដើមរបស់ខ្ញុំវិញ។ ដោយសារតែបងប្អូនរបស់លោកមិនអាចប្រាប់ពីអាយុបានដូច្នេះនៅពេលដែលស៊ើបអង្កេតមកហ្នឹង លោកក៏ប្រាប់គេ។ ប៉ុន្តែខ្ញុំចង់ដឹងថា តើលោកមានប្រាប់គេថា លោកមិនច្បាស់ថាលោកកើតឆ្នាំ៦០ ឬក៏៥៩ ឬក៏៦១ នោះទេ? តើលោកមានប្រាប់គេថាលោកមិនច្បាស់ ឬមួយក៏លោកប្រាប់ត្រង់ ប្រាប់ភ្លាមតែម្តងថាលោកកើតខែធ្នូ ឆ្នាំ៦០នេះ?

**ផ៖** ប្រាប់ថាមិនច្បាស់បាទ ហើយខាងស៊ើបអង្កេតគេថាយកតាមផ្លូវការ តាមអត្តសញ្ញាណប័ណ្ណបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំចង់ផ្តោតអំពីពេលវេលាដែលលោកធ្វើជាអ្នកបើកបរដែលយើងដឹងថាលោកមិនដឹងច្បាស់អំពីថ្ងៃខែឆ្នាំកំណើតរបស់លោក តើលោកដឹងដែរឬទេថានៅពេលដែលលោកធ្វើជាអ្នកបើកបរហ្នឹង តើលោកមានអាយុប៉ុន្មានដែរ?

**ផ៖** អត់ដឹងច្បាស់ដែរបាទគ្រាន់តែប្រហែលៗ ប្រហែលអាយុ១៧, ១៨ បាទ។

[០៩:៥៥:៥៨]

**ស៖** ដូច្នេះប្រហែលជាអាច ១៦ ឬ១៥ ផងដែរ ដោយសារតែលោកមិនច្បាស់ថា លោកកើតឆ្នាំណាអ៊ីចឹងទេ?

**ឆ៖** ដូចអត់ ១៥ទេ ពីព្រោះអីខ្ញុំបើកឡានតាំងពីនៅជាមួយឪពុកខ្ញុំបើកឡានកាំមីញ៉ុងធំៗ ខ្ញុំបើកបានបាទ។

**ស៖** តើដោយសារតែនៅពេលនុ៎ងអ្នកមានច្បាប់ហាមឃាត់ថាអ្នកអាយុ ១៥, ១៦ឆ្នាំ មិនអាចបើកឡានធំ ឬមួយក៏ដោយសារលោកគិតលើកម្ពស់ទាបខ្ពស់ ដែលលោកនិយាយថាលោកអាចបើកឡានធំនោះបាន តើដោយសារចំណុចណាមួយដែរ?

**ឆ៖** ចំណុចជើងខ្ញុំជាន់អំប្រ៊ីយ៉ាដល់បាទ ហើយនិងកម្លាំង។

**ស៖** ចុះប្រសិនបើលោកអាយុ១៦ឆ្នាំ ពេលនុ៎ងប្រហែលជាលោកខ្ពស់ល្មមអាចជាន់អំប្រ៊ីយ៉ាបាន ហើយលោកមានកម្លាំងគ្រប់គ្រាន់ក្នុងការបើកឡាន តើលោកយល់ឃើញយ៉ាងម៉េចដែរ ប្រសិនបើលោកអាយុ១៦ឆ្នាំវិញ?

[០៩:៥៧:៣៣]

**ឆ៖** បើអាយុតិចបើកឡានមានកម្លាំងខ្លាំងល្អបាទ។

**ស៖** ប៉ុន្តែលោកនិយាយអ៊ីចឹង អត់បានឆ្លើយសំណួរខ្ញុំទេ។ អ្វីដែលខ្ញុំចង់និយាយ ខ្ញុំចង់ដឹងថាលោកប្រាកដទេដែលថាលោកអាយុ១៧, ១៨ឆ្នាំ តើវាអាចដែរឬទេ ដែលថាលោកអាចក្មេងត្រឹមតែអាយុ១៦ឆ្នាំ ហើយលោកមកបើកនៅទីក្រុងភ្នំពេញនោះ តើវាអាចដែរឬទេ?

**ឆ៖** ដូចមិនអាចទេបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងបន្តទៅមុខទៀត។ ក្នុងនាមជាអ្នកបើកបរតើវាជាតួនាទីរបស់លោកដែរឬទេដែលត្រូវចូលរួម? ក្នុងចង់និយាយថា ក្នុងនាមជាអ្នកបើកបរលោកមិនត្រឹមតែដឹកពីមួយកន្លែងទៅមួយកន្លែង ដឹកពីចំណុច "ក" ទៅចំណុច "ខ" នោះទេ ប៉ុន្តែលោកក៏មានតួនាទីចូលរួមការប្រជុំអីដែរ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** អត់មានទេបាទ។

**ស៖** តើលោកធ្លាប់ចូលទៅក្នុងបន្ទប់ប្រជុំ បានន័យថា ត្រឹមតែចូលក្នុងបន្ទប់ប្រជុំ ហើយអាចឃើញថាអ្នកណាចូលរួមខ្លះ ឬក៏មានអ្នកចូលរួមអ្វីខ្លះដែរឬទេ?

[០៩:៥៩:១០]

**ឆ៖** ក្នុងនាមអ្នកបើកឡានបានជូនត្រឹមកន្លែងៗមាត់ទ្វារហ្នឹង។ អ៊ំអីគាត់ចុះទៅកន្លែងៗប្រជុំទៅខ្ញុំអត់មានសិទ្ធិអីទៅកន្លែងប្រជុំទេបាទ។ គ្រាន់តែដឹងថាប្រជុំជាមួយអ្នកណាៗប៉ុណ្ណឹងឯង បើនៅក្រសួង

មានប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ តើលោកបើកឡាន ហ្នឹងគឺថាដឹកទៅដល់បន្ទប់ប្រជុំដល់មាត់ទ្វារតែម្តង ឬក៏លោកឈប់ពីចម្ងាយ? តើចម្ងាយប៉ុនណាដែរ ពីកន្លែងដែលលោកដាក់មនុស្សចុះហ្នឹង ធៀបទៅនឹងបន្ទប់ប្រជុំនោះ?

**ឆ៖** នៅរបងខាងក្រៅបាទ។

**ស៖** លោកចង់និយាយអំពីខ្លោងទ្វារនៃច្រកចូលទៅក្នុងអគារ ឬមួយក៏លោកនិយាយពីខ្លោងទ្វារនៃអគារប្រជុំនោះ តើលោកចង់និយាយពីខ្លោងទ្វារមួយណា?

**ឆ៖** ខ្លោងទ្វារចូលកន្លែងហ្នឹងបាទ អគារប្រជុំ។

**ស៖** ហើយនៅខាងក្រៅខ្លោងទ្វារអគារនុំងតើចម្ងាយពីខ្លោងទ្វារហ្នឹងទៅកន្លែងប្រជុំ គឺទៅបន្ទប់ប្រជុំហ្នឹងវាមានចម្ងាយប៉ុន្មានដែរ លោកអាចប្រាប់បានទេ?

**ឆ៖** លោកសួរ -- វាច្រើនកន្លែងបាទ វាមិនមែនតែមួយកន្លែងឯណា ទៅត្រង់នេះទៅត្រង់នោះ។ ឈប់តែកន្លែងមាត់ទ្វារហ្នឹង គាត់ទៅៗ ខ្ញុំនៅខាងក្រៅទៅ នៅយាមឡានហ្នឹងបាទ។ កន្លែងខ្លះឆ្ងាយ កន្លែងខ្លះជិតទៅ អត់ទៀងទេបាទ។

[១០:០១:២០]

**ស៖** នៅពេលដែលលោករង់ចាំ ខ្ញុំគិតថា លោករង់ចាំខាងក្រៅនៅពេលដែលការប្រជុំហ្នឹងកំពុងតែបន្ត តើលោករង់ចាំនៅខាងក្នុងបរិវេណអគារហ្នឹង ឬមួយក៏លោករង់ចាំខាងក្រៅបរិវេណទេ?

**ឆ៖** តួនាទីអ្នកបើកឡាននៅយាមឡានបាទ អត់មានចោលឡានបានទេជំនាន់ហ្នឹង នៅតែនឹងឡានហ្នឹង។

**ស៖** តើមានរបងព័ទ្ធជុំវិញអគារ មានរបងព័ទ្ធជុំវិញ ឬក៏អត់មានរបងទេនៅអាកន្លែងប្រជុំនោះ?

**ឆ៖** កន្លែងខ្លះមាន កន្លែងខ្លះអត់បាទ។

**ស៖** នៅពេលដែលលោករង់ចាំ គឺរង់ចាំខាងក្រៅ គឺលោកអង្គុយចាំក្នុងឡានលោកនោះ តើលោកមានបានជជែកជាមួយអ្នកយាម ឬក៏សន្តិសុខថា តើប្រជុំហ្នឹងប្រជុំពីអ្វី? គេប្រជុំជាមួយអ្នកណាខ្លះ ឬក៏មានប្រធានបទអីនៃការប្រជុំហ្នឹង តើលោកមានបានជជែកពីបញ្ហាហ្នឹងទេជាមួយអ្នកយាមនោះ?

[១០:០២:៤៨]

**ឆ៖** អត់មានទេបាទ។

**ស៖** នៅពេលដែលលោកដឹក ជូនទៅកន្លែងប្រជុំនោះ ក្នុងនាមលោកជាអ្នកបើកឡាន តើលោកមានជជែកជាមួយអ្នកដែលលោកដឹកទៅហ្នឹងដែរឬទេ? តើលោកមានសួរថាតើប្រជុំហ្នឹងប្រជុំពីអី និយាយជាមួយអ្នកណា? ឬក៏ប្រជុំពីប្រធានបទអី? តើលោកមានជជែកជាមួយអ្នកដែលលោកដឹកទៅហ្នឹងដែរឬទេ?

**ឆ៖** អត់ទេបាទ។

**ស៖** នៅពេលដែលប្រជុំបញ្ចប់ ហើយលោកត្រូវដឹកភ្ញៀវ ដឹកអ្នកហ្នឹងត្រឡប់មកកន្លែងវិញហ្នឹង តើលោកមានបានជម្រាបសួរគាត់អំពីការប្រជុំហ្នឹង តើអ្នកដែលជិះឡានជាមួយលោកហ្នឹងគាត់មានប្រាប់ថា គេប្រជុំនិយាយពីអ្វី? អ្នកណានិយាយពីអ្វីខ្លះ ហើយមានអ្នកណាចូលរួមខ្លះក្នុងកិច្ចប្រជុំអីហ្នឹង តើលោកមានជជែកជាមួយអ្នកដែលជិះជាមួយលោកហ្នឹងដែរទេ អំពីបញ្ហានេះ?

[១០:០៣:៥៥]

**ឆ៖** អត់មានបានជជែកទេបាទ។

**ស៖** ឥឡូវនេះ ខ្ញុំសូមលើកយកចំណុចមួយទៀត គឺមុនពេលដែលលោកធ្វើជាអ្នកបើកបរ។ ខ្ញុំមិនចង់និយាយលម្អិតអំពីមុខងារលោកនៅពេលនោះទេ ប៉ុន្តែខ្ញុំលើកយកតែចំណុចតូចមួយគឺទាក់ទងនឹងតួនាទីរបស់ឪពុកលោក លោកបានប្រាប់ថាឪពុកលោកគឺជាលេខាតំបន់ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវបាទ។

**ស៖** តើតួនាទីជាលេខាតំបន់ហ្នឹងជាតួនាទីសំខាន់ តើមែនដែរឬទេ?

**ឆ៖** សម័យនុ៎ង ខ្ញុំអត់ដឹងថាសំខាន់ ឬមិនសំខាន់ទេ ដឹងតែថាលេខាតំបន់តែប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ លោកបានរៀបរាប់អំពីការបំភ័ន្តអក្ខរៈ ការបកប្រែ ការបោសសម្អាត ប៉ុន្តែឥឡូវនេះ ខ្ញុំដូចជាវង្វេងវង្វាន់អស់ហើយ។ លោកបាននិយាយថា លោករស់នៅក្នុងរបបនោះ ធ្វើការជាមួយឪពុក ជាមួយនឹងអ្នកដទៃ ប៉ុន្តែឥឡូវបែរជាលោកនិយាយថា លោកអត់ដឹងថា តួនាទីឪពុករបស់លោកហ្នឹងសំខាន់ ឬក៏មិនសំខាន់។ តើអាហ្នឹងគឺជាអ្វីដែលលោកចង់និយាយនៅថ្ងៃហ្នឹង តើមែនដែរឬទេ?

**ឆ៖** ខ្ញុំអត់យល់ច្បាស់សំណួររបស់លោកសោះ។ ន័យសំខាន់ហ្នឹងសំខាន់យ៉ាងណា? ស្អីយ៉ាងម៉េចហ្នឹង? ទាល់តែ -- ដល់អីចឹងខ្ញុំអត់យល់ពាក្យថា សំខាន់ហ្នឹងស្អីទៅបាទ?

[១០:០៥:៥៤]

**ស៖** ដូច្នេះ ខ្ញុំសូមបញ្ជាក់ នៅក្នុងតំបន់ ថាតើនៅក្នុងតំបន់ហ្នឹងមានអ្នកណាធំជាងឪពុករបស់លោកដែរឬទេ ឬក៏មានអ្នកណាដែលនៅពីលើ មានតួនាទីលើឪពុកលោកទេ?

**ឆ៖** អត់មានទេបាទ។

**ស៖** សូមអរគុណ។ តាមរយៈចម្លើយរបស់លោកហ្នឹង តើលោកអាចសន្និដ្ឋានបានទេ តើយើងអាចនិយាយបានទេថា ក្នុងតំបន់ហ្នឹងឪពុកលោក គឺជាមនុស្សដែលសំខាន់ជាងគេបំផុត។ តើយើងអាចនិយាយបែបនេះបានដែរឬទេ? តើយើងគួរតែមានអ្វីជាការសង្ស័យដែរឬទេ ឬក៏យើងប្រាកដថាគាត់សំខាន់មែន?

**ឆ៖** ក្នុងជំនាន់ហ្នឹង អាចចាត់ទុកថាជាសំខាន់ក៏បានដែរបាទ។

**ស៖** ឥឡូវនេះ តាមអ្វីដែលខ្ញុំយល់លោកត្រឹមត្រូវនោះ លោកឆ្ងល់ លោកសង្ស័យថា ហេតុ-ការណ៍ពិតដែលឪពុករបស់លោក គឺជាមនុស្សសំខាន់ ជាមនុស្សមានអំណាចខ្លាំងនៅក្នុងតំបន់ នៅពេលដែលគាត់ជាលេខានៃតំបន់ដែលមិនមានអ្នកណាជាថ្នាក់លើរបស់គាត់ទេនៅតំបន់នោះ?

[១០:០៧:២៨]

**ឆ៖** តាមទស្សនៈខ្ញុំ តាំងពីសម័យ គិតឥឡូវនេះ ថាគ្មានអីសំខាន់ទេជំនាន់ហ្នឹងបាទ។ ប៉ុន្តែអ្នកទទួលខុសត្រូវចំពោះបក្ស តែប៉ុណ្ណឹងឯងបាទ សម័យហ្នឹង។ គេមិនកំណត់ថាសំខាន់ស្អីឯណាអត់មានទេ។ អានេះឲ្យលោកយល់អីចឹងបាទ។

**ស៖** សូមអរគុណដែលលោកបានធ្វើការប្រៀបធៀប ប៉ុន្តែយើងចង់និយាយអំពីហេតុការណ៍នៅសម័យនោះ។ អ្វីដែលលោកអាចគិតថា លេខា ឬក៏អនុលេខា ឬក៏អ្នកណាធ្វើនៅទីនេះទេ យើងនិយាយកាលនោះ សូមលោកប្រាប់ខ្ញុំនិងតុលាការ ថាតើលោកមានការសង្ស័យដែរឬទេ ថាឪពុករបស់លោកមិនមែនជាមនុស្សសំខាន់ មានអំណាចខ្លាំងទេ នៅក្នុងតំបន់នោះទេ នៅពេលដែលគាត់ជាលេខាតំបន់។ ជាសំណួរដែលឲ្យលោកឆ្លើយថា បាទ ឬក៏មិនមែន ឬក៏លោកអាចឆ្លើយថា ខ្ញុំមិនដឹង។

**ឆ៖** ខ្ញុំជឿថាគាត់អត់មែនជាមនុស្សសំខាន់អី មានអំណាចអីតែឯងអីទេបាទ។

[១០:០៨:៥២]

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងដឹងថា លោកធ្វើការឲ្យឪពុករបស់លោក ហើយធ្វើការបកទូរលេខ ហើយនិងបំភ័ន្តអក្ខរៈមួយចំនួន ហើយនិងសារសម្ងាត់។ តើឪពុករបស់លោកធ្លាប់ប្រាប់ពីមុខងាររបស់គាត់ដល់លោកទេនៅពេលដែលថា លោកធ្វើការឲ្យគាត់ថា តួនាទីរបស់គាត់ជាអ្វី ការងារ

របស់គាត់ជាអ្វី នៅពេលដែលគាត់ជាលេខានៃតំបន់នោះ?

**ឆ៖** អត់ទេបាទ។

**ស៖** តើឪពុករបស់លោកនៅពេលណាមួយនោះ ធ្វើការប្រជុំជាសម្ងាត់ជាមួយបុគ្គលណាផ្សេងមួយចំនួនដែរឬទេ នៅពេលដែលគាត់ជាលេខាតំបន់នោះ?

**ឆ៖** អត់មានទេបាទ។

**ស៖** ថាតើគាត់បានរៀបចំការប្រជុំដែរឬទេ?

**ឆ៖** ប្រជុំមាន ដូចៗបានប្រាប់នៅឯកសារហ្នឹងបាទ។

**ស៖** តើក្នុងការប្រជុំទាំងអស់នោះលោកវត្តមានទេ? លោកនៅទីនោះទេ?

**ឆ៖** អត់ទេបាទ។

[១០:១០:២២]

**ស៖** ដោយហេតុថាការប្រជុំនោះជាសម្ងាត់ ឬក៏ដោយហេតុថាលោកមិនមានតួនាទីអ្វី ដែលជាអ្នកចូលរួមក្នុងប្រជុំនោះ តើណាមួយ?

**ឆ៖** ខ្ញុំអត់មានតួនាទីអីទេ ព្រោះខ្ញុំក្មេងបាទ។

**ស៖** បាទ ហើយលោកមិនបានចូលប្រជុំនោះទេ ដោយថាលោកមិនមានតួនាទី ឬក៏លោកមិនមានតំណែងអ្វីត្រូវចូលរួមប្រជុំ។ តើឪពុករបស់លោកប្រាប់ជាមុនទេ ថាតើការប្រជុំហ្នឹងគេនិយាយពីអ្វី? ឬក៏ក្រោយប្រជុំមកលោក -- គាត់ប្រាប់លោកថាប្រជុំហ្នឹងប្រជុំពីអ្វីទេ ក្នុងករណីនោះ?

**ឆ៖** គាត់អត់មានប្រាប់ទេបាទ ព្រោះខ្ញុំអត់មានតួនាទីអី គាត់ប្រាប់តែគ្នាគាត់ក្នុងគណៈគេហ្នឹងតែប៉ុណ្ណឹងបាទ។

**ស៖** តើលោកបានសួរគាត់ទេ ដើម្បីឲ្យគាត់ប្រាប់ពីព័ត៌មានថ្មីៗថាតើគាត់ប្រជុំជាមួយអ្នកណា? តើប្រធានបទអ្វី? គេសម្រេចអ្វី? តើគេសម្រេចអ្វី? ហើយចេញបញ្ហាបែបណា? តើលោកបានសួរបែបនោះ ឬក៏គាត់ប្រាប់លោកបែបនោះដែរឬទេ?

**ឆ៖** អត់ប៊ានសួរទេបាទ ហើយក៏អត់មានប្រាប់អីដែរ ពីព្រោះវាអត់មានត្រូវការងារខ្ញុំផងបាទ។

[១០:១១:៥៧]

**ស៖** ដោយហេតុនោះ គឺដោយសារតែនៅក្នុងសម័យកាលនោះ ការសម្ងាត់គឺជាបញ្ហាសំខាន់បំផុតនៅពេលនោះ។ ចំពោះម្នាក់ៗនោះ ជាពិសេសចំពោះបុគ្គលណាម្នាក់ដែលមានតំណែងជាលេខានោះ

លេខាតំបន់នោះ។ តើអ៊ីចឹងឬទេ?

**ឆ៖** ត្រឹមត្រូវហើយ អង្គាល់ជំនាន់ហ្នឹងគេប្រើពាក្យថា "ការងារអ្នកណា អ្នកហ្នឹងដឹង កុំចង់ដឹងរឿងគេ"។ នេះសូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**សៈ** ហើយខ្ញុំប្រកាន់ពាក្យលោកថា "លោកយកតែការងាររបស់ខ្លួនទេ មិនត្រូវដឹងរឿងគេ" តើអ៊ីចឹងដែរឬទេ?

**ឆ៖** គេកំណត់អ៊ីចឹងតែម្តងសម័យហ្នឹងបាទ។

**សៈ** ហើយនយោបាយគឺជារឿងមួយ ហើយការអនុវត្តជារឿងមួយ។ ខ្ញុំចង់ឲ្យលោកឆ្លើយលោកសាក្សី តើលោកគោរពតាមមាគ៌ានយោបាយគេដែរឬទេ?

**ឆ៖** គោរព។ អត់មាននរណាមួយថា អត់ប៉ានគោរពទេបាទ។

**សៈ** សូមអរគុណ។ ឥឡូវនេះ លោកបានប្រាប់តុលាការថា "ក្នុងឱកាសមួយឪពុករបស់លោកទៅភ្នំពេញ ហើយលោកក៏បានទៅជាមួយគាត់ក្នុងឱកាសមួយ"។ តើលោកបានអមដំណើរគាត់ចូលទៅប្រជុំនោះទេ? ឬក៏លោកនៅខាងក្រៅទេ?

[១០:១៣:៣៦]

**ឆ៖** អត់បានទៅទេបាទ។ ខ្ញុំមកភ្នំពេញ មកត្រឹមមន្ទីរពាណិជ្ជកម្ម ដូចខ្ញុំបានបញ្ជាក់ខាងដើមហើយ។

**សៈ** ហើយខ្ញុំសូម សូមឲ្យលោកបំភ្លឺទៀត ដែលនៅក្នុងការប្រជុំទាំងអស់នោះដែលថាការប្រជុំខ្លះនៅភ្នំពេញ តើឪពុករបស់លោកបានប្រាប់លោកថា តើការប្រជុំហ្នឹងអំពីអ្វី? ពេលមុនប្រជុំ ឬក៏ក្រោយពីការប្រជុំគាត់ប្រាប់លោកដើម្បីឲ្យលោកបានដឹងអំពីស្ថានភាពដែរឬទេ?

**ឆ៖** អត់បានដឹងទេបាទ។ ហើយគាត់ក៏អត់ប្រាប់ដែរ។ មានតែប៉ុណ្ណឹង។

**សៈ** ដើម្បីឲ្យប្រាកដថា ខ្ញុំយល់ច្បាស់អំពីចំណុចនេះ ឬក៏តុលាការបានជ្រាបច្បាស់នោះ នៅពេលដែលលោកនៅភ្នំពេញកាលនោះ តើលោកបានចូលរួមប្រជុំសំខាន់ៗ ឬក៏មហាសន្និបាត មហាមីទ្ទិងណាដែរឬទេ? ដែលគេអាចចេញសេចក្តីសម្រេចណាមួយនៅពេលនោះដែរឬទេ?

**ឆ៖** អត់ទេបាទ។

[១០:១៤:៥៦]

**សៈ** បន្ទាប់ពីនោះទៀត លោកបាននិយាយអំពីឪពុករបស់លោក ថាតើមានអ្នកណាផ្សេងទៀត

ប្រាប់លោកថា តើមានអ្វីកើតឡើង មានសេចក្ដីសម្រេច ឬក៏ប្រធានបទអីគេពិភាក្សា ហើយមានការសម្រេចអ្វីនៅក្នុងការប្រជុំទាំងអស់នោះ ឬក៏មហាមីទ្ទិងទាំងអស់នោះ?

**ឆ៖** ខ្ញុំអត់ដឹងទេបាទ។

**ស៖** សូមអរគុណ។ ប្រធានបទចុងក្រោយរបស់ខ្ញុំ ខ្ញុំនិយាយដោយសង្ខេបអំពីការសម្ភាសរបស់លោក បទសម្ភាសន៍មួយចំនួនដែលលោកបានឆ្លើយនោះ។ គួរកត់សម្គាល់ថា លោកបានផ្ដល់ភស្តុតាងនៅពេលដែលសហព្រះរាជអាជ្ញាសួរលោកនោះ នៅពេលមួយដែលថាការចងចាំនោះគឺត្រូវរំឭកឡើងវិញមុនពេលដែលប្រាប់ទៅអ្នកស៊ើបអង្កេត ពីព្រោះថាលោកមិនអាចនឹកឃើញភ្លាមៗបាន។ តើលោកអាចមានសេចក្ដីពន្យល់អ្វីទេ ថាហេតុអីបានជាបែបហ្នឹងដែរថា លោកអាចយល់ដឹងរស់រវើកថ្មីៗដ៏លម្អិត នៅពេលដែលផ្ដល់ការសម្ភាសទៅឱ្យអ្នកស៊ើបអង្កេត ប៉ុន្តែមួយឆ្នាំពីរឆ្នាំចុងក្រោយមកលោកមិនមានការចងចាំលម្អិតនោះទេ សូមលោកពន្យល់តុលាការបាទ។

**ឆ៖** បញ្ហាហ្នឹងខ្ញុំចង់ពន្យល់អ៊ីចេះ ចង់ថា ពេលមួយសួរអ៊ីចឹង សួរប្រចុចញ៉ុច ខ្ញុំក្ដាប់មិនបាន។ ពេលដែលសាកសួរដូចសន្ទនាគ្នាលេង លើកឧទាហរណ៍ពីនេះ ពីនោះ នៅឯណាអីនៅឯណាអ៊ីចឹងទៅខាងស្រាវជ្រាវគេចងក្រង ដល់ចងក្រងទៅយកជាឯកសារមកមើលទាំងអស់គ្នា អើ! ហេតុការណ៍ពីថ្ងៃនេះកើតដល់ថ្ងៃនេះវាមានស្អីៗអ៊ីចឹង ចេះតែរៀបរាប់បានហើយ។ ដល់មកសួរឱ្យឆ្លើយប្រចុចញ៉ុចអ៊ីចឹងខ្ញុំឆ្លើយមិនត្រូវដែរបាទ។ នេះចង់បញ្ជាក់ប៉ុណ្ណឹង ហើយខ្ញុំក៏អត់យល់ដែរបាទ។ អាហ្នឹងមួយ។ ទី២ទៀតមក នៅក្នុងសាលប្រជុំមនុស្សច្រើន យើងវាមិនដែលចូលក្នុងវេទិកាគេ។ អ៊ីចឹងដល់ឆ្លើយទៅវារតិបរតុប ហើយរៀបពាក្យ ក៏ខ្ញុំមិនចេះរៀបពាក្យទៅទៀត។ នេះចង់បញ្ជាក់ជូនលោកអ៊ីចឹង ព្រោះខ្ញុំវប្បធម៌ក៏មិនបានរៀនសូត្រជ្រៅជ្រះពីអក្សរសាស្ត្រអីៗ ប៉ុនរៀនបានអាន និងសរសេរ និងប្រកបតែប៉ុណ្ណឹងបាទ។ សូមបញ្ជាក់ជូនលោកប៉ុណ្ណឹង។

[១០:១៧:១៣]

**ស៖** ខ្ញុំអាចយល់ការពន្យល់របស់លោក។ ខ្ញុំមិនផ្ចាញ់លោកដោយសំណួរច្រើនពេកនោះទេ ខ្ញុំសួរយឺតៗតែប៉ុណ្ណោះ ប៉ុន្តែខ្ញុំសូមសួរលោកបន្តទៅទៀត។ នៅពេលដែលលោកផ្ដល់សម្ភាសនេះ ដែលជាបែបការសន្ទនា ដែលលោកអាចប្រមូលការចងចាំ ហើយគិតឃើញបាន ថាតើអ្នកស៊ើបអង្កេតដែលនិយាយជាមួយលោកនោះ មុនពេលដែលគេសម្ភាសហើយថតខ្សែអាត់ដែលឬទេ ដើម្បីឱ្យដឹងថាការចងចាំម៉េច? លោកដឹងអ្វីខ្លះ តើមានបែបនោះដែរឬទេ?

[១០:១៧:៥៥]

**ឆ៖** ការស្រាវជ្រាវហ្នឹងមាន មានថតហើយសាចុះសាឡើងជជែកគ្នាសាចុះសាឡើង។ មានប៉ុណ្ណឹងបាទ។

**ស៖** បាទគិតថាអាចជាការបកប្រែទៅមិនសូវច្បាស់ ឬក៏លោកអាចនិយាយខុស។ ខ្ញុំចង់ឲ្យច្បាស់ តើលោកនិយាយថាតើមានការសន្ទនាមុន ហើយគេសម្ភាសហើយបានថតខ្សែអាត់ ឬក៏យ៉ាងម៉េច? តើវាកើតមានឡើងអ៊ីចឹងដែរឬទេ ដែលថាលោកស្ដាប់សំណួរពេលនេះនោះ?

**ឆ៖** អត់ទេនិយាយបណ្ដើរថតទុក ដូចនិយាយអ៊ីចឹងថតទុករហូតបាទ ដល់ហើយបើថាខុសសារិញមកកែនិយាយជជែកគ្នាថាអាហ្នឹងត្រឹមត្រូវ ឬមិនត្រឹមត្រូវអ៊ីចឹង។ ហើយនឹកឃើញតាមហ្នឹងមែនឬអត់ស្អីៗ ជជែកគ្នាលុបចេញ អាណាអត់ត្រូវនិយាយទៀត រកនឹកឃើញទៀត អ៊ីចឹងបាទ។

**ស៖** ខ្ញុំមិនប្រាកដថាខ្ញុំយល់ច្បាស់ចម្លើយចុងក្រោយរបស់លោកទេ។ តើលោកនិយាយថាបើសិនមានអ្វីខុស ពីព្រោះខ្ញុំមើលឃើញថា ការបកប្រែនោះគឺថាចម្លើយត្រឹមត្រូវៗ ពេលខ្លះគឺថានឹងកែតម្រូវ ឬក៏ខុសលុបចេញ ថាតើសូមលោកប្រាប់ឲ្យច្បាស់មើល ថាតើមានន័យដូចម្ដេចដែលថាកែតម្រូវឡើងវិញ ឡើងចុះនោះ?

[១០:១៩:៣៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាសំណួរចុងក្រោយនេះត្រូវតែរៀបចំឡើងវិញដើម្បី ឲ្យមានលក្ខណៈបើកចំហបន្តិច ទុកឲ្យសាក្សីពន្យល់ជៀសវាងឆ្លើយដោយសារមានការនាំមុខពីខាងមេធាវី។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន លោក លោកស្រីចៅក្រម គឺថា -- ហើយការសួរគឺថា បើកចំហគឺថា ខ្ញុំបានសួរគឺជាសំណួរដែលសួរពីរបៀប ថាតើកើតឡើងដោយវិធីណា? តើអ្វីដែលកើតឡើង? ថាតើមានថតខ្សែអាត់ ឬក៏មិនថតពេលក្រោយយ៉ាងដូចម្ដេច សូមឲ្យគាត់រៀបរាប់ឲ្យជាក់ស្ដែង អំពីបែបបទនៃការធ្វើសម្ភាសនោះវាយ៉ាងដូចម្ដេចបាទ។

**លោក ផាន វ៉ាន៖**

**ផ៖** សូមឲ្យលោកសួរម្តងទៀតបាទ អត់យល់ដែរ។

[១០:២១:០៤]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកបានប្រាប់យើងថា គេសម្ភាសលោក ហើយគេថតខ្សែអាត់។ បន្ទាប់មកលោកហាក់ដូចជានិយាយថា បើមានបញ្ហាអ្វីនោះ មានកំហុសនោះគេនឹងកែតម្រូវ។ ហើយខ្ញុំស្តាប់ការបកប្រែទៅជាភាសាអង់គ្លេសអ៊ីចឹង គឺថាសូមអភ័យទោស បើខ្ញុំស្តាប់ទៅខុស ឬក៏មិនត្រឹមត្រូវតាមលោកឆ្លើយ។ នៅពេលដែលលោកថាបើមានបញ្ហាអី តើបញ្ហាហ្នឹងជាអ្វី? ហើយកែតម្រូវនោះបែបណា? របៀបម៉េច?

**ផ៖** មិនមែនកំហុសទេបាទ គ្រាន់តែថា ខ្ញុំបញ្ជាក់អ៊ីចេះ ឧទាហរណ៍ដូច យើងនិយាយគ្នាអ៊ីចឹង ឧបមាថា វាមិនត្រូវពីការពិត ដល់អ៊ីចឹងវាឲ្យសាមើលនិយាយខុស ឬត្រូវ។ ចង់បញ្ជាក់ជូនលោកអ៊ីចឹង។ ស្អីដែលការពិត យើងនិយាយពីការពិត ស្អីដែលថាយើងនិយាយទៅវាខុស យើងកែៗវាចេញទៅ វាមិនមែនជាការពិត។ ចង់និយាយអ៊ីចេះ។ ហ្នឹងសូមឲ្យលោកតុលាការពិចារណា។ ខ្ញុំប្រើពាក្យវាមិនត្រូវ។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺ។ នេះហើយដែលខ្ញុំចង់ឲ្យលោក -- បានការបភ្លឺពីលោកនោះ ពីព្រោះថា យើងដូចជាឮពីលោកថា លោកបានផ្តល់ការនិយាយនៅពេលចំណុចខ្លះ គឺថាអ្នកស៊ើបអង្កេតថា ដូចជាមិនពិតអ៊ីចឹងទេ គេឈប់ខ្សែអាត់ ហើយស្តាប់ឡើងវិញ ហើយដើម្បីឆ្លើយឆ្លងគ្នាហើយលោកបានទទួលឱកាសដើម្បីកែតម្រូវចម្លើយដែលលោកបានឆ្លើយពីមុន។ តើការពិតនោះវាអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១០:២២:៤៦]

**ផ៖** ការពិតហ្នឹងវាអ៊ីចឹងបាទ។ អាណាមិនពិតយើងកែតម្រូវវា។ ចង់និយាយអ៊ីចឹង ព្រោះការស្រាវជ្រាវពីរឿងអតីតកាលវាៗចាំវាមិនច្បាស់ ដូចយើងថ្ងៃនេះមានភស្តុតាង ដូចសម័យឥឡូវឯណាអីក៏កត់ត្រាទុកៗ សម័យនោះមានស្អី អត់មានទេ។ អាហ្នឹងមួយ។ ហើយពីរទៀត ក្នុងសង្គមខ្មែរជំនាន់នុ៎ងវាៗមិនដូចឥឡូវឯណា លោកត្រូវយល់ដែរ ព្រោះគ្មានស្អីជាឯកសារ គ្មានស្អីជាភស្តុតាងទេ។ វាអ៊ីចឹងវាការពិតនៅតែការពិតនៅក្នុងខួរក្បាលខ្ញុំ នៅក្នុងចិត្តខ្ញុំ ឧបមាអ៊ីចឹង។ ខ្ញុំឃើញអី ខ្ញុំនៅត្រង់ណា ខ្ញុំដឹង ប៉ុន្តែថ្ងៃខែវាៗមិនច្បាស់ ហើយព្រឹត្តិការណ៍ក៏ដឹងនៅក្នុងចិត្តដែរ ព្រោះឃើញ ដូចឃើញថ្ងៃនេះអ៊ីចឹង។ ដូចយើងរំឭកអតីតកាលអ៊ីចឹង។ ប៉ុន្តែថ្ងៃខែហ្នឹងវាមិនច្បាស់ទេ។ ហ្នឹងសូមបញ្ជាក់ជូនលោកអ៊ីចឹង។

**ស៖** បាទ នៅពេលដែលគេរំឭកការចងចាំរបស់លោក ខ្ញុំយល់ថា អ្នកស៊ើបអង្កេតជាអ្នកជួយរំឭកការចងចាំរបស់លោក តើមែនទេ?

**ឆ៖** មិនមែនអ្នកស៊ើបអង្កេតជួយរំឭកទេ គេសួរ បាទ គេសួរ ដល់អ៊ីចឹងគេឲ្យយើងនឹករកមើលអ៊ីចឹងណ៎ះ! ឧទាហរណ៍ដូចពីម្សិលមិញអ៊ីចឹងលោកនៅឯណា? ឧបមាអ៊ីចឹង។ ម្សិញមិញនេះ ដូចនៅផ្ទះលោក ក ឬលោក ខ អ៊ីចឹងឧបមាអ៊ីចឹង។ អ្អេ! ដូចជា ដូចឮថា និយាយជាមួយខ្ញុំដូចឮនៅឯណោះផ្សេង, អេ! ខុសហើយ ឧបមាអ៊ីចឹងបាទ។ ខ្ញុំឧទាហរណ៍ឲ្យយល់អ៊ីចឹង។ ហេតុការណ៍នេះក៏ដូច្នេះដែរ បាទ គេជួយៗរំឭកអ៊ីចឹង ជួយសួរអ៊ីចឹងបាននឹកឃើញទៅ វានៅឯណា វាយ៉ាងម៉េច អីយ៉ាងម៉េច? អីអ៊ីចឹងបាទ។ សូមបញ្ជាក់ជូនលោកប៉ុណ្ណឹង។

[១០:២៤:៥០]

**ស៖** នៅក្នុងការសួរសំណួរទាំងអស់នោះទៅលោក តើគេបានស្នើគំនិតនៅក្នុងចម្លើយ នៅក្នុងសំណួរ ហើយសូមឲ្យលោកបញ្ជាក់ទៅតាមអ្វីដែលគេនិយាយពីនៅក្នុងសំណួររបស់គេដែរឬទេ?

**ឆ៖** សួរយ៉ាងម៉េចបាទ។ សូមលោកបញ្ជាក់ម្តងទៀត។

**ស៖** នៅពេលដែលគេកែតម្រូវលោក តើពួកគេស្នើនៅគំនិតថា តើណាមួយជាចម្លើយត្រូវ ឬខុសដែរឬទេ ដើម្បីឲ្យលោកកែតម្រូវការចងចាំរបស់លោក ដើម្បីឲ្យមានការកត់ត្រាត្រឹមត្រូវនៅក្នុងខ្សែអាត់នោះនោះ?

**ឆ៖** បាទ ត្រឹមត្រូវ គេបញ្ជាក់ ដើម្បីឲ្យខ្ញុំចងចាំ ហើយនិងគិតឲ្យត្រឹមត្រូវបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំមានចំណុចមួយដែលមានភាពមិនច្បាស់លាស់។ អម្បាញ់មិញលោកមេធាវី កាណាវាស បានលើកចំណុចមួយថា អ្នកស៊ើបអង្កេតមានការកែតម្រូវទៅលើអ្វីដែលនិយាយដោយសាក្សីនៅពេលដែលសួរសំណួរ។ កន្លែងនេះគួរតែមានការបញ្ជាក់ តើអ្នកស៊ើបអង្កេតមានការកែតម្រូវទៅលើអ្វីដែលសាក្សីបាននិយាយនាពេលនោះដែរឬទេ? សូមអរគុណ។

[១០:២៦:៣៧]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន។ មេធាវីគឺតែងតែមិនបញ្ជាក់ការសង្ស័យទេ ត្រូវតែជំទាស់។ ហើយគាត់មានឱកាសក្នុងការសួរសំណួរសាក្សី។ សាក្សីយល់សំណួររបស់ខ្ញុំច្បាស់ណាស់ ហើយបើគាត់មានការចម្ងល់ គាត់អាចសុំការអនុញ្ញាត ដើម្បីសួរសំណួរបន្ថែម។ ប៉ុន្តែខ្ញុំនឹងទៅមួយជំហានម្តង ដើម្បីឱ្យយើងមានកំណត់ត្រាតុលាការត្រឹមត្រូវថា តើការសម្ភាសនោះដោយវិធីណា? គាត់ឆ្លើយវិធីណា?

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះលោកសាក្សីលោកបានប្រាប់តុលាការថា មកដល់ពេលនេះគឺអ្នកស៊ើបអង្កេតបានជួយលោកឱ្យរំឭកការចងចាំ។ តើគេបានប្រាប់ បង្ហាញឯកសារអ្វីទៅលោក ដើម្បីឱ្យបញ្ជាក់ ផ្ទៀងផ្ទាត់ដើម្បីឱ្យលោកយល់អំពីទីកន្លែង កាលបរិច្ឆេទ ឬក៏ឈ្មោះមនុស្សនៅក្នុងពេលសម្ភាសនោះដែរឬទេ?

**លោក ផាន វ៉ាន៖**

**ឆ៖** អត់មានទេបាទ។

**លោក ម៉ៃខល កាណាវាស៖**

បាទ នៅក្នុងកាលដែលលោកឆ្លើយនេះ។ សូមអរគុណលោកសាក្សីដែលលោកបានមកផ្តល់សក្ខីកម្ម ហើយសូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ដែលខ្ញុំបាន ឱ្យខ្ញុំសួរ ហើយសូមឱ្យលោកសាក្សីមានសុខភាពល្អ ធ្វើដំណើរសុវត្ថិភាពទៅលំនៅដ្ឋានវិញ។ សូមអរគុណ។

[១០:២៨:០៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣០:៣២]

**ប្រធានអង្គជំនុំ៖**

លោក -- យ៉ាងម៉េចទៅលោកមេធាវី?

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

លោកប្រធានសូមអរគុណ។ ខ្ញុំ កាលពីម្សិលមិញ ខ្ញុំត្រូវបានចាកចេញពីសាលសវនាការដោយមិនទាន់មានឱកាសថ្លែងអំណរគុណដល់សាក្សី ហេតុដូច្នេះខ្ញុំសូមចំណាយពេលវេលានេះ ដើម្បីថ្លែងអំណរគុណដល់សាក្សីដែលសាក្សីបានផ្តល់នូវចម្លើយ ហើយសូមអភ័យទោសដែរ ដែលម្សិលមិញខ្ញុំមិនបាននិយាយជាមួយលោកសាក្សីឱ្យមានលក្ខណៈថាជាសន្ទនាដ៏ល្អនោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោក ផាន វ៉ាន ការស្តាប់សក្ខីកម្មរបស់លោក រហូតដល់ពេលនេះបានចប់ហើយ។ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានចំណាយពេលវេលាដ៏មានតម្លៃនេះ មកចូលរួមផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះប្រកបដោយភាពអត់ធ្មត់ និងខិតខំអស់ពីសមត្ថភាពលទ្ធភាពរបស់ខ្លួន។

[១០:៣២:៤១]

សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ សូមលោក ផាន វ៉ាន ជួបតែសំណាងល្អ មានសុខភាពល្អ និងទទួលបាននូវសេចក្តីសុខសប្បាយ ហើយនិងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។ ហើយលោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សីក៏ត្រឡប់ទៅវិញបានហើយដែរ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិញត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏ទីកន្លែងគោលដៅដែលគាត់ចង់ទៅបានហើយ។

ឥឡូវនេះដល់ពេលសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-665។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:៥០]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសនាការ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីដែលមានរហស្សនាម TCW-695 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១០:៥៥:១៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក សួន កានិល៖**

**ឆ៖** បាទ ខ្ញុំបាទសូមគោរពលោកប្រធាន ខ្ញុំបានឈ្មោះ សួន កានិល។

**ស៖** បាទ អរគុណលោក កានិល។ ក្រៅពីឈ្មោះ កានិល តើលោកប្រើឈ្មោះ មានដែលប្រើឈ្មោះអ្វីផ្សេងទៀតដែរឬទេ? ឬក៏ឈ្មោះហៅក្រៅ?

**ឆ៖** ឈ្មោះហៅក្រៅ គឺឈ្មោះ នាង។

**ស៖** បាទ អរគុណ។ លោក កានិល តើលោកមានអាយុប៉ុន្មានឆ្នាំ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! បាទចាំមើលក្បាលមីក្រូប្រតិបត្តិការភ្លើងក្រហម នៅខាងក្រោមនៅទីនេះសឹមឆ្លើយបាទ។

**លោក សួន កានិល៖**

**ឆ៖** ខ្ញុំមានអាយុ ៥៩ឆ្នាំ។

**ស៖** បាទ អរគុណ។ លោក កានិល តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណាដែរ?

**ឆ៖** ខ្ញុំរស់នៅភូមិឈ្មក ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ។

**ស៖** បាទ អរគុណ។ ចុះទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** ទីលំនៅបច្ចុប្បន្ន នៅភូមិដដែល។ ភូមិឃុំដដែល។

**ស៖** តើលោកប្រកបមុខរបររកស៊ីធ្វើអ្វី?

**ឆ៖** មុខរបរខ្ញុំ បច្ចុប្បន្នជាកសិករ។

**ស៖** ចុះឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកឈ្មោះ សួន ស៊ិន (ស្លាប់)។

**ស៖** ចុះម្ដាយបង្កើតលោកឈ្មោះអី?

**ឆ៖** ម្ដាយបង្កើតឈ្មោះ ចាន់ គឹមហួត (ស្លាប់)។

**ស៖** អរគុណ។ ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធរបស់ខ្ញុំឈ្មោះ ជីវ នី ឬ មាស នី។ មានកូនទាំងអស់ប្រាំមួយនាក់ ប្រុសពីរ ស្រីបួន។

**ស៖** បាទ អរគុណ។ លោក សួន កានិល តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ រាយការណ៍កាលពីព្រឹកមិញថា តាមសមត្ថភាពដែលលោកអាចដឹង លោកមិនជាប់ -- មិនមានជាប់ចំណងលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្ដីនេះទេ ហើយក៏មិនជាប់ញាតិលោកហិត ឬក៏ជាប់ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីនាក់ដែរ គឺលោក នួន ជា, លោក អៀង សារី, លោក ខៀវ សំផន។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ រឿងហ្នឹងពិតមែន មិនមានបញ្ហាអីពាក់ព័ន្ធទេ។

[១០:៥៨:២៦]

**ស៖** តាមរបាយការណ៍ដដែលថា លោកថា លោកបានធ្វើសម្បថរួចហើយមុននឹងចូលមកកាន់បន្ទប់សវនាការនេះ។ ពិតមែនដែរទេ?

**ឆ៖** ពិតមែនហើយ បានធ្វើរួច។

**ស៖** អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ចលោក ក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោក កានិល ក្នុងនាមលោកជាសាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

អំពីករណីយកិច្ច លោក កានិល ក្នុងនាមលោកជាសាក្សី ត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរ

ចំពោះលោក លើកលែងតែក្នុងករណីសំណួរដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ លោកជាសាក្សី លោកត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចនៅក្នុងនាមជាសាក្សីនេះដែរឬទេ?

**ផ៖** ខ្ញុំយល់មិនទាន់ច្បាស់ សូមលោកប្រធានជួយពន្យល់ថែម។

[១១:០០:០៧]

**ស៖** ក្នុងនាមលោកជាសាក្សី គឺសិទ្ធិរបស់លោក គឺលោក -- សំណួរឯណាដែលឆ្លើយនាំឲ្យលោកចម្លើយរបស់លោកឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង ទម្លាក់កំហុសលើខ្លួនឯងអំពីអំពើផ្សេងៗ នោះគឺលោកអាចរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរដែលសួរបែបនេះទេ។ ផ្ទុយទៅវិញករណីយកិច្ចរបស់លោក គឺលោកត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគីចូលរួមនៅក្នុងកិច្ចដំណើរនីតិវិធីនេះ ដែលមានសិទ្ធិសួរលោក គឺលោកត្រូវតែឆ្លើយតបទៅតាមស្ថានភាពសមស្របទៅនឹងខ្លឹមសារនៃសំណួរដែលសួរ លើកលែងតែសំណួរដែលសួរដាក់ពិរុទ្ធភាពលើខ្លួនឯង ឲ្យលោកឆ្លើយដាក់កំហុសលើខ្លួនឯង ទើបលោករក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏លោកឆ្លើយតប ស្រេចលើលោកទេ។

ហើយមួយទៀត គឺលោកមានករណីយកិច្ចត្រូវតែនិយាយតែការណ៍ណាដែលពិត។ ការពិតនេះគឺអាចដោយសារមានសំណួរខ្លះ ដោយសារលោកបានឃើញ លោកបានដឹង លោកបានឮ លោកបានចងចាំ ឬក៏ជាបទពិសោធន៍ដែលលោកបានជួបប្រទះ ឬក៏បានធ្វើការសង្កេតនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធទៅនឹងសំណួរដែលសួរ ជាពិសេសទាក់ទងទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះគឺចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលលោកបាន -- ផ្ទាល់ នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលសួរ។ នេះជាសិទ្ធិនិងករណីយកិច្ចរបស់លោក។ លោកយល់ទេ?

[១១:០១:៥៤]

**ផ៖** បាទ ខ្ញុំយល់ហើយ។

**ស៖** លោក កានិល តើលោកធ្លាប់បានសក្ខីកម្មជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ កន្លងមក?

**ឆ៖** ខ្ញុំធ្លាប់បានផ្តល់សក្ខីកម្មដល់អ្នកទៅស៊ើបអង្កេតនោះ។ ធ្លាប់បាន។

**ស៖** ប៉ុន្មានដង? ហើយធ្វើនៅពេលណា? នៅទីកន្លែងណា? លោកអាចចាំទេ?

**ឆ៖** ខ្ញុំចាំបាន ព្រោះគាត់ទៅធ្វើ ទៅសួរនៅផ្ទះខ្ញុំ នៅភូមិឈូក ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំកាលពីឆ្នាំ២០០៩ ខែសីហា, ថ្ងៃទី១៨ ថ្ងៃទី១៩ និងថ្ងៃទី២០ បីថ្ងៃជាប់។ មួយវគ្គ។ វគ្គលើកក្រោយទៅមួយវគ្គទៀត ប៉ុន្តែខ្ញុំភ្លេចហើយ ទៅពីរវគ្គ។ ហើយនិងមានហៅថា ដូចថាអ្នកទៅសួរក្រោយហ្នឹងពីរដងទៀត ទៅ។ អាហ្នឹងខ្ញុំភ្លេចថ្ងៃខែដែរ។

**ស៖** អ៊ីចឹងសរុបមកវិញគេសួរលោកប៉ុន្មានដង ធ្វើសម្ភាសជាមួយលោកប៉ុន្មានដង?
បង្អង់បន្តិច រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណា។

**ឆ៖** ទៅសួរហ្នឹងវាពីរដងទេ។

**ស៖** បាទ អរគុណ។ មុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យមើល ឬក៏បានអានទូវកំណត់ហេតុដែលស្តាប់សក្ខីកម្មរបស់លោក ដែលបានធ្វើជាមួយនឹងអ្នកស៊ើបអង្កេតកន្លងមកដែរឬទេ ដើម្បីរំឭកការចងចាំ?

**ឆ៖** គឺខ្ញុំបានមើល និងបាននេះរួចហើយ មើលម្តងទៀតរួចហើយ។

[១១:០៥:២១]

**ស៖** ហើយបើតាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំ ថាតើលោកអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនេះគឺពិតជាត្រឹមត្រូវ វាសមស្របស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានផ្តល់បទសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេត កាលពីពីរដងមុននោះដែរឬទេ?

**ឆ៖** គឺខ្ញុំអាចឆ្លើយបាន នូវបញ្ហាដែលគេទៅសួររួចហើយក្នុងឯកសារដែលមាន។

**ស៖** សំណួរសួរអ៊ីចេះថា ក្រោយពីលោកបានអានឡើងវិញ ដើម្បីរំឭកការចងចាំហ្នឹង សំណួរថាខ្លឹមសារនៃកំណត់ហេតុដែលលោកបានអាននេះ វាស្រប ឬក៏ស៊ីសង្វាក់គ្នាទៅនឹងបទសម្ភាសន៍ ដែលលោកបានផ្តល់ពីរដងកាលពីលើកមុននៅលំនៅដ្ឋានរបស់លោកនោះដែរឬអត់?

**ឆ៖** គឺវា -- ខ្ញុំបានអានរួចហើយ គឺខ្ញុំអាចហៅថា អាចស្រប យល់ស្រប។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបជូនតំណាងសហព្រះរាជអាជ្ញាថា នៅក្នុងកិច្ចដំណើរការពិភាក្សាដេញ

ដោយស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយអង្គជំនុំជម្រះសូមជម្រាបផងដែរថា សហព្រះរាជអាជ្ញារួមទាំងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេល១ថ្ងៃក្នុងការសួរសាក្សីរូបនេះ។

សូមអញ្ជើញ!

[១១:០៦:០៥]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ ជាបឋមសូមគោរពលោកប្រធាន សូមគោរពលោកលោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។

ជម្រាបសួរលោក សួន កានិល ខ្ញុំឈ្មោះ សុង ឆវ័ន្ត។ ខ្ញុំជាតំណាងសហព្រះរាជអាជ្ញាជាតិថ្ងៃនេះ ខ្ញុំមានសំណួរមួយចំនួនចង់សាកសួរទៅលោក។ ប៉ុន្តែមុននឹងចាប់ផ្តើមសួរសំណួរលោក ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីផ្តល់ឯកសារដែលជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនេះ ដែលមានលេខឯកសារ E3/344, E3/411 និង E3/74។ ដើម្បីផ្តល់ជូនសាក្សីរូបជាជំនួយនៅពេលដែលនាងខ្ញុំសាកសួរសំណួរ។ សូមលោកប្រធានអនុញ្ញាត។

[១១:០៦:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោក កានិល នៅខាងមុខលោកហ្នឹងគឺជាកំណត់ហេតុដែលលោកបានសួរ ហើយបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ មានចម្លើយរបស់លោកនៅក្នុងនោះ។ បន្ទាប់ពីនេះបន្តិចទៀត ខ្ញុំនឹងសួរសំណួរមួយចំនួនដែលលោកបានឆ្លើយ ហើយមាននៅក្នុងចម្លើយ ប៉ុន្តែដើម្បីបញ្ជាក់ ឬក៏បំភ្លឺបន្ថែមនៅចំណុចដែលមិនទាន់បានសាកសួរ។ ប៉ុន្តែជាដំបូងខ្ញុំចង់សួរលោកថា តើលោកបានចូលធ្វើបដិវត្តន៍នៅក្នុងថ្ងៃខែឆ្នាំណាដែរ ប្រសិនបើលោកនៅចាំបាន?

[១១:០៧:៥៨]

**លោក សួន កានិល៖**

**ឆ៖** បាទ ខ្ញុំចូលបដិវត្តន៍ពីថ្ងៃ១១ ខែ១១ ឆ្នាំ១៩៧១។

**ស៖** ពេលចូលធ្វើបដិវត្តន៍ដំបូងហ្នឹង តើលោកចូលធ្វើនៅកន្លែងណាដែរ ក្នុងខេត្ត ឬក៏ក្នុងទីតាំងណាមួយដែរ?

**ឆ៖** ខ្ញុំចូលបដិវត្តន៍ដំបូងនៅភូមិខ្លាឃ្មុំ ឃុំទ័ពសៀម ស្រុកជីក្រែង ខេត្តសៀមរាប។

**ស៖** ក្រោយពីចូលធ្វើបដិវត្តន៍តាមចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេត លោកត្រូវបានគេជ្រើសរើសឲ្យចូលរៀនទូរលេខ។ ចង់សួរបញ្ជាក់ថា តើចូលបដិវត្តន៍បានរយៈពេលប៉ុន្មាន បានគេជ្រើសរើសលោកឲ្យចូលរៀនទូរលេខ?

**ឆ៖** ខ្ញុំត្រូវបានគេជ្រើសរើសឲ្យចូលរៀនទូរលេខ តាមខ្ញុំចាំបាន គឺខ្ញុំចូលបដិវត្តន៍បាន៦ខែគត់។

[១១:០៩:១៦]

**ស៖** លោកថា ក្រោយចូលបដិវត្តន៍បាន៦ខែ លោកត្រូវបានគេជ្រើសរើសឲ្យចូលរៀនទូរលេខ តើលោកដឹងទេថា មូលហេតុអ្វីពេលនោះបានគេរើសលោកឲ្យចូលរៀនទូរលេខ?

**ឆ៖** មូលហេតុដែលគេជ្រើសឲ្យរៀនទូរលេខ គឺពេលនោះគេតម្រូវទៅតាមតំបន់ជា -- គឺថានៅក្នុងកាលណោះ ខ្ញុំនៅវាជាប់នឹងគេហៅថា តំបន់៣៥ ភូមិភាគឧត្តរចាស់។ ដូច្នេះគេត្រូវរើសយកតែខ្ញុំម្នាក់ទេបាទ។

**ស៖** អ៊ីចឹងពេលលោកចូលរៀនទូរលេខដំបូងហ្នឹង តាមជាក់ស្តែងលោកមានអាយុប៉ុន្មាន? លោកចាំបានទេពេលហ្នឹង?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! លោកៗបង្អង់បន្តិច!

ហើយលោកមន្ត្រីរដ្ឋបាលតុលាការអាចសម្រួល ដាកអានេះចេញ។ កាលណាយើងដាក់ចំអ៊ីចឹងគាត់មើលអាភ្លើងនេះមិនឃើញទេ។ ដាកឲ្យបន្តិចទៅ គាត់អាចនឹងមើលឃើញភ្លើងក្រហមនៅខាងលើផ្នែកខាងលើនេះ។

លោក កានិល លោកនិយាយឆ្ងាយបានណ៎ះ និយាយឆ្ងាយបន្តិចក៏ឮដែរ។

បាទ លោកមិនបាច់ខំទៅជិតទេ លោកអាចនិយាយចម្ងាយបែបនេះក៏ឮដែរ។ លោកចម្ងាយប៉ុណ្ណឹងឮហើយ។ បាទ សូមអញ្ជើញបន្ត!

[១១:១០:៥១]

**លោក សួន កានិល៖**

**ឆ៖** ដូច្នេះ ខ្ញុំសូមបញ្ជាក់សំណួរម្ដងទៀត។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចាស ខ្ញុំចង់ដឹងថា ពេលដែលលោកចូលធ្វើបដិវត្តន៍ដំបូង ហើយបាន៦ខែ ហើយក្រោយមកបានគេរើសទៅរៀនទូរលេខហ្នឹង ពេលហ្នឹងលោកអាយុប៉ុន្មាន?

**ឆ៖** អាយុប្រហែលជា១៨ឆ្នាំ។

**ស៖** ចាស សូមអរគុណ។ ពេលដែលចូលរៀនទូរលេខហ្នឹង តើអ្នកដែលរើសហ្នឹង គេមានប្រាប់លោកទេ ថាមានលក្ខខណ្ឌអីខ្លះបានតម្រូវឲ្យចូលរៀនទូរលេខបាន ឬក៏នៅសុខៗគេមករើសលោកយកទៅរៀនតែម្ដង?

**ឆ៖** ការដែលគេរើសខ្ញុំទៅហ្នឹង គេមានហៅថា លក្ខខណ្ឌដែរ គេតម្រូវៗឲ្យទៅរៀនថា ព្រោះទៅរៀននៅតាមតំបន់គេយកមនុស្សទៅមួយតំបន់មួយ ឬតំបន់ពីរនាក់ទៅ ទៅតាមដែលគេចាត់ចែងមកឲ្យខ្ញុំទៅរៀន។

[១១:១២:០២]

**ស៖** តាមការសង្កេតរបស់លោកហ្នឹង តើអ្នកចូលរៀនទូរលេខហ្នឹងមកពីកន្លែងណាខ្លះ? ហើយភាគច្រើនអាយុប្រហែលជាប៉ុន្មាន?

**ឆ៖** គឺអ្នកដែលចូលរៀនទូរលេខហ្នឹង វាអាយុហ្នឹងប្រហាក់ប្រហែលគ្នា ប្រហែលនឹងខ្ញុំដែរ។ ហើយហៅថា នៅក្នុងភូមិភាគហ្នឹង វាមាន អង្កាល់ហ្នឹងមានបីតំបន់។ ហើយទៅតាមតំបន់ ហើយនិងទៅតាមរបស់ ហៅថាគណៈបញ្ជាការខ្លះ។

**ស៖** ចាស សូមអរគុណ។ តាមចម្លើយរបស់លោកនៅក្នុងចម្លើយដែលធ្វើជាមួយនឹងអ្នកសង្កេត នៅត្រង់ឯកសារ E3/344 នៅត្រង់ ERN ជាភាសាខ្មែរហ្នឹងគឺ 00373492, ERN ជាភាសាអង់គ្លេសគឺ 00384424 និង ERN ជាភាសាបារាំងគឺ 00426142។ អ្នកស៊ើបអង្កេតបានសួរលោកពាក់ព័ន្ធទៅនឹងពេលដែលលោកចូលធ្វើបដិវត្តន៍ហើយ។ ខ្ញុំសូមដកស្រង់ "ពេលខ្ញុំចូលធ្វើបដិវត្តន៍ហើយ

គេបានដកឲ្យខ្ញុំធ្វើការឃោសនាជាមួយប្រជាជននៅភូមិមួយហៅថា ភូមិក្របីរាល"។ ខ្ញុំសូមបញ្ចប់ការដកស្រង់ ហើយខ្ញុំចង់សួរលោកមួយចំនួនទាក់ទងនឹងបញ្ហានេះ។ ចង់ដឹងថា ការឃោសនានៅភូមិក្របីរាលពេលហ្នឹង តើគេធ្វើផ្តោតលើបញ្ហាអ្វីដែលសំខាន់?

**ឆ៖** នៅពេលនោះ ដែលខ្ញុំធ្វើការនៅភូមិក្របីរាលហ្នឹង គេធ្វើការផ្តោតសំខាន់ហៅថា "រំដោះជាតិ"។

[១១:១៤:១៧]

**ស៖** សូមជួយលោកជួយពន្យល់មើល តើមានន័យថាយ៉ាងដូចម្តេចពាក្យថា "រំដោះជាតិ"ហ្នឹង?

**ឆ៖** ពាក្យថា "រំដោះជាតិ" ខ្ញុំចង់និយាយថា ពាក្យ "បដិវត្ត"។ ពាក្យ "បដិវត្ត" គឺថាចង់ថា ប្រែក្រឡាស់ពីសង្គមចាស់មកសង្គមថ្មី។

**ស៖** ចាស សូមអរគុណ។ ហើយវិធីដែលគេផ្សព្វផ្សាយរឿងធ្វើឃោសនាហ្នឹង តើគេធ្វើតាមមធ្យោបាយណាដែរពេលហ្នឹង?

**ឆ៖** វិធីឃោសនានៅពេលនោះ គេធ្វើតាមការប្រជុំ។

**ស៖** តើគេប្រជុំទូទាំងតំបន់ ទូទាំងស្រុក ឬក៏មានការកម្រិតការប្រជុំដែរ? ហើយប្រជុំហ្នឹងញឹកញាប់អត់ទេ?

**ឆ៖** ការប្រជុំហ្នឹងគឺគេធ្វើទៅតាម ហៅថាថ្នាក់ៗរបស់វា អត់មានធ្វើតាមនេះទេ។ ដូចខាងខ្ញុំហ្នឹង ខ្ញុំត្រូវទទួលការណែនាំពីខាង -- ដូចថាខ្ញុំនៅភូមិ គឺខាងឃុំគេចុះមក។ គេចុះមកណែនាំថាយើងត្រូវធ្វើតស៊ូរំដោះជាតិអីចឹង ហើយយើងធ្វើដើម្បីហៅថា យើងមាន -- ហៅថាៗសង្គមមួយថ្មីអីចឹងទៅបាទ។ ដើម្បីអីចឹងបាទ។

[១១:១៥:៥៦]

**ស៖** ចាស សូមអរគុណ។ ប្រសិនបើមានការប្រជុំ មានការចុះតាំងពីថ្នាក់ឃុំ មានន័យថាពីឃុំមកចុះមកផ្សព្វផ្សាយតាមភូមិ តាមអីហ្នឹង តើជាក់ស្តែងការឃោសនានៅភូមិក្របីរាលហ្នឹងទទួលបានជោគជ័យអត់ទេ?

**ឆ៖** ពេលប្រជុំនៅពេលនោះគឺថា គឺបានជោគជ័យ។

**ស៖** តើជោគជ័យដែលលោកសំដៅថា ជោគជ័យ ហ្នឹងវាយ៉ាងម៉េចដែរ សូមលោកជួយបញ្ជាក់បន្តិចមក?

**ឆ៖** បញ្ហាជោគជ័យគឺខ្ញុំអាចនិយាយបាន ពីព្រោះថាពីមុនគឺប្រជាជនយើងអត់ទាន់យល់ ដល់ក្រោយពីការប្រជុំហើយណែនាំទៅគាត់យល់ គឺថាគាត់ចូលរួមក្នុងបដិវត្តន៍។ ធ្វើបដិវត្តន៍ គាត់ចូលរួមៗបាទ។

**សៈ** ចាស សូមអរគុណ។ ឥឡូវខ្ញុំចង់ឆ្លងចូលទៅដល់ប្រធានបទតូចមួយទៀត ពាក់ព័ន្ធនឹងវគ្គបណ្ដុះបណ្ដាលដែលលោកបានទទួលរឿងរៀនទូរលេខ។ លោកថា នៅពេលដែលលោកចូលបដិវត្តន៍បាន៦ខែ គេបញ្ជូនលោកឲ្យទៅរៀនទូរលេខ ហើយពេលដែលលោករៀនទូរលេខហ្នឹង តើលោករៀនកន្លែងណា? នៅទីតាំងណាមួយដែរ?

[១១:១៧:៣៥]

**ឆ៖** ការដែលខ្ញុំមករៀនទូរលេខហ្នឹង ខ្ញុំគ្រាន់តែនិយាយវែងបន្តិច តែបន្តិចទេបាទ។ គឺថាវាមកតាំងពីសៀមរាបរហូតមកដល់នៅឯព្រៃ។ទ-៨ នៅជិតក្រចេះ ឬកំពង់ចាមនេះ ខ្ញុំភ្លេចហើយត្រង់ខេត្តរៀននៅកន្លែងហ្នឹង។

**សៈ** តើទ-៨ហ្នឹង នៅក្នុងទួលសំបូរមែនអត់ទេ?

**ឆ៖** កន្លែងហ្នឹងវាយូរហើយ ក្រែងតែខ្ញុំវាភ្លេច អារឿងឈ្មោះទួលសំបូរ ឬក៏អារក្សត្នោតអ៊ីចឹងអាហ្នឹងខ្ញុំភ្លេចហើយ ព្រោះពេលវេលាវាយូរដែរហើយ។

**សៈ** ចាស អរគុណ។ អ៊ីចឹងពេលដែលលោកចូលទៅរៀនទូរលេខនៅក្នុងព្រៃទ-៨ហ្នឹង លោកមានដែលបានធ្លាប់ឮថាមានមន្ទីរ៨៧០ នៅក្នុងព្រៃហ្នឹងទេ?

**ឆ៖** កាលដែលខ្ញុំចូលទៅរៀនហ្នឹង ខ្ញុំគ្រាន់តែឮ។ ហ្នឹងខ្ញុំឮ មន្ទីរ៨៧០។

**សៈ** លោកឮ តើលោកចាំទេថា លោកឮមកពីណា? ឬក៏មានអ្នកណាប្រាប់លោក? ហើយមានឈ្មោះអីដែរពេលហ្នឹង ដែលអ្នកដែលប្រាប់ហ្នឹង?

**ឆ៖** ខ្ញុំឮៗតាមរយៈដែលគ្រូបណ្ដុះបណ្ដាល។ បាទ គ្រូបណ្ដុះបណ្ដាលទូរលេខ។

[១១:១៩:១៤]

**សៈ** គ្រូបណ្ដុះបណ្ដាលលោកហ្នឹងមានឈ្មោះអ្វីដែរ លោកមាននៅចាំបានទេ?

**ឆ៖** គឺគ្រូបណ្ដុះបណ្ដាល គឺខ្ញុំៗចាំបានឈ្មោះបាទ។ គឺមួយ ប៉ុន្តែទូរលេខហ្នឹងដែលខ្ញុំចូលទៅរៀនហ្នឹង គេចែកចេញជាពីរផ្នែក។ វាផ្នែកមួយ គឺផ្នែកវាយម៉ស ផ្នែកមួយគឺផ្នែកជួសជុល។ ដូច្នេះក្នុងការរៀនវៃម៉ស វាត្រូវប្រើពេលឲ្យរៀន៣ខែកន្លះ ឯអ្នកជួសជុលរៀន ៦ខែ។ ឯគ្រូៗវៃម៉ស គឺឈ្មោះៗ

នឿន។ បាទ ឯគ្រូៗជួលជុល អ្នកគ្រប់គ្រងកន្លែងហ្នឹងវាឈ្មោះ យឿនៗ។ ហើយគ្រូមួយទៀតដែលគ្រូ -- តាមពិតកាលនោះ គឺខ្ញុំរៀនដល់វគ្គទី៣ទៅហើយ ដូច្នេះរៀនវគ្គទី១ ទី២ គេរើសកូនសិស្សម្នាក់ដែលខ្លាំង ដែលពូកែហ្នឹងគេឲ្យមកជួយវៃ ហៅថាល្បឿនលឿន ល្បឿនណាលឿន គេឲ្យកូនសិស្សហ្នឹងបង្ហាត់ហ្នឹងបាទ។

**ស៖** ចាស ទាក់ទងទៅនឹងអ្នកដែលប្រាប់លោកគឺគ្រូរបស់លោកដែលឈ្មោះ នឿន ឬក៏ឈ្មោះ យឿន នៅពេលដែលគាត់ប្រាប់ថាមានមន្ទីរ៨៧០ មួយនៅក្នុងព្រៃហ្នឹង សូមលោកជួយបញ្ជាក់ គ្រូមួយហ្នឹង តើគ្រូឈ្មោះអីដែលប្រាប់?

[១១:២០:៥៥]

**ឆ៖** គ្រូដែលប្រាប់នោះ គឺឈ្មោះ យឿន គាត់អ្នកដែលទទួលរួម។

**ស៖** ចាស អរគុណ។ តើលោកចាំបានទេ នៅឆ្នាំណាដែលលោកដឹងថាមានមន្ទីរ៨៧០ នៅក្នុងព្រៃមួយហ្នឹង?

**ឆ៖** រឿងនៅខែឆ្នាំ គឺខ្ញុំចាំអត់បាន ភ្លេច។

**ស៖** ប្រសិនបើលោកមិនចាំបានឆ្នាំខែទេ ខ្ញុំចង់សួរបញ្ជាក់ថា លោកដឹងថាមានមន្ទីរ៨៧០ នៅក្នុងព្រៃហ្នឹងនៅពេលដែលលោកទៅរៀនទូរលេខ ហើយគ្រូលោកប្រាប់នៅក្នុងឆ្នាំហ្នឹងតែម្តង ឬក៏ពេលណាដែរ?

**ឆ៖** ទាល់តែខ្ញុំទៅរៀនទូរលេខហ្នឹងបានៗខ្ញុំ បានគេប្រាប់ បានខ្ញុំដឹង ពីមុនមកខ្ញុំអត់ដឹងដែរ។

**ស៖** ចាស អរគុណ។ ពាក់ព័ន្ធទៅនឹងទូរលេខ នៅពេលដែលលោកទៅរៀនទូរលេខហ្នឹង តើគេមានប្រាប់លោកទេ ថាគេប្រើប្រាស់ទូរលេខដើម្បីធ្វើអ្វី?

[១១:២២:១១]

**ឆ៖** ពេលដែលខ្ញុំទៅរៀនទូរលេខហ្នឹង គឺគេមានប្រើពាក្យថា និយមន័យរបស់ទូរលេខហ្នឹងច្បាស់លាស់ណាស់ គឺថាទូរលេខ គឺប្រើសម្រាប់ខាងផ្នែកយោធា គឺបម្រើនៅខាងជើងគោក ជើងអាកាស និងជើងទឹក។ បីបញ្ហាហ្នឹង ជាសរសៃឈាមនៃការធ្វើសង្គ្រាមរំដោះជាតិ។

**ស៖** ចាស អរគុណ។ ទាក់ទងទៅនឹងអត្ថន័យលម្អិតនៃទូរលេខហ្នឹង ខ្ញុំនឹងទុកមួយអន្លើសិន ហើយនឹងចូលស៊ីជម្រៅនៅពេលបន្តិចទៀតនេះ។ ចង់និយាយអំពីទំនាក់ទំនងដែលគេប្រើទូរលេខហ្នឹង តើចាប់ពីថ្នាក់ណាទៅដល់ថ្នាក់ណា ដែលគេប្រើទូរលេខដើម្បីទំនាក់ទំនងគ្នា លោកចាំបានទេ?

**ឆ៖** គឺខ្ញុំចាំបានបញ្ហាហ្នឹង។ បញ្ហាទូរលេខហ្នឹងគឺពេលនោះគេប្រើទំនាក់ទំនងតែផ្នែកខាងៗខ្ញុំហ្នឹង គឺខាងភូមិភាគ ខាងតំបន់ និងទៅខាងបញ្ជាការសមរភូមិ។ ហ្នឹងនៅពេលនោះ។

**ស៖** ចុះក្រោយមកទៀតតើគេមានប្រើទូរលេខពីភូមិភាគទៅថ្នាក់លើរបស់ភូមិភាគទៀតទេ?

**ឆ៖** គឺក្រោយមកទៀត គេបានដែលថា គេបានថាឲ្យទាក់ទងទៅខាងលើដែរ ទៅមន្ទីរ៨៧០ ទៅខាងលើអីចឹង។

[១១:២៤:០០]

**ស៖** ចាស អរគុណ។ ទាក់ទងទៅនឹងការប្រើប្រាស់លេខកូដ ការប្រើប្រាស់អក្សរសម្ងាត់ គឺលោកចាំបានទេ ថាចាប់ផ្ដើមមានលេខកូដ មានអក្សរសម្ងាត់ហ្នឹងតាំងពីឆ្នាំណាមកដែរ?

**ឆ៖** ប្រើលេខកូដ និងអក្សរសម្ងាត់ពេលដែលខ្ញុំ -- គឺថាម៉ាស៊ីនគេបញ្ជូនមកពេលណា គឺគេប្រើពេលនោះដែរ ឲ្យតែម៉ាស៊ីនធ្លាក់មកដល់។ កាលណោះវាអត់ទាន់មានម៉ាស៊ីនទេ ខាងភូមិភាគឧត្ដរ ចាស់គេឲ្យទៅខាងរតនគិរី ឬក៏ទៅខាងឆ្ងាយៗមុន។

**ស៖** ចុះពេលដែលម៉ាស៊ីនបញ្ជូនដល់កន្លែងរបស់លោកហ្នឹង នៅក្នុងឆ្នាំណាដែរ?

**ឆ៖** ម៉ាស៊ីនដែលគេបញ្ជូនមកដល់នៅកន្លែងខ្ញុំនោះគឺនៅឆ្នាំ -- កាលទុំងវ៉ែនៅភ្នំពេញ ខ្ញុំនៅ -- ឆ្នាំប្រហែលជាចិត អានេះវាមិនច្បាស់ទេ ប្រហែលក្នុងអំឡុង៧៣ ហ្នឹង អីក៏ចុង៧២ ហ្នឹង។

**ស៖** ចាស អរគុណ។ ចុះពេលម៉ាស៊ីនយកមកដល់ហ្នឹង តើគេដាក់ម៉ាស៊ីនហ្នឹងនៅកន្លែងណា? ហើយថ្នាក់ដឹកនាំរបស់លោកហ្នឹងគឺពួកគាត់មានការិយាល័យពួកគាត់នៅកន្លែងហ្នឹងជាមួយគ្នា ឬកន្លែងផ្សេងគ្នា?

**ឆ៖** ពេលម៉ាស៊ីនទូរលេខមកដល់ គឺថាគឺទូរលេខហ្នឹងវាជាសរសៃឈាមរបស់បញ្ជាការ ដូច្នេះពេលនោះយន្តហោះច្រើនផង គេអត់ឲ្យនៅជាមួយមេបញ្ជាការទេ។ គេឲ្យខ្ញុំនៅឆ្ងាយពីមេបញ្ជាការពីរគីឡូឯណោះ រកតែព្រៃណាដែលយើងអាចដំឡើងអង់តែនបាន។ ព្រោះថា ទូរលេខដែលខ្ញុំធ្វើនោះវាមានគ្នាដល់ទៅបួននាក់ ក្នុងមួយគ្រឿងហ្នឹង។

[១១:២៦:១៦]

**ស៖** ចាស អរគុណ។ បន្ទាប់ពីរៀនទូរលេខ បន្ទាប់ពីបានទទួលម៉ាស៊ីន ក្រោយមកទៀតហ្នឹង តាមចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង លោកបានថា ដោយសារមានការខ្វះមនុស្សធ្វើការ អីចឹងគេបានបញ្ជូនលោកទៅធ្វើការនៅរោងពុម្ពរបស់ភូមិ

ភាគ។ ខ្ញុំចង់ដឹងថា នៅពេលដែលលោកចាប់ផ្តើមចូលរួមពុម្ពធ្វើការហ្នឹងនៅក្នុងខែ ឬឆ្នាំណាដែរ លោកចាំបានទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយ ក្បាលមីក្រូមិនទាន់ប្រតិបត្តិការទេបាទ។

**លោក សួន កានិល៖**

**ឆ៖** គឺថា ខែថ្ងៃ ខ្ញុំចាំមិនបានទេ បើឆ្នាំ ខ្ញុំថាប្រហែល ព្រោះយូរដែរវាភ្លេច ប្រហែលជាចុងឆ្នាំ៧២ ឬ៧៣។ ព្រោះដល់ខ្ញុំចូលមកបាន -- គេអត់ គេមិនទាន់ឲ្យម៉ាស៊ីនមក វានៅចេញពីសាលារៀនហ្នឹង ព្រោះថាក្នុងព្រៃនោះវានៅ អាកន្លែងភូមិភាគហ្នឹង គេឲ្យខ្ញុំ តាមពិតគេមិនសូវឲ្យខ្ញុំធ្វើការនៅក្នុងការិយាល័យទេ គេច្រើនតែឲ្យជម្រះចម្ការទេ។ ប៉ុន្តែដល់ពេលគេអ្នកអូសស្តង់ស៊ីលចេះតែខូច ខ្ញុំថាមើលខ្ញុំសូមអូសម្តង។ ដល់គេឃើញខ្ញុំយកមកអូសត្រូវ គេយកមកខ្ញុំឲ្យនៅក្នុងរោងពុម្ពបាទ។

**ស្នងដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** អ៊ីចឹងតើរោងពុម្ពហ្នឹងមានទីតាំងនៅកន្លែងណាឲ្យពិតប្រាកដ ហើយរោងពុម្ពនុ៎ងធំ ឬមានទំហំប៉ុន្មានដែរ?

**ឆ៖** កាលណោះរោងពុម្ពនៅកន្លែងគីឡូ១៣ បាទ។ គេហៅថា គីឡូ១៣ នៅខាងខេត្តកំពង់ចាម គីឡូ១៣ ខ្ញុំចាំ។ ហើយរោងពុម្ពនោះមិនមែនជាមានទំហំអីធំទេ គឺថាមានតែអ្នកសរសេរ គេហៅថា ពីដើមគេសរសេរស្តង់ស៊ីលណ៎ះ ហើយនិងអ្នកអូសរ៉ូដេអូ ហើយនិងហៅថា កម្លាំងពីរបីនាក់ប៉ុណ្ណឹងទេ។ ហើយធ្វើជារោងមួយតូចទេ អត់មានជាធំអីទេ។

**ស៖** ចុះអ្នកណាជាអ្នកទទួលខុសត្រូវនៅក្នុងរោងពុម្ពហ្នឹង?

**ឆ៖** អ្នកដែលសរសេរស្តង់ស៊ីល គឺថាឈ្មោះ ធី ហើយម្នាក់ អ្នកទទួលខុសរួមនៅក្នុងកន្លែងដែលរោងពុម្ព ខ្ញុំភ្លេចឈ្មោះទៅវាយូរពេក។ ខ្ញុំស្គាល់តែអ្នកសរសេរស្តង់ស៊ីល ខ្ញុំនៅចាំបានបាទ ចាំបានមួយ ភ្លេចមួយ។

[១១:២៨:៥៩]

**ស៖** ចុះនៅក្នុងរោងពុម្ពហ្នឹងមានដែលមានឮឈ្មោះ សឿន ដែលមានឮឈ្មោះអត់ទេ នៅក្នុងរោងពុម្ពនុ៎ង?

**ឆ៖** អ្ហ៎! ដូចអត់ដែលឮឈ្មោះ។

**ស៖** ចាស អរគុណ។ ចុះនៅក្នុងរោងពុម្ពហ្នឹង គេបោះពុម្ពឯកសារអីខ្លះដែរ លោកចាំទេ?

**ឆ៖** នៅក្នុងរោងពុម្ពហ្នឹងគេបោះឯកសារដូចថា "រស្មីបដិវត្តន៍" ដាក់អ៊ីចឹង គេសរសេរ។

**ស៖** លោកជួយពន្យល់បានទេថា "រស្មីបដិវត្តន៍" ហ្នឹងជាឯកសាប្រភេទម៉េច ហើយវាជាលិខិតជាសៀវភៅ ជាទស្សនាវដ្ដី ឬក៏ជាអីដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ នៅ--បាទ បង្អង់បន្តិចណ៎ះ!

**លោក សួន កានិល៖**

**ឆ៖** រស្មីបដិវត្តន៍ បើសិនជាប្រៀបធៀបមកសព្វថ្ងៃនេះ ប្រហែលជាដូចជាហៅថាជាទស្សនាវដ្ដី។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចុះនៅក្នុងរោងពុម្ពហ្នឹង គេមានបោះពុម្ពពាក្យស្លោក ឬក៏លិខិតអនុញ្ញាតអីផ្សេងៗ ឬក៏អត់ទេ?

[១១:៣០:៣៤]

**ឆ៖** នៅក្នុងរោងពុម្ពហ្នឹង គេមាន ដូចថា ពេលណាដែលមានត្រូវការធ្វើអី គឺច្រើនអ្នករោងពុម្ពហ្នឹងជាអ្នកសរសេរជាពាក្យស្លោក ហើយនិង បើមានលិខិតផ្សេងៗ អាចធ្វើបាន។

**ស៖** ដើម្បីរំឭក ហើយនិងសួរបញ្ជាក់លោក។ នៅក្នុងចម្លើយដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនូវឯកសារពីដើមហ្នឹង នៅត្រង់ ERN ជាភាសាខ្មែរគឺ 00373509, ជាភាសាអង់គ្លេស 00390076 និងជាភាសាបារាំង 00424036។ នៅពេលដែលអ្នកស៊ើបអង្កេតសួរលោកថា "តើនៅរៀងពុម្ពហ្នឹង គេបោះពុម្ពឯកសារអីខ្លះ?" ពេលនោះលោកឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា "នៅក្នុងរោងពុម្ពគេមានបោះពុម្ពបដា និងពាក្យស្លោក និងលិខិតអនុញ្ញាត និងរៀបចំឯកសារសម្រាប់ភូមិភាគ"។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** គឺយោងទៅតាមឯកសារនេះ គឺខ្ញុំឆ្លើយលើកមុន ក៏ខ្ញុំមិន ខ្ញុំមិនថាមិនជំទាស់អីទេ គឺថាខ្ញុំយល់ស្របតាមឯកសារលើកមុន ពាក្យដែលខ្ញុំនិយាយ។ ដល់វា តាមពិតវា៣ឆ្នាំហើយ វាអាចភ្លេចខ្លះពាក្យហ្នឹង។

[១១:៣២:១៦]

**ស៖** ចាស អរគុណ។ ហើយនៅក្នុងរោងពុម្ពហ្នឹងដែរ តើអ្នកណាជាអ្នកសម្រេច ឬក៏ចេញបញ្ជាថា ឯកសារនេះត្រូវបោះពុម្ព ឯកសារប្រភេទនេះអត់ឲ្យបោះពុម្ព ឬក៏ត្រូវតែបោះពុម្ពឯកសារនេះ អ្នកណាជាអ្នកសម្រេច? គាត់ឈ្មោះអី ហើយមានតួនាទីអី?

**ឆ៖** គឺការសម្រេចនៃការបោះពុម្ព ឬក៏បោះជា ហៅថា "រស្មីបដិវត្តន៍" ហ្នឹងគឺថាមានការសម្រេចរបស់ លេខារបស់លេខាភូមិភាគ។

**ស៖** អរគុណ។ តើបន្ទាប់ពីបោះពុម្ពឯកសារហ្នឹង ឯកសារទាំងអស់ហ្នឹង គេចែកចាយទៅរបៀបម៉េចដែរ គឺគេបញ្ជូនទៅណា ឬក៏គេយកទៅណាដែរពេលហ្នឹង?

**ឆ៖** នៅពេលនោះ គឺឯកសារគេចែកចាយទៅតាម ហៅថា តាមតំបន់ តាមស្រុក ទៅតាមកម្មាភិបាលដែលធ្វើការហ្នឹង។

[១១:៣៣:៣៣]

**ស៖** នៅពេលដែលចែកចាយឯកសារហ្នឹង តើលេខាភូមិភាគដដែលហ្នឹង គាត់ជាអ្នកសម្រេចរឿងចែកចាយឯកសារហ្នឹង ឬក៏មានអ្នកណាផ្សេង មានលិខិត ឬក៏មានបញ្ជាអីផ្សេងមកពីខាងណាដែរ?

**ឆ៖** គឺនៅកន្លែងហ្នឹង គឺថាលេខាភូមិភាគគាត់អ្នកសម្រេច ថាឥឡូវឲ្យទៅតំបន់ ដូចថា៣៥ប៉ុន្មានក្បាល, ឲ្យទៅតំបន់៤២ប៉ុន្មានក្បាល, តំបន់៤១ប៉ុន្មានក្បាល គឺមានការសម្រេចទៅតាមមនុស្សច្រើន ឬតិច។

**ស៖** តើលេខាភូមិភាគដែលលោកនិយាយសំដៅដល់ហ្នឹង គាត់មានឈ្មោះអ្វីដែរ?

**ឆ៖** គាត់មានឈ្មោះ គេហៅក្រៅ ខ្ញុំឮគេហៅថាឈ្មោះ បងធុចៗ។ ខ្ញុំថាអ៊ីចឹងដែរ។

**ស៖** ចាស សូមអរគុណ។ ចង់សួរបញ្ជាក់បន្តិច នៅក្នុងរោងពុម្ពហ្នឹង នៅពេលធ្វើការនៅក្នុងរោងពុម្ព លោកមានដែរឃើញទង់បដិវត្តទេ?

[១១:៣៥:០០]

**ឆ៖** ខ្ញុំធ្វើការនៅក្នុងរោងពុម្ព ខ្ញុំឃើញទង់បដិវត្ត។ បញ្ជាក់ថែម ទង់បដិវត្តហ្នឹងគឺថា រោងពុម្ពហ្នឹងអត់បានបោះទេ គឺថាមកពីខាងៗលើគេយកមកឲ្យ។ គេមិនឲ្យច្រើនទេ គេឲ្យ១០ក្បាលអ៊ីចឹង។ ហើយទង់គឺផ្សេង គេជាអ្នកបោះ។

**ស៖** លោកថា លោកធ្លាប់បានឃើញទង់បដិវត្តហ្នឹង ហើយពីលើគេបញ្ជូនយកមកឲ្យ។ ចង់ឲ្យលោកបញ្ជាក់បន្តិចថា ពីលើហ្នឹងអ្នកណាអ្នកបញ្ជូនមក? ហើយខ្លឹមសារនៅក្នុងទង់បដិវត្តហ្នឹង លោក

មានដែលបានអានទេ?

**ឆ៖** ខ្ញុំបានឃើញដោយសារខ្ញុំនៅក្នុងរោងពុម្ព ប៉ុន្តែខ្ចីមសារនៅទង់បដិវត្ត គេអត់ឲ្យខ្ញុំអានទេ ព្រោះយើងអត់មានចូលបក្ស។

[១១:៣៦:០៣]

**ស៖** ចុះអ្នកណាៗពីខាងលើ ដែលលោកសំដៅថាពីខាងលើបញ្ជូនទង់បដិវត្តហ្នឹងមកហ្នឹង តើពីខាងលើហ្នឹង អ្នកខាងលើហ្នឹងអ្នកណា? លោកបញ្ជាក់បន្តិចមើល៍?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

ឈប់អាល កុំអាលទាន់ឆ្លើយ។

**លោក សួន កានិល៖**

**ឆ៖** ឯខាងលើហ្នឹង ខ្ញុំដឹងថាកន្លែងមជ្ឈិម ប៉ុន្តែខ្ញុំអត់ស្គាល់ថាមជ្ឈិមហ្នឹងចូលមកក្នុងណាទេ គ្រាន់តែពេលនោះនៅៗក្នុងព្រៃនោះ គេលាក់ការណ៍ដែរបាទ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចាស សូមអរគុណ។ លោកសាក្សី ខ្ញុំចង់សួរបញ្ជាក់លោកបន្តិចពីការងារ ហើយបន្ទាប់មកលោកមានផ្លាស់ទីពីខេត្តមួយទៅខេត្តមួយហ្នឹង ខ្ញុំចង់ដឹងពីកាលបរិច្ឆេទមួយចំនួន។ អ៊ីចឹងចង់សួរលោកបញ្ជាក់ថា តើលោកនៅកំពង់ធំជាមួយនឹង កែ ពក ហ្នឹងនៅក្នុងឆ្នាំ១៩៧៣ មែនទេ?

**ឆ៖** បាទ ខ្ញុំនៅក្នុងឆ្នាំ១៩៧៣។

[១១:៣៧:១៤]

**ស៖** នៅពេលដែលលោកនៅជាមួយនឹង កែ ពក នៅកំពង់ធំ ឆ្នាំ៧៣ហ្នឹង តើលោកចាំបានទេថាមានព្រឹត្តិការណ៍ ហេតុការណ៍អ្វីដែលសំខាន់កើតមានឡើងពេលនោះអត់ទេ? ឧទាហរណ៍មានប្រយុទ្ធសមរភូមិក្តៅ ឬក៏ការវាយប្រយុទ្ធខ្លាំងក្លា? លោកចាំបានទេពេលហ្នឹង?

**ឆ៖** នៅពេលនោះ គឺខ្ញុំចាំបាន។ គឺខ្ញុំវាត្រូវចុះជាប់នឹងសមរភូមិហ្នឹងហើយ គឺវ៉ៃនៅកំពង់ធំ។ គឺវ៉ៃតាំងពីរលួស ដល់ជុំវិញហ្នឹង។ គឺហ្នឹងសុទ្ធតែសមរភូមិក្តៅហើយ នៅពេលនោះ។

**ស៖** ចង់ឲ្យលោករៀបរាប់ឲ្យលម្អិតបន្តិចថា ចាប់ផ្តើមវ៉ៃហ្នឹងវ៉ៃចេញពីណាទៅណា? ហើយទីតាំងដែលសមរភូមិក្តៅហ្នឹងគឺនៅកន្លែងណាឲ្យពិតប្រាកដនោះ ចាំទេ?

**ឆ៖** ពីឆ្នាំ៧៣ហ្នឹង គឺថាសភាពការណ៍នៅពេលនោះ គឺវៃគ្នាហ្នឹងគឺថាវារួញ គឺថារួញក្តោបនៅក្រុងកំពង់ធំ។ ដូច្នេះនៅតាមថ្នល់ជាតិ ផ្លូវជាតិលេខ៦ហ្នឹង តាំងពី -- ចាប់ពី -- តាំងពីកកោះ សន្ទុក កំពង់ថ្មអីហ្នឹង គឺថាៗជាតំបន់រំដោះទៅហើយ។ ដូច្នេះវាត្រូវប្រយុទ្ធគ្នានៅក្នុងឆ្នាំ៧៣ ហ្នឹង នៅកន្លែងហ្នឹង វៃនៅ -- ខ្ញុំគេឲ្យនៅតាំងពី ហៅថា ភូមិរលួស អាហ្នឹងនៅខាងត្បូងកំពង់ធំ បានមកវៃនៅ គេហៅថា នៅខាងកើតនៅស្ពានត្រពាំងវែង បាននៅខាងត្បូងចាប់តាំងពីបញ្ជាជី ហើយមកពីលិច ចាប់តាំងពីរហូតពីស្ពានព្រៃប្រស់អីមកអ៊ីចឹង។ នេះសុទ្ធតែ ហៅថានៅជុំវិញក្រុងកំពង់ធំហ្នឹងបាទ។

[១១:៣៩:១៤]

**ស៖** ចាស អរគុណ។ ហើយជាក់ស្តែងនៅពេលឆ្នាំ៧៣ហ្នឹងមានមនុស្សប៉ុន្មាននាក់ដែលធ្វើការនៅជិត កែ ពក ហ្នឹង? លោកចាំបានទេ ហើយជួយរាប់ឈ្មោះផង?

**ឆ៖** នៅឆ្នាំ៧៣ហ្នឹង នៅជុំវិញ កែ ពក មានតែដូចថា អ្នកទូរលេខទើបមកឆ្នាំ៧៣ដែរ ហើយនិងកងការពារ ហើយនិងហៅថាៗ អ្នកដែលថា វរសេនាតូច វរសេនាធំ ដែលជាកងទ័ពនៅជុំវិញគាត់ ព្រោះ កែ ពក គាត់ក្តាប់ជាសេនាធិការរបស់ភូមិភាគទេ ពេលនោះ។

**ស៖** ចង់ឲ្យលោកបញ្ជាក់ឈ្មោះបន្តិច ថាទូរលេខហ្នឹង គឺលោកឬក៏មានអ្នកផ្សេង? ហើយកងការពារហ្នឹងគាត់ឈ្មោះអី? វរសេនាតូចធំហ្នឹងគាត់ឈ្មោះអី? សូមលោកជួយបញ្ជាក់បន្តិចមក។

**ឆ៖** ដូច្នេះខ្ញុំសូមបញ្ជាក់ គ្រាន់ពេលវេលាវាយូរទៅហើយ ចាំខ្លះ ក៏មិនចាំខ្លះ ខ្ញុំចាំតែអ្នកទូរលេខនិងអ្នកដែលខ្ញុំស្គាល់ គឺនិយាយអ៊ីចឹងចុះ។ គឺថាអ្នកទូរលេខជាមួយខ្ញុំវាមានគ្នាហៅថា ប្អូនៗនាក់ទាំងខ្ញុំអាហ្នឹងជាអ្នកវាយម៉ាសទេ មានអ្នកជួសជុលម្នាក់ទៀតវា ប្រាំនាក់។ អាហ្នឹងខាងផ្នែកទូរលេខ គេនៅជាមួយគ្នា។ ហើយនៅជាមួយ កែ ពក កាលនោះ មានឈ្មោះគេហៅថាឈ្មោះហៅថា ឈ្មោះជិត មួយ។ ជិត នោះគាត់ជាហៅថាជំនួយការ ឬក៏ថាម៉េចទេ ខ្ញុំភ្លេចទៅ គេអ្នកដែលជួយនៅក្នុងសមរភូមិហ្នឹង។ សមរភូមិកំពង់ធំហ្នឹង។ ហើយនិងលេខវរសេនាតូច កាលនោះមានត្រឹមវរសេនាតូច។ គឺខ្ញុំស្គាល់តាំងពី៣០៥, នៅវរសេនាតូច៣០៥ ឈ្មោះ បេង ប្រធាន គេហៅថាប្រធានវរសេនាតូចហ្នឹង បេង, ដូច៣០៨ ឈ្មោះ ម៉ន, ធាន -- ហ៊ឺ! ដល់យូរទៅថាភ្លេចទៅចុះ កុំពិបាក។

[១១:៤២:០០]

**ស៖** ចាស អរគុណ។ ចង់សួរបញ្ជាក់ថា អ៊ីចឹងនៅឆ្នាំ១៩៧៣ នៅពេលដែលមានសមរភូមិក្តៅហ្នឹង គឺទូរលេខពេលហ្នឹង ចាប់ផ្តើមមានដំណើរការហើយ មែនឬអត់ទេ?

**ឆ៖** ទូរលេខដែលយកមកដំណើរការនៅក្នុងភូមិភាគឧត្តរចាស់ហ្នឹង វាដំណើរការ កាលនោះ ខ្ញុំនៅសំបូរ (ឮមិនច្បាស់)-- កាលនោះ មកវ៉ៃព្រែកក្ដាមប្រហែលឆ្នាំ ដើមឆ្នាំ៧៣ ចុងឆ្នាំ៧៣ បានគេផ្លាស់ឲ្យទៅវាយនៅសមរភូមិសៀមរាបវិញ។ ដូច្នេះ ទូរលេខដំណើរការនៅពេលនោះ។ ម៉ាស៊ីនដែលខាងលើយកមកឲ្យ ឲ្យនៅពេលហ្នឹងហើយ ពេលដែលសមរភូមិចាប់ក្ដៅ បានគេឲ្យទូរលេខមកដើម្បីកុំឲ្យពិបាករត់ចុះឡើង រត់ មនុស្សហ្នឹងបាទ សារ។

**ស៖** ចាសអរគុណ។ ពាក់ព័ន្ធនឹងរបបរាយការណ៍ចង់ឲ្យលោកបញ្ជាក់ថា តើនរណាជាថ្នាក់លើរបស់ កែ ពក ដែល ប្រសិនបើមាននៅក្នុងបញ្ហាកើតឡើងក្នុងតំបន់ក្នុងអី តើគាត់ត្រូវរាយការណ៍ឲ្យអ្នកណា ថ្នាក់លើរបស់គាត់ហ្នឹង?

**ឆ៖** ពេលដែលរាយការណ៍គឺ កែ ពក ព្រោះគាត់កាន់ជាសេនាធិការរបស់ភូមិភាគ គាត់រាយ-ការណ៍ទៅប្រធានរបស់ភូមិភាគ អាហ្នឹងមួយ។ នៅពេលនោះគឺខាងលើក៏ភ្ជាប់ ហៅថាភ្ជាប់តារាងទាក់ទងមកឲ្យនៅខាងភូមិភាគដែរ មកខាងសេនាធិការដែរ។

[១១:៤៣:៥៦]

**ស៖** ចង់ឲ្យលោកបញ្ជាក់ថា លោកដឹងអត់ទេ ថាតើអ្នកណាជាថ្នាក់លើបំផុតដែល កែ ពក ត្រូវរាយការណ៍ឲ្យ?

**ឆ៖** កែ ពក ដែលរាយការណ៍ពេលនេះ តាមខ្ញុំចាំបាន គឺរាយការណ៍ទៅតាមថ្នាក់របស់វា។ គឺគាត់រាយការណ៍ទៅតាម ឲ្យទៅខាងប្រធានលេខាភាគ ហើយលេខាភាគបានរាយការណ៍បន្ត អានេះគឺតាមក្រឹត្យក្រមរបស់វា។

**ស៖** តើពេលហ្នឹង កែ ពក គាត់រាយការណ៍ទៅថ្នាក់លើរបស់គាត់ តើគាត់រាយការណ៍តាមមធ្យោបាយណាដែរ? ហើយរាយការណ៍ញឹកញាប់អត់ទេពីហេតុការណ៍ដែលកើតមានឡើងហ្នឹង?

**ឆ៖** នៅពេលនោះ ឃើញថាការរាយការណ៍របស់ កែ ពក គឺវារាយការណ៍ទៅតាមទូរលេខ គឺថា ដូចថាពេលណាដែលមានហៅថា ពេលមានបញ្ហាណាសំខាន់ៗដែលឲ្យផ្ដល់ដំណឹងទៅវិញទៅមក វាមានសមរភូមិច្រើនពេលនោះ ដែលខាងភូមិភាគឧត្តរ នៅភូមិភាគនិរតីអ៊ីចឹង ដូច្នេះគេត្រូវការរាយ-ការណ៍មកខាងលើដើម្បីក្ដាប់សភាពការណ៍ធ្វើសង្គ្រាម។

[១១:៤៥:៣៩]

**ស៖** ចាស អរគុណ។ នៅមានសំណួរចុងក្រោយមួយពាក់ព័ន្ធនឹងឆ្នាំ៧៣ ហ្នឹង គឺ ចង់សួរលោក

ថាឆ្នាំ៧៣ ហ្នឹង មានទូរលេខហើយ បានដំណើរការហើយ នៅពេលដែលលោកធ្វើការខាងផ្នែកទូរលេខហ្នឹងតើលោកមានធ្លាប់បានផ្ញើទូរលេខទៅមន្ទីរ៨៧០ទេ ក្នុងឆ្នាំ៧៣?

**ឆ៖** នៅក្នុងឆ្នាំ៧៣ហ្នឹង គឺថា តាមដែលខ្ញុំដឹង គឺមានផ្ញើទៅខាង៨៧០ដែរ ប៉ុន្តែផ្ញើតែដំណឹងជ័យជម្នះ គេវាយជាម៉ាស៊ីនខ្មែរ ព្រោះខ្ញុំៗអត់មែនអ្នកបកប្រែទេ ខ្ញុំគ្រាន់ថាប៉ុណ្ណឹង គ្រាន់វាយសួរអក្សរខ្មែរ គេឱ្យសិទ្ធិតែផ្ញើដំណឹងជ័យជម្នះ ឯបញ្ហាអីទៀតអត់ទេ។

**ស៖** អ៊ីចឹងលោកដឹងបញ្ហាដែរគេផ្ញើទូរលេខទៅថ្នាក់លើ គឺមន្ទីរ៨៧០ហ្នឹង ដឹងហ្នឹងដឹងដោយអ្នកណា ឬក៏ដឹងដោយខ្លួនឯង? ប្រសិនបើមានគេប្រាប់តើឈ្មោះអ្នកប្រាប់លោក?

**ឆ៖** គឺខាងខ្ញុំ ខ្ញុំឱ្យទៅខាង៨៧០ហ្នឹង គឺផ្ញើតែដំណឹងជ័យជម្នះ ព្រោះដំណឹងជ័យជម្នះហ្នឹងវាយចេញជាអក្សរខ្មែរតែម្តង អត់មានបកជាលេខកូដអីទេ។ អ៊ីចឹងខ្ញុំដឹងតាមរយៈហ្នឹងទេ។

[១១:៤៧:២៧]

**ប្រធានអង្គជំនុំ៖**

លោកស្រីតំណាងសហព្រះរាជអាជ្ញា គប្បីជំរុញនៃការតាំងសំណួរឱ្យចូលយុត្តាធិការ ពេលវេលាចំណាយ១ម៉ោងហើយ សំណួរមិនទាន់ចូលនៅក្នុងអង្គហេតុយុត្តាធិការ អ.វ.ត.ក នៅឡើយទេ ទើបដល់៧៣ ទេ ពេលវេលាមិនច្រើនទេ យើងបានកំណត់ច្បាស់លាស់រួចហើយអំពីពេលវេលាសម្រាប់ភាគីក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា សុង ឆវ័ន្ត៖**

អរគុណលោកប្រធានដែលបានរំឮក។ ខ្ញុំនឹងចំណាយពេលបន្តិចទៀតទេ មុននឹងចូលដល់ឆ្នាំ៧៥ ព្រោះវា អង្គហេតុនេះវាមានបញ្ហាពាក់ព័ន្ធគ្នាបន្តិច។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ខ្ញុំនឹងសួរលោកបន្តនៅក្នុងឆ្នាំ៧៤ នៅឆ្នាំ៧៤ហ្នឹងពេលហ្នឹងលោកនៅកន្លែងណា? ហើយបានធ្វើអ្វី?

**លោក ស្វួន កានិល៖**

**ឆ៖** នៅក្នុងឆ្នាំ៧៤ គឺគេដកខាងខ្ញុំ ហើយនិងខាងសេនាធិការភូមិភាគ ទៅ មកនៅខាងសៀមរាប។ មកខេត្តសៀមរាបវិញ មកវ៉ៃនៅខាងសៀមរាបវិញ ថាអ៊ីចឹងខ្លីៗ។

[១១:៤៨:៣៧]

**ស៖** អ៊ីចឹងនៅពេលដែលឆ្នាំ៧៤ គេដកលោកមកសៀមរាបហ្នឹង លោកមានដឹងបញ្ហាដែលគេជម្លៀសប្រជាជននៅក្នុងខេត្តក្រចេះ ខេត្តឧដុង្គ កំពង់ចាមទេ ក្នុងឆ្នាំ៧៤?

**ឆ៖** ក្នុងឆ្នាំ៧៤ គឺថា ខ្ញុំវាអត់បានដឹងទេអាបញ្ហាជម្លៀសប្រជាជន។

**ស៖** ចាស សូមអរគុណ។ ឥឡូវខ្ញុំនឹងឆ្លងចូលដល់ឆ្នាំ៧៥ បន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ភូមិភាគរបស់ កែ ពក ហ្នឹងគឺ ភូមិភាគ ក្លាយជាភូមិភាគឧត្តរថ្មីហើយ ឬក៏ភូមិភាគកណ្តាល។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ពេលដែល ក្រោយពី១៧ មេសា មក ដូច្នេះ គឺត្រូវការបែងចែកហើយ បែងចែកភូមិភាគឧត្តរចាស់ មក១គឺថាមកខាងភូមិភាគកណ្តាល។ គឺជាការត្រឹមត្រូវដែលខ្ញុំនិយាយនេះ ត្រឹមត្រូវ បែងចែក។ ហើយខ្ញុំកាលនោះគេឲ្យមកតែ ដែល កែ ពក គាត់មកនៅកំពង់ចាមហ្នឹង គឺខ្ញុំមក គេយកតែអ្នកទូរលេខមកទេ ហើយនិងកងការពារ ក្រៅពីហ្នឹងគេឲ្យនៅតំបន់៣៥ឯណោះ នៅសៀមរាបហ្នឹង។

**ស៖** អ៊ីចឹងនៅពេលដែលលោកមកកំពង់ចាមជាមួយ កែ ពក តើពេលនោះស្ថានភាពប្រជាជនយ៉ាងម៉េចដែរក្នុង៧៥ហ្នឹង មានការជម្លៀស ឬក៏គេបញ្ជូនប្រជាជនមានចេញទៅណា ទៅកន្លែងផ្សេងដែរទេ?

**ឆ៖** នៅក្នុងឆ្នាំ៧៥ ហ្នឹងគឺអាបញ្ហាជម្លៀសប្រជាជនហ្នឹង គឺថាខាងខ្ញុំ គឺពុំសូវបានដឹងទេ ដោយសារខ្ញុំនៅសមរភូមិមុខនោះ។ អាហ្នឹងគឺផ្នែកខាងស្រុកខាងអី។ ដូច្នេះវាការងារខុសគ្នា។

[១១:៥០:៥៥]

**ស៖** ចុះនៅពេលដែលលោកចូលដល់កំពង់ចាមភ្លាម តើលោកមានដែលឃើញសាកសព ឬក៏ឃើញស្ថានភាពនៃការរស់នៅរបស់ប្រជាជនពេលហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ពេលដែលខ្ញុំចូលដល់កំពង់ចាមភ្លាម ពេលនោះសភាពការណ៍ពេលនោះ គឺថារៀបចំខ្លះទៅហើយ។ បើកំពុងដែលពេលការប្រយុទ្ធគ្នា អានោះបានមានសាកសពនៅតាមផ្លូវ មកត្រើង មកអីហ្នឹង ហើយខ្ញុំអ្នកទៅដុតកុំឲ្យស្អុយនៅហ្នឹង អ្នកដុតផ្ទាល់នៅហ្នឹង អាហ្នឹងពេលវ៉ៃគ្នា។ ដល់ពេលចប់ហើយគឺគេរៀបចំហើយ។ ដូច្នេះ ប្រជាជន ខ្ញុំអត់ឃើញដែរនៅក្នុងក្រុង មិនដឹងគេយកទៅណាទេកាលនោះ។

**ស៖** លោកថា លោកអត់បានឃើញប្រជាជនហ្នឹង មានន័យថាម៉េច? សូមលោកជួយបញ្ជាក់មក ហើយខ្ញុំចង់ឲ្យលោកសង្កត់ធ្ងន់បន្តិច ទៅនឹងប្រជាជន ជនជាតិចាម ជនជាតិឥស្លាម នៅពេលហ្នឹង នៅពេលដែលលោកទៅដល់កំពង់ចាមហ្នឹង តើមានដែលឃើញប្រជាជន ដែលជាជនជាតិចាម ឬ

ឥស្លាមហ្នឹងទេ?

**ឆ៖** ពេលដែលខ្ញុំទៅដល់កំពង់ចាមហ្នឹង គឺខ្ញុំបានដឹង បញ្ហាជនជាតិខ្មែរឥស្លាមហ្នឹង គឺថាគេអត់មានជម្លៀសទេ ពីព្រោះថាខ្មែរឥស្លាម ខ្ញុំដឹងគាត់នៅអន្លង់សងណោះ នៅខាងពាមជីកងណោះ គឺគាត់នៅក្នុងភូមិរបស់គាត់នៅដដែល។ អានេះ ខ្ញុំមិនបានទៅដាក់មងដាក់អី ពីព្រោះខ្ញុំមានមិត្តភក្តិខ្ញុំមួយនៅអង្គរបាន។ ដូច្នេះ ទៅស្រុកហ្នឹងឃើញចាមនៅហ្នឹង គេឲ្យនៅហ្នឹងបាទ។

**ស៖** ចាស សូមអរគុណ។ ខ្ញុំចង់ពិភាក្សាលម្អិតជាមួយលោក ពាក់ព័ន្ធទៅនឹងភូមិភាគកណ្ដាល ឬក៏ភូមិភាគឧត្ដរចាស់។ បើនិយាយពីឋានានុក្រម មុននេះលោកបាននិយាយហើយគឺថា កែ ពក គឺជាលេខាភូមិភាគ។ ខ្ញុំចង់បញ្ជាក់ថា តើអ្នកណាជាអនុលេខាភូមិភាគរបស់ កែ ពក ពេលហ្នឹង?

[១១:៥៣:០៥]

**ឆ៖** ពេលហ្នឹង គឺថាដល់ពេលមក គាត់គម្រោងនោះគឺថា គាត់មកកំពង់ចាមដឹងថា កាលមុនគាត់នៅសេនាធិការភូមិភាគ ដល់ក្រោយមកបានគាត់ឡើងជាលេខាភាគ។ ដូច្នេះនៅកាលមុនគេអត់ទាន់បានបែងចែកទេ គេនៅឧត្ដរ ភូមិភាគឧត្ដរហ្នឹងវាធំ។ ដូច្នេះ គេទើបនឹងបែងចែកដែលពេលក្រោយ១៧ មេសា ហ្នឹងគេឲ្យតំបន់៣៥ នោះទៅឈ្មោះ សែ ពីដើមគាត់, ពក លេខាមក សែ ហ្នឹងអនុប្រធាននៅខាងសៀមរាបហ្នឹង។

**ស៖** លោកថា គេចាប់ផ្ដើមបែងចែកហ្នឹងក្រោយ១៧ មេសា។ ក្រោយ ១៧ មេសា ក្នុងឆ្នាំ៧៥ តែម្ដង ឬក៏ក្នុងឆ្នាំណាបន្ទាប់ពីហ្នឹងទៀត?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេបាទ។

**លោក សួន កានិល៖**

**ឆ៖** បាទ ក្រោយ ១៧ មេសា ហ្នឹងក៏មិនយូរដែរ ប៉ុន្តែខ្ញុំភ្លេចថ្ងៃខែទៅ។ ដល់ពេលហ្នឹងគឺថាប្រហែលជាបួនប្រាំខែក៏មិនដឹង អាហ្នឹងខ្ញុំភ្លេចចាំមិនច្បាស់ ប៉ុន្តែក៏មិនយូរដែរ បើខ្ញុំបែងចែកភូមិភាគហ្នឹង ព្រោះពីដើមគាត់ជាសេនាធិការ ក្រោយមកគាត់ឡើងភូមិភាគ។ ហើយដល់ពេលហ្នឹងគេដាក់ឈ្មោះ សែ នៅខាង -- ជាអនុប្រធាន នៅហ្នឹងសៀមរាបនោះ។ គាត់ជាអនុប្រធានរបស់ កែ ពក។ នេះតាមសំណួរ។

[១១:៥៤:៣៩]

**សួរដោយកញ្ញា សុង ឆវ័ន្តៈ**

**ស៖** ចាស អរគុណ។ បើនិយាយដល់គណៈភូមិភាគកណ្ដាល ឬក៏មន្ទីររបស់គណៈភូមិភាគកណ្ដាល នៅក្នុងចម្លើយរបស់លោក ដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតរបស់សហចៅក្រមហ្នឹងអង្កេតហ្នឹង គឺនៅឯកសារ E3/344។ នៅត្រង់ ERN ជាភាសាខ្មែរគឺ 00373496, ជាភាសាអង់គ្លេសគឺ 00384428 និងជាភាសាបារាំងគឺ 00426144។ ពេលនោះលោកបានប្រាប់អ្នកស៊ើបអង្កេតថា "គណៈភូមិភាគកណ្ដាលមានសមាជិកប្រាំនាក់៖ កែ ពក ជាប្រធាន, ស្រេង ជាអនុលេខាបានបាត់ខ្លួន, តុល ជាសមាជិកបានបាត់ខ្លួន, ចន បានបាត់ខ្លួន, សំអឿន ប្អូនថ្លៃ កែ ពក បានបាត់ខ្លួន"។ ចង់បញ្ជាក់ថា ការឆ្លើយរបស់លោកហ្នឹង គឺលោកនៅរក្សាចម្លើយដដែល ឬយ៉ាងណា?

**ឆ៖** ខ្ញុំឆ្លើយ ខ្ញុំសូមនៅរក្សាចម្លើយដដែល។

**ស៖** ចាស សូមអរគុណ។ តើលោកមានដែលស្គាល់ឈ្មោះ សួ ទេ? ហើយ សួ ហ្នឹងជាអ្នកណាប្រសិនបើលោកស្គាល់?

[១១:៥៦:១៨]

**ឆ៖** គឺខ្ញុំស្គាល់ឈ្មោះ សួ។ សួ វាមានពីរ។ មួយជា សួ នៅខាងគណៈស្រុក, មួយ សួ នៅខាងមន្ទីរ។ មានពីរបាទ។

**ស៖** ហើយនៅក្នុងចម្លើយដដែល ឯកសារដដែល ចុះមកខាងក្រោមបន្តិចហ្នឹងលោកថា សួ ហ្នឹងគឺជាអ្នកតស៊ូនយោបាយ ហើយបានបាត់ខ្លួននៅក្នុងឆ្នាំ៧៧។ តើ សួ មួយណាដែលលោកសំដៅដល់ហ្នឹង?

**ឆ៖** គឺ សួ នៅខាងមន្ទីរ។

**ស៖** ចាស អរគុណ។ ចុះពីភូមិភាគមក ខ្ញុំចង់និយាយដល់ ពាក់ព័ន្ធនឹងរឿងតំបន់។ នៅក្នុងភូមិភាគកណ្ដាលហ្នឹងគឺមានតំបន់បី គឺតំបន់៤១, ៤២ និង៤៣ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវ។ តំបន់៤១, ៤២, ៤៣។

**ស៖** ហើយនរណាជាប្រធានតំបន់៤១? ហើយអ្នកណាជាអនុប្រធានតំបន់៤១?

**ឆ៖** ប្រធានតំបន់៤១ កាលនោះឈ្មោះ ស្រេង។ អនុ ខ្ញុំអត់ស្គាល់ដែរ ស្គាល់តែប្រធាន។

**ស៖** ចុះ ស្រេង ហ្នឹង គាត់ធ្វើបន្តរហូត ឬមានអ្នកណាឡើងជំនួសគាត់ក្រោយមកទៀត?

[១១:៥៨:១៦]

**ឆ៖** ក្រោយមកទៀតគឺ មានគេឡើងជំនួសដែរឈ្មោះ តាអាន។

**ស៖** ចុះលោកទេ ហេតុអីបានជា តាអាន ឡើងជំនួស ស្រេង? ហើយ ស្រេង បាត់ទៅណា?

**ឆ៖** គឺខ្ញុំដឹងដោយសារអ៊ីចេះទេ ដែលថា ស្រេង បាត់ខ្លួន តាអាន ឡើងជំនួស គឺខ្ញុំដឹងដោយសារគេធ្វើអាកូនសៀវភៅ អាសៀវភៅទាក់ទងទូរលេខហ្នឹង គឺខ្ញុំថា ប៉ុន្តែខ្ញុំអត់ប៊ានសួរគេដែរ ខ្ញុំខ្លាចដែរ ដល់គេថា ឥឡូវតំបន់៤១ គឺផ្លាស់ប្តូរឈ្មោះហើយ គេគ្រាន់តែប្រាប់អ៊ីចឹងទេ។ ប្រាប់ថា ឥឡូវ ស្រេង គេប្រាប់ថា ឈប់ហើយ គេគ្រាន់តែថាអ៊ីចឹង ហើយជំនួសដោយ តាអាន។ គេគ្រាន់តែថាអ៊ីចឹងក៏ខ្ញុំអត់សួរគេតទៅទៀត បាត់ខ្លួន គេអត់ឲ្យខ្ញុំសួរច្រើនដែរបាទ។

**ស៖** លោករំឭកដល់កូនសៀវភៅទាក់ទងទូរលេខហ្នឹង ហើយលោកដឹងព័ត៌មានរឿង ស្រេង បាត់ខ្លួន។ ចង់ដឹងថា សៀវភៅទូរលេខហ្នឹង ជាសៀវភៅប្រភេទអីគេ? ហើយវាយ៉ាងម៉េចដែរសូមលោកជួយពន្យល់បន្ថែម។

[១១:៥៩:៣៣]

**ប្រធានអង្គជំនុំ៖**

លោកកុំអាលទាន់ឆ្លើយ ក្បាលមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការទេ។

**លោក សួន កានិល៖**

**ឆ៖** គឺថា ខាងផ្នែកទូរលេខនោះ វាមានហៅថា ទីមួយវាហៅថា តារាងទាក់ទង។ មួយគឺតារាងទាក់ទង ថាទាក់ទងពីតំបន់ ដែលថាពីភូមិភាគទៅតំបន់។ ដូច្នេះ ពីមុនគេដាក់ឈ្មោះ ស្រេង ដល់ក្រោយមកគេដាក់ឈ្មោះ តាអាន។ ដូច្នេះ ខ្ញុំក៏ឆ្ងល់ដែរ ប៉ុន្តែខ្ញុំអត់ប៊ានសួរទេពេលនោះ គ្រាន់តែដឹង។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកពិសាថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

[១២:០០:៤៤]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ កូនក្ដីខ្ញុំបានជម្រាបមកខ្ញុំថា គាត់មានអារម្មណ៍ មានសុខភាពមិនល្អ គាត់សូមបន្តតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោម ដោយសារឈឺខ្នង ឈឺក្បាល និងមិនអាចផ្ដង់អារម្មណ៍បាន ហើយយើងនឹងដាក់ជូននូវលិខិតលះបង់សិទ្ធិទៅអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន លោកលោកស្រីចៅក្រម ខ្ញុំចង់លើកយកនូវបញ្ហាមួយទាក់ទងការសម្រេច។ អង្គជំនុំជម្រះសាលាដំបូងកាលពីម្សិលមិញ បានបណ្ដេញលោក អ៊ីនូហ្ស៊ី ដោយសារតែគាត់បានប្រមាថតុលាការ។ លោកប្រធាននៅក្នុងយុត្តាធិការ ដែលខ្ញុំធ្វើការអនុវត្តនៅពេលដែលមេធាវីមួយដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ត្រូវបានសម្រេចដោយអង្គជំនុំជម្រះថា ប្រមាថតុលាការ ដូចដែលបានរកឃើញកាលពីម្សិលមិញនោះ បុគ្គលដែលប្រមាថតុលាការនោះ នឹងត្រូវមានឱកាសមួយក្នុងការសម្រេចទាក់ទងទៅនឹងការប្រមាថតុលាការនេះ។

ដើម្បីលះបង់ ឬក៏ដើម្បីបោះបង់ចោលនូវការប្រមាថនោះវិញ តាមប្រព័ន្ធច្បាប់ខំមិនឡ គឺថាលះបង់នូវការប្រមាថហ្នឹង គឺថាប្រហែលលោក កាណាវាស គាត់យល់ស្របជាមួយខ្ញុំ គឺថា នៅពេលដែលមានការប្រមាថ ត្រូវតែមានការលះបង់នូវការប្រមាថ។ ក្នុងករណីនេះ អ្នកដែលបានប្រមាថហ្នឹង ដូចដែលយើងឃើញ គឺលោក អ៊ីនូហ្ស៊ី គឺថាត្រូវមានឱកាសមួយប្រសិនបើគាត់ចង់ ដើម្បីឲ្យគាត់ធ្វើការសុំអភ័យទោសដល់តុលាការដែលគាត់បានប្រមាថនោះ។ ដូច្នេះ ប្រសិនបើគាត់ធ្វើការសុំទោស ការប្រមាថហ្នឹងបានបញ្ចប់ ប្រសិនបើគាត់ គឺអ្នកដែលប្រមាថតុលាការហ្នឹងមានចេតនា ដើម្បីធ្វើការសូមទោស ឬក៏យើងនិយាយថា លះបង់នូវការប្រមាថនោះ។

[១២:០៣:១៧]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាមានការបោសសម្អាតគ្រប់គ្រាន់រួចទៅហើយនៅក្នុងប្រទេស

នេះ។ ដូច្នេះ យើងមិនចាំបាច់មានការបោសសម្អាតទៀតទេ។

[១២:០៣:៣១]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:១១:២០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្តល់វេទិកា -- ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយតបទៅនឹងការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា ដែលបានលើកឡើងបញ្ហាចុងក្រោយអម្បាញ់មិញនេះ។ សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងបានចាំថា ផ្នែកដែលព្រះរាជអាជ្ញាបានលើកឡើង គឺមិនមែនជាផ្នែកមួយនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការមានឱកាសមួយដើម្បីផ្តល់ឱកាសដល់លោក អ៊ីនូហ្ស៊ី ដើម្បីធ្វើការសុំទោស ប្រសិនបើគាត់ចង់។ ប៉ុន្តែបើសិនគាត់មិនចង់គឺជាការសម្រេចរបស់គាត់។ គឺជាការដែលធ្វើដ៏ត្រឹមត្រូវមួយដោយ -- ទាក់ទងទៅនឹងការដែលគាត់និយាយថា វាមានការបោសសម្អាតច្រើនគ្រប់គ្រាន់រួចទៅហើយនៅក្នុងប្រទេសកម្ពុជា អ្វីដែលគាត់និយាយហ្នឹងគឺជាអ្វីដែលមិនអាចទទួលយកបានទាល់តែសោះក្នុងការដែលនិយាយទៅកាន់ប្រជាជនដែលទទួលរងការឈឺចាប់រួចរាល់ណាស់ទៅហើយ។

[១២:១២:៣៤]

ប្រសិនបើគាត់មិនធ្វើការសូមអភ័យទោសទេ គឺយើងនឹងដាក់បញ្ចូលទៅក្នុងរបាយការណ៍បន្ថែមដែលអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើជូនទៅគណៈមេធាវីរបស់គាត់។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការនៅរសៀលថ្ងៃនេះ ដោយមូលហេតុមានបញ្ហាសុខភាពមិនអាចអង្គុយតាមដានក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការបាន។ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឱ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការ

នេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

[១២:១៣:៣៣]

អង្គជំនុំជម្រះ តម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់ជូនមកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះដោយមានចុះហត្ថលេខ ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់លោក នួន ជា។ បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលកិច្ចដំណើរការសវនាការពេញមួយរសៀលថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនៅឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១៤ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការសាជាថ្មីម្តងទៀត ហើយក៏សូមសួស្តីផងដែរលោក សួន កានិល។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** កាលពីព្រឹកមិញ យើងបានពិភាក្សាគ្នាដល់តំបន់៤១ ហើយនៅពេលរំឭកដល់លេខា និងអនុលេខាតំបន់ លោកបានប្រាប់អង្គសវនាការថា ឈ្មោះ ស្រេង គឺជាប្រធានតំបន់៤១ ហើយក្រោយមកត្រូវឡើងជំនួសដោយ តាអាន។ ហើយលោកថាលោកដឹង បញ្ហានេះដោយសារតែមានកូនសៀវភៅទំនាក់ទំនងទូរលេខមួយដែលបានសរសេរថា "ស្រេង ជំនួសដោយ តាអាន"។ ខ្ញុំចង់សួរបញ្ជាក់លោកថា តើនៅក្នុងសៀវភៅទូរលេខសម្រាប់ទំនាក់ទំនងដែលលោកបានឃើញនោះ សៀវភៅហ្នឹងសរសេរថាអ្នកណាឈ្មោះអី? មានឋានៈអីនៅក្នុងហ្នឹង ហើយជំនួសដោយអ្នកណា? ឬក៏សៀវភៅហ្នឹងសរសេររបៀបណាដែរ? សូមលោកជួយបញ្ជាក់ឲ្យលម្អិតនៅក្នុងនេះ។

[១៣:៣៤:១៥]

**លោក សួន កានិល៖**

**ឆ៖** បាទ ខ្ញុំសូមគោរពលោកប្រធានជាថ្មី អង្គប្រជុំ។ គឺថាខ្ញុំសូមឆ្លើយនូវសំណួរហ្នឹង គឺថាសំណួរដែលដាក់ តាអាន មកជំនួសហ្នឹង គឺខ្ញុំដឹងដោយសារនៅក្នុងផ្នែកទូរលេខ វាមានហៅថាតារាងទាក់ទង គឺខ្ញុំអ្នកធ្វើនៅតាមភូមិភាគ។ អ្នកណាទាក់ទងទៅណា? អីទៅណា? ហើយនៅក្នុងនោះគេដាក់ថា ដូចថាទៅខាងតំបន់៤១អ៊ីចឹង ពីដើមដាក់ឈ្មោះ ស្រេង ជាលេខាតំបន់។ ដល់ក្រោយមកមិនដឹងយ៉ាងម៉េច? ដល់ពេលគេមកធ្វើការនៅក្នុងភូមិភាគហ្នឹងទៀត ស្រាប់តែអត់ឃើញឈ្មោះហ្នឹង។ ទៅខាងភូមិភាគថា ឥឡូវអាកន្លែងហ្នឹង គេដូរឈ្មោះហើយ។ អ៊ីចឹងខ្ញុំក៏មិនចាប់អារម្មណ៍ថា បើថាដូរឈ្មោះក៏ទៅ។ ព្រោះនៅក្នុងពេលនោះ គឺមិនអាចនឹង គឺថាគេប្រាប់ខ្ញុំថាមិនឲ្យ -- គេថាមិនដឹង មិនឮ មិនឃើញ និយាយ ព្រោះបើថាឃើញយ៉ាងម៉េច ដឹងយ៉ាងម៉េចធ្វើតាមអ៊ីចឹងបានៗអត់គ្រោះថ្នាក់។ ដល់អ៊ីចឹងខ្ញុំធ្វើតាមអ៊ីចឹង។ ដល់ពេលនេះ ខ្ញុំដឹងថា ឬក៏ដឹងតាមរយៈនីរសារដែលគេមក គេមកធ្វើការទៅ ដឹងតាមរយៈនីរសារហ្នឹង។ បើគេផ្លាស់ប្តូរ គឺនីរសារផ្លាស់ប្តូរដែរ។ ដល់អ៊ីចឹងបានខ្ញុំដឹងថា អូ! ប្រហែលជាបាត់ខ្លួន។ គ្រាន់តែដឹងថាអ៊ីចឹងទេ តាមដែលខ្ញុំយល់ប៉ុណ្ណឹង។

**ស៖** ចាស អរគុណ។ មុននឹងចូលដល់តំបន់៤២ ចង់ឲ្យលោកបញ្ជាក់បន្តិចថា សៀវភៅទូរលេខ ឬក៏តារាងដែលលោកធ្វើហ្នឹង ជាតារាងដែលមានលេខកូដ ឬក៏ជាតារាងដែលមានសរសេរអក្សរមានឈ្មោះ មានអីត្រឹមត្រូវ?

[១៣:៣៥:៥៦]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក សួន កានិល៖**

**ឆ៖** តារាងនៅក្នុងកូនសៀវភៅហ្នឹង គឺមានតារាងមួយ តារាងទាក់ទង។ ក្នុងតារាងទាក់ទងហ្នឹងវាមានតារាង១ឈ្មោះ។ នៅក្នុងតារាងទាក់ទងហ្នឹង គេដាក់ជាលេខកូដ រួចថាលេខគេដាក់៣៤ ទៅគេដាក់ឈ្មោះហ្នឹង។ គឺថាឈ្មោះ ស្រេង អីចឹងមានលេខ១កូដ គេដាក់អីចឹង។

**ស៖** ចាស សូមអរគុណ។ ឥឡូវខ្ញុំនឹងឆ្លងចូលទៅដល់តំបន់៤២។ លោកនៅចាំទេថាប្រធានតំបន់៤២ ហើយអនុរបស់គាត់ហ្នឹងមានឈ្មោះអី ពេលហ្នឹង?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** បង្អង់!

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយបាទ! ចេះតែភ្លេច។

**លោក សួន កានិល៖**

**ឆ៖** គឺខ្ញុំនៅចាំបាន ដោយសារការ មិនខុសពីខាងតំបន់៤១ទេ ដូចតែគ្នាអីចឹង។ គឺថាដល់ពេលហ្នឹងទៅក៏ ដល់ពេលបាត់ទៅក៏ដូរនីរសារ ដូរអីទៅ ក៏គេមក។ ភាគច្រើនក្នុងកន្លែងទូរលេខហ្នឹង គឺពួកនីរសារហ្នឹងឯងតែមកគឺចូលហ្នឹងបាទ ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចង់បានឈ្មោះរបស់គាត់លោក ឈ្មោះ?

**ឆ៖** មុនដំបូងឈ្មោះ តុល ដល់ឈ្មោះ តុល, ដល់ក្រោយមកក៏បាត់ខ្លួនពីឈ្មោះ តុល ហ្នឹងមកក៏ឡើងឈ្មោះ អឿន។ អឿន ហ្នឹងគឺប្អូនថ្លៃ តាពក ហ្នឹង។ បាទ និយាយឲ្យខ្លី១។

**ស៖** ចាស១ ហើយចង់ដឹងថា តុល ហ្នឹងគាត់បាត់ទៅណាលោកដឹងទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** លោកៗបង្អង់បន្តិច ចាំក្បាលមីក្រូហ្វូនដំណើរការ។

**ឆ៖** ចេះតែភ្លេច។ គឺឈ្មោះ តុល ហ្នឹងបាត់ខ្លួន គឺខ្ញុំ -- គេៗអត់ឲ្យដឹងដែរ។ ចំពោះខ្ញុំការងារខ្ញុំវានៅៗ គឺថាខ្ញុំនៅលើផ្ទះថ្មផ្សេង។ ដូច្នេះខ្ញុំអត់ៗនេះដែរ។

[១៣:៣៨:០៤]

**ស៖** ចាស អរគុណ។ ចុះតំបន់៤៣ អ្នកណាជាប្រធាន? ហើយអ្នកណាជាអនុ? ហើយលើកក្រោយមកមានអ្នកជំនួសអត់ទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** លោកចាំបន្តិច!

**ឆ៖** គឺតំបន់៤៣ មានអ្នកជំនួសដូចគ្នា។ ពីមុនឈ្មោះ ចន ក្រោយមកជំនួសដោយ តាងិន។ បាទ ដូចគ្នា គ្រាន់តែបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ចាស អរគុណ។ ដោយសារព្រឹកមិញនេះលោកបាននិយាយឲ្យនិយមន័យទៅដល់អ្វីជាទូរលេខ ហើយសារៈសំខាន់របស់ទូរលេខ។ ហើយខ្ញុំបានស្នើសុំថា ខ្ញុំនឹងពិភាក្សាលម្អិតជាមួយលោកនៅបន្តិចទៀតនេះ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់មើលថាពាក្យ ទូរលេខត្រូវបានចាត់ទុកថាជាសរសៃឈាមរបស់អង្គការនីមួយៗ ឬក៏អង្គភាពនីមួយៗហ្នឹងមានន័យថាម៉េច? សូមលោកពន្យល់ដោយលម្អិតបន្តិចមើល?

[១៣:៣៩:១៤]

**ឆ៖** បញ្ហាហ្នឹងគឺខ្ញុំអាចនិយាយបាន ពីព្រោះថានិយមន័យនៃពាក្យថា “សារទូរលេខ” នេះវាដូចជាសរសៃឈាម។ បើគេប្រៀបធៀបហ្នឹងពីមនុស្សយើង ដូច្នេះនៅក្នុងការ -- នៅក្នុងពេលនោះឲ្យតែដាច់ទូរលេខគឺថាដាច់អ្វីៗទាំងអស់ ពីលើមកក្រោម ពីក្រោមឡើងលើអីទៅដាច់ វាបញ្ជាគ្នាអត់បាន។ ខ្ញុំគ្រាន់តែចង់លើកឧទាហរណ៍ថា ពេលដែលឆ្នាំ៧៥ហ្នឹង វែដាច់ភ្លាមដល់ពេលនេះ ទូរលេខខាងខ្ញុំវាត្រូវខូច គេយកមកធ្វើនៅលើ។ ដូច្នេះគឺខាងលើផ្តល់ដំណឹងមកអត់ទាន់ គ្រាន់តែថា ដូចថាប្រជាជនយើងដែលនេះទៅ គ្រាន់តែកាប់សណ្តាគារ ហើយនិងយកកង់ឡានមកធ្វើស្បែកជើងហ្នឹងអស់រាប់រយ។ អាហ្នឹងបានៗន័យថាវាដាច់សរសៃឈាមហ្នឹង វាអាចបណ្តាលឲ្យមានការលំបាក ឬក៏មានការខ្វះខាតអ៊ីចឹង។

**ស៖** ចាស អរគុណ។ ចុះការទំនាក់ទំនងគ្នាពីថ្នាក់មជ្ឈិមមកតំបន់ ឬក៏ទៅភូមិភាគវិញ តើគេប្រើតែទូរលេខ ឬក៏មានមធ្យោបាយផ្សេងដើម្បីទំនាក់ទំនងគ្នាដែរ? លោកបង្អង់បន្តិច។

**ឆ៖** ការទំនាក់ទំនងពីតំបន់មកភូមិភាគ ឬក៏ពីភូមិភាគទៅខាងលើហ្នឹង សំខាន់គេទាក់ទងតាមទូរលេខវាលឿន ហើយទាក់ទងគ្នាតាមទូរលេខហ្នឹងហើយ លឿន។

**ស៖** អ៊ីចេះទេ ក្រៅពីទូរលេខតើមានអីផ្សេងទេ ដូចជានីរសារ មានសំបុត្រ ឬក៏មានវិធីអី ផ្សេងក្រៅពីហ្នឹងទៀតទេ ក្រៅពីទូរលេខដើម្បីគេផ្ញើទំនាក់ទំនងគ្នា?

**ឆ៖** ក្រៅពីសារទូរលេខគាត់នៅមានការ ហៅថានីរសាររត់សំបុត្រដៃដែរ រត់សំបុត្រសរសេរដៃដែរ។

**ស៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូហ្វូន។

**កញ្ញា សុង ឆវ័ន្ត៖**

សូមទោសលោកប្រធាន។

[១៣:៤១:២៥]

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** តាមបទពិសោធន៍របស់លោកហ្នឹងរវាងទូរលេខ ហើយនិងនីរសារគេសរសេរដៃ ផ្ញើសំបុត្រហ្នឹង តើមួយណាដែលគេច្រើនប្រើញឹកញាប់ជាង? ហើយហេតុអ្វីលោកដឹងទេ?

**លោក សួន កានិល៖**

**ឆ៖** គឺសំបុត្រទូរលេខ និងសំបុត្រដៃហ្នឹងវាមានសារៈសំខាន់វាពីរ។ ទី១ គឺថាដោយសារខ្ញុំនៅហ្នឹងឃើញថាតាំងពីនីរសារវានៅក្នុងមន្ទីរមួយអ៊ីចឹង ដូចថាខ្ញុំអ្នកដែលថាមើល ដែលថាវានៅជាមួយគ្នាដូចមិត្តភក្តិអ៊ីចឹង។ ដូច្នេះសារទូរលេខគេនិយាយតែខ្លីៗ កាលណាដែលវែងៗ ឬក៏មានសារៈសំខាន់គេឲ្យមកតាម -- ឲ្យនីរសារទៅយក គេដាក់ឲ្យនីរសារទៅយក។

**ស៖** មានសំណួរចុងក្រោយមួយមុននឹងចូលដល់ប្រធានបទថ្មីមួយទៀត។ នៅក្នុងចម្លើយរបស់លោកដែលបានឆ្លើយប្រាប់អ្នកស៊ើបអង្កេត នៅត្រង់ឯកសារ E3/344 នៅត្រង់ ERN ជាភាសាខ្មែរហ្នឹងគឺហ្នឹង 00373498, ជាភាសាអង់គ្លេស 00384429, ជាភាសាបារាំង 00426148។ លោកបានរំឭក

ដល់ឋានានុក្រមនៃការទំនាក់ទំនង ហើយលោកបាននិយាយថា "ថ្នាក់មជ្ឈិមជាថ្នាក់ដែលខ្ពស់ជាងគេ បន្ទាប់មក គឺថ្នាក់ភូមិភាគ បន្ទាប់មកថ្នាក់តំបន់ បន្ទាប់មកទៀតថ្នាក់ស្រុក"។ តើលោកនៅតែរក្សាចម្លើយដដែលនេះ ឬយ៉ាងណា?

**ឆ៖** គឺខ្ញុំនៅរក្សាចម្លើយដដែល។

[១៣:៤៣:២៥]

**ស៖** ចាសសូមអរគុណ។ ខ្ញុំនឹងទុកបញ្ហាទូរលេខនេះមួយអន្លើ ដោយសហភាតាអន្តរជាតិរបស់ខ្ញុំលោក ឃីត រេយ៍ន័រ គាត់នឹងសួរលម្អិតលើបញ្ហាទូរលេខនេះ។ ប៉ុន្តែពេលនេះខ្ញុំឆ្លងចូលទៅដល់ប្រធានបទថ្មីមួយទៀត ទាក់ទងទៅនឹងការចាប់ខ្លួន ការឆ្លើយដាក់គ្នាទៅវិញទៅមក និងការបាត់ខ្លួនមនុស្ស។

នៅក្នុងឯកសារ E3/411 នៅត្រង់ ERN ជាភាសាខ្មែរ 00373513, ជាភាសាអង់គ្លេស 00390079, ជាភាសាបារាំង 00424039 នៅពេលដែលអ្នកស៊ើបអង្កេតបានសួរលោកពីរឿងចាប់មនុស្ស គាត់សួរថា "តើលោកអាចនិយាយលម្អិតពីបញ្ហានេះបានទេ?" ពេលនោះលោកបានឆ្លើយថា ដកស្រង់ "នៅពេលដែលស្ថានភាពបានផ្លាស់ប្តូរ គេបន្តចាប់មនុស្ស ហើយអ្នកដែលត្រូវចាប់នោះសុទ្ធតែជាមនុស្សដែលមានចម្លើយឆ្លើយដាក់ ការចាប់ខ្លួននៅពេលនោះមានលក្ខណៈទាំងខ្សែៗ ជាប់ទាក់ទងគ្នា ខ្ញុំដឹងរឿងនេះ ដោយសារតែតាមការសង្កេតរបស់ខ្ញុំនៅពេលនោះ"។ ខ្ញុំចង់បញ្ជាក់លោកថា ពេលនុ៎ងអ្វីដែលលោកឆ្លើយប្រាប់អ្នកស៊ើបអង្កេតហ្នឹង គឺលោកនៅរក្សាដដែល គឺលោកបានឃើញ ឬបានដឹងដោយការសង្កេតរបស់លោកផ្ទាល់តើមែនទេ?

**ឆ៖** គឺបញ្ហាហ្នឹងគឺថា ខ្ញុំនៅរក្សាដដែល។

**ស៖** ចាស អរគុណ។ ខ្ញុំមានសំណួរមួយចំនួន ទាក់ទងទៅនឹងការសង្កេតផ្ទាល់របស់លោក ក៏ដូចជាការដឹងឮផ្ទាល់របស់លោក។ ចង់ឲ្យលោកប្រាប់ទៅអង្គសវនាការថា តើពាក្យថា "ការបាត់ខ្លួន" ហ្នឹងមានន័យយ៉ាងដូចម្តេច?

[១៣:៤៥:៤១]

**ឆ៖** ខ្ញុំសូមឆ្លើយ គឺការបាត់ខ្លួន ដោយសារខ្ញុំអត់ឃើញគេទៅទៀត បានបាត់ អត់ឃើញមានមនុស្សហ្នឹងមកបន្តទៀត ហើយខ្ញុំសង្កេតតាមការដែលគេមកប្រជុំនៅក្នុងភូមិភាគ ដូចពីខាងតំបន់ខាងស្រុកអី។ ដល់អីចឹងទៅ ខ្ញុំថា គឺថាគេនិយាយថា ការបាត់ខ្លួន ការសង្កេតឃើញអីចឹង។

**ស៖** ចាស អរគុណ។ នៅក្នុងចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យ

សហចៅក្រមស៊ើបអង្កេតដែរ នៅត្រង់ ERN ជាភាសាខ្មែរគឺ 00373510, ជាភាសាអង់គ្លេស 00390077, ជាភាសាបារាំង 00424037។ ពេលនោះលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតពីអត្ថន័យនៃការបាត់ខ្លួនថា ដកស្រង់ "ការបាត់ខ្លួន មានន័យថា ស្លាប់។ ការបាត់ខ្លួន អាចជាការស្លាប់ដោយធម្មជាតិ ឬដោយមូលហេតុចាប់ខ្លួន និងការកម្ទេច"។ តើលោកនៅរក្សាចម្លើយដដែលនេះឬទេ?

**ឆ៖** គឺខ្ញុំសូមនៅរក្សាចម្លើយនេះដដែល។

**ស៖** នៅត្រង់ឯកសារដដែល គឺចុះមកក្រោមបន្តិច គឺនៅត្រង់ ERN ជាភាសាខ្មែរគឺ 003753 11, ជាភាសាបារាំង 00424037 និងជាភាសាអង់គ្លេស 00390078។ លោកក៏បានឆ្លើយប្រាប់អ្នកស៊ើបអង្កេតផងដែរថា ដកស្រង់ "ខ្ញុំមិនបានដឹងថា ពួកគេត្រូវបានបញ្ជូនទៅទីណាទេ តែភាគច្រើនគឺបានបញ្ជូនទៅកាន់កំពង់ចាមនិងភ្នំពេញ"។ ខ្ញុំចង់សួរបញ្ជាក់លោកថា តើចម្លើយដែលលោកប្រាប់ថា មនុស្សដែលបាត់ខ្លួន គឺគេភាគច្រើនបញ្ជូនទៅកំពង់ចាម និងភ្នំពេញហ្នឹង តើលោកដឹងដោយផ្ទាល់ ការសង្កេត ឬក៏មានអ្នកផ្សេងប្រាប់លោកដែរ?

**ឆ៖** បញ្ហានេះគឺខ្ញុំសូមឆ្លើយ។ គឺការបាត់ខ្លួនហ្នឹង គឺនែ៎-- សូមសំណួរម្តងទៀត ដូចមិនច្បាស់បាទ។

[១៣:៤៨:២២]

**ស៖** ចាស ប្រសិនបើនិយាយពីរឿងបាត់ខ្លួនលោកបានឆ្លើយ ប្រាប់អ្នកស៊ើបអង្កេតថា ពួកគេហ្នឹងត្រូវបានបញ្ជូនទៅទីណា លោកអត់ដឹងដែរ តែភាគច្រើនគឺគេបញ្ជូនទៅភ្នំពេញ ហើយនៅកំពង់ចាម ហើយខ្ញុំចង់ដឹងថា លោកឆ្លើយប្រាប់អ្នកស៊ើបអង្កេតហ្នឹង ថាគេបញ្ជូនទៅណាហ្នឹង គឺតាមការសង្កេតផ្ទាល់របស់លោក ឬក៏មានអ្នកផ្សេងគេប្រាប់លោក?

**ឆ៖** ខ្ញុំសូមឆ្លើយគឺការដែលបាត់ខ្លួននេះ គឺមានគេយកឈ្មោះមកឲ្យខ្ញុំមើល។

**ស៖** សូមជួយលោកជួយពន្យល់បន្តិចមើល ថាអ្នកណាយកឈ្មោះមកឲ្យលោក? ហើយយកមកហ្នឹងជារបៀបម៉េចដែរ? សូមលោកជួយពន្យល់ឲ្យបានក្បោះក្បាយលើបញ្ហានេះ។

**ឆ៖** ពេលដែលបាត់ខ្លួនហ្នឹងគឺខ្ញុំមិនទាន់ដឹងទេ ប៉ុន្តែដល់ពេលអាថ្ងៃដែលគេ ទៅស៊ើបអង្កេតនិងសួរខ្ញុំផ្ទាល់ គេយកអាឈ្មោះទាំងអស់នេះ គេសួរថាខ្ញុំស្គាល់ក៏អត់? ខ្ញុំថា ចុះនៅជាមួយគ្នារាប់តាំងពីសម័យជាមួយអ៊ីគ្នាយើងនេះ មកដល់សព្វថ្ងៃនេះ ខ្ញុំថាខ្ញុំស្គាល់ ខ្ញុំថាឈ្មោះនេះខ្ញុំស្គាល់។ ប៉ុន្តែគេយកមកឲ្យខ្ញុំមើល គ្រាន់តែឲ្យខ្ញុំ សួរថាស្គាល់ក៏អត់? ខ្ញុំថាឈ្មោះនេះ ខ្ញុំស្គាល់។ ឲ្យខ្ញុំនិយាយមុន ខ្ញុំអត់បាន

និយាយទេ គ្រាន់តែសួរ គេយកមកឲ្យខ្ញុំពិនិត្យមើលណ៎ា ថាបាត់ខ្លួនហ្នឹងវា ឈ្មោះហ្នឹងវាបាត់មែនក៏អត់ ខ្ញុំថាហ្នឹងហើយ។

**ស៖** ចាស អរគុណៗ។ ពាក់ព័ន្ធនឹងការបាត់ខ្លួននេះដដែល លោកអាចបញ្ជាក់បានទេថា ឲ្យមនុស្សហ្នឹងសុខៗនៅក្នុងភូមិ នៅក្នុងតំបន់ភូមិភាគជាមួយគ្នាហ្នឹង មកនៅសុខៗគាត់បាត់ខ្លួនហ្នឹង មានន័យថាម៉េច?

**ឆ៖** នៅសុខៗបាត់ខ្លួននេះ មានតែៗគេចាប់។

**ស៖** ហើយប្រសិនបើគេចាប់ហ្នឹង តើគេចាប់បញ្ជូនទៅកន្លែងណា? ហើយអ្នកណាជាអ្នកសម្រេចរឿងចាប់ខ្លួនហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

[១៣:៥០:៥៦]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់សំណួរនេះ ដោយសារជាសំណួរប្រភេទឧបមានវិធីឲ្យសាក្សីឆ្លើយទានស្មានៗ ដោយប្រើពាក្យថា “ប្រសិនបើ”។ បាទ សូមអរគុណ។

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយចង់បញ្ជាក់ថានៅក្នុងករណីនេះ លោកសាក្សីបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតហើយៗនៅក្នុងចម្លើយរបស់លោក ហើយខ្ញុំគ្រាន់តែចង់សួរបញ្ជាក់ថា តើប្រសិនបើមានមនុស្សបាត់ខ្លួនអ៊ីចឹង គេយកមនុស្សហ្នឹងទៅណា? គាត់ថា គេបានចាប់ខ្លួន។ អ៊ីចឹងចម្លើយទាំងអស់នេះ គឺវាមានពាក់ព័ន្ធគ្នា ហើយបានបញ្ជាក់រួចជាស្រេច។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកសាក្សី មុននេះ លោកបានប្រាប់ថា នៅពេលដែលអ្នកស៊ើបអង្កេតសួរលោកថា លោកស្គាល់អ្នកណាដែលត្រូវគេចាប់ខ្លួន ឬបានបាត់ខ្លួនហ្នឹងទេ? លោកថាលោកបានស្គាល់ឈ្មោះហ្នឹង។ ស្គាល់ឈ្មោះហ្នឹង តើលោកអាចរៀបរាប់ពីរបីឈ្មោះ ថាតើពួកគាត់មានតួនាទី ឬឋានៈអ្វី? ឲ្យបានពីរបីឈ្មោះក៏បានដែរ។

[១៣:៥២:១៤]

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាអាចបញ្ជាក់បានទេអំពីកាលបរិច្ឆេទនៃការបាត់ខ្លួន។ ក្រែងលោមានការភ័ន្តច្រឡំ ក្រៅវិសាលភាពនៃអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការសម្រាប់សំណុំរឿង ០០២/០១ ពីព្រោះការសួរមកនេះ ហាក់ដូចជាមិនបានបង្ហាញអំពីកាលបរិច្ឆេទពាក់ព័ន្ធជាមួយអង្គហេតុដែលសួរនេះទេ។ សូមឲ្យចូលទៅក្នុងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការសម្រាប់សំណុំរឿង០០២/០១។ ទាំងអង្គហេតុ ទាំងកាលបរិច្ឆេទ ពាក់ព័ន្ធទៅនឹងការជម្លៀសដំណាក់កាលទី១ និងដំណាក់កាលទី២។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន ដែលបានរំឭកពីបញ្ហានេះ។ ជាក់ស្ដែងសាក្សី សួន កានិល នេះគាត់បានឡើង-- បានសួរពីព្រឹកហើយថា គាត់ចាប់ផ្ដើមធ្វើជាអ្នកវាយទូរសារ គាត់ធ្វើការនៅមន្ទីរទូរសារហ្នឹងតាំងពីពេលណា ហើយអ៊ីចឹងវាស្ថិតនៅក្នុងដែលយុត្តាធិការ។ ហើយម្យ៉ាងទៀតសហព្រះរាជអាជ្ញាកំពុងតែសួរនាំគាត់ពាក់ព័ន្ធទៅនឹងទំនាក់ទំនងដែលបានធ្វើឡើងនៅក្នុងអំឡុងឆ្នាំ១៩៧៥។ ហើយការបាត់ខ្លួននេះ ជាក់ស្ដែងគឺវាស្ថិតនៅក្នុងអំឡុងឆ្នាំ១៩៧៥ រហូតដល់អំឡុងឆ្នាំ១៩៧៩។

[១៣:៥៣:៤៥]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងហើយបានជាអង្គជំនុំជម្រះរំឭកកុំឲ្យលោកតំណាងសហព្រះរាជអាជ្ញាជាតិហ្នឹង គឺធ្វើការកំណត់ឲ្យបានច្បាស់លាស់អំពីកាលបរិច្ឆេទពាក់ព័ន្ធនឹងអង្គហេតុនៃការបាត់ខ្លួន ថាវាតើវាពេលណា? ប្រសិនបើវាចាកចេញឆ្ងាយពីវិសាលភាពនៃអង្គហេតុដែលអង្គជំនុំជម្រះ កំណត់ធ្វើសវនាការក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះមិនអនុញ្ញាតទេ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោក សួន កានិល ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិចទាក់ទងទៅនឹងកាលបរិច្ឆេទនៃការបាត់ខ្លួនលោកដឹងថាមានមនុស្សបាត់ខ្លួនហ្នឹងបន្ទាប់ពីឆ្នាំ អំឡុងឆ្នាំ១៩៧៥ គឺ១៧ មេសា ហើយដល់៧៩ ហ្នឹង តើមនុស្សដែលបាត់ខ្លួននៅក្នុងអំឡុងពេលហ្នឹង មានប្រហែលជាប៉ុន្មាននាក់? ហើយសូមលោកលើក

ឧទាហរណ៍ឲ្យបានបួនប្រាំនាក់ ប្រសិនបើអាច ពីតួនាទី និងភារកិច្ចរបស់គាត់ផង។

[១៣:៥៤:៥១]

**លោក សួន កានិល៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ បញ្ហាបាត់ខ្លួននេះ ខ្ញុំដឹងដែរ ដឹងតែនៅហៅថានៅៗជុំវិញដែលកន្លែងខ្ញុំរស់នៅ។ ព្រោះនៅតាមតំបន់តាមអី ខ្ញុំអត់ដឹងទេ។ ខ្ញុំចង់លើកឈ្មោះដែលខ្ញុំស្គាល់ គឺមួយគឺថាឈ្មោះ ដូចជាឈ្មោះ ភោគ។ ភោគ ហ្នឹងជាប្រធានសន្តិសុខហ្នឹងដែរ ដល់ក្រោយមកបាត់ខ្លួន។ ក្រោយមក -- ប៉ុន្តែថ្ងៃខែខ្ញុំវាៗភ្លេចទៅ ប៉ុន្តែក្រោយមកឡើងឈ្មោះ អ៊ឹម មួយទៀត ប្រធានសន្តិសុខដែរ។ ឡើងទៅបាត់ខ្លួនទៀត។ បានក្រោយមកនៅក្នុងអាកន្លែងមន្ទីរហៅថា ទទួលភ្ញៀវ ៗក៏បាត់ខ្លួនដែរឈ្មោះ ឡី បាត់ទៅ។ ដល់បន្តិចទៀតមក បាត់ឈ្មោះ ឡី ឃើញបាត់ឈ្មោះ គុន ហ្នឹងទៀត។ ហើយក្រោយមកទៀតក៏ឃើញបាត់ឈ្មោះ ខាងដែល នៅខាងភ័ស្តុភារកងពល ដល់វាផ្ទុះអាគ្រាប់បែកហ្នឹងទៅ ក៏បាត់ខ្លួន។ ហ្នឹងខ្ញុំដឹងតែអ៊ីចឹងជំនាន់នុ៎ង ថាបាត់ខ្លួនអ៊ីចឹង។ បួនប្រាំនាក់ប៉ុណ្ណឹង។

**ស៖** ចាស សូមអរគុណ។ ពាក់ព័ន្ធនឹងបញ្ហាបាត់ខ្លួននៅអំឡុងកម្ពុជាប្រជាធិបតេយ្យនេះដែរ នៅពេលដែលអ្នកស៊ើបអង្កេតសួរលោកនៅត្រង់ឯកសារ E3/411 ជាភាសាខ្មែរ ERN គឺ 00373516, ជាភាសាអង់គ្លេស 00390082, ជាភាសាបារាំង 00424043។ នៅពេលដែលអ្នកស៊ើបអង្កេតសួរលោកថា "អ្នកណាជាអ្នកសម្រេចថាមនុស្សណាមួយត្រូវចាប់ខ្លួននោះ?" ពេលនោះលោកបានឆ្លើយប្រាប់ថា "អ្នកដែលត្រូវចាប់ខ្លួននៅភូមិភាគកណ្តាលទាំងអស់គឺត្រូវសម្រេចដោយមជ្ឈិម"។ ខ្ញុំចង់សួរលោកបញ្ជាក់ថា តើលោកនៅរក្សាចម្លើយនេះដដែលឬទេ?

[១៣:៥៧:២៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ជាថ្មីម្តងទៀត ខ្ញុំសូមជំទាស់ចំពោះសួរនេះ ដោយសារវាចាកចេញពីវិសាលភាពនៃសវនាការសំណុំរឿង ០០១/០១ (ស៊ុក) នេះ។ បើ -- លើកលែងតែតំណាងសហព្រះរាជអាជ្ញាបញ្ជាក់ពីពេលវេលាជាក់ស្តែងថា វាជាប់ពាក់ព័ន្ធទៅនឹងការជម្លៀសលើកទី១ ឬលើកទី២

នោះបាទ។ សូមអរគុណ។

**កញ្ញា សុង ឆវ័ន្ត៖**

សូមឆ្លើយតបដោយសង្ខេបជាមួយនឹងការជំទាស់របស់មេធាវី។ ជាស្តែងសំណួរនេះ ត្រូវបានសួរជាច្រើនលើកច្រើនសាមកហើយដោយភាគីដទៃនៅក្នុងរឿងក្តីនេះ ហើយសំណួរនេះគឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការប្រាស្រ័យទាក់ទង ឬការធ្វើទំនាក់ទំនងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើមនុស្សម្នាក់ៗនៅក្នុងតួនាទីរបស់គាត់ហ្នឹង គាត់ទំនាក់ទំនងគ្នាយ៉ាងម៉េច? ហើយគាត់ដឹងអំពីបញ្ហានៃការបាត់ខ្លួនហ្នឹងយ៉ាងដូចម្តេច? ហេតុដូច្នេះ ខ្ញុំគិតថាសំណួរនេះ គឺវាបានស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះនៃតុលាការមួយនេះ។

[១៣:៥៨:៥១]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០០:៣៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាជាតិ!

លោកស្រីអាចពន្យល់អង្គជំនុំជម្រះបានទេ អំពីភាពពាក់ព័ន្ធនៃសំណួររបស់លោកស្រីទៅនឹងសំណុំរឿង០០២/០១។ លោកស្រីកុំច្រឡំថា នៅក្នុងវិសាលភាពនៃអង្គហេតុក្នុងសំណុំរឿង០០២ ឬក៏យុត្តាធិការ អ.វ.ត.ក អី ព្រោះអង្គជំនុំជម្រះបានបំបែកសំណុំរឿងក្តីនេះមកធ្វើសវនាការ គឺជាសំណុំរឿង ០០២/០១។

ពន្យល់បានទេ ដើម្បីឲ្យមានការសម្រេចច្បាស់លាស់ពីបញ្ហានេះ ពីព្រោះយើងបានរំឭកច្រើនលើក ច្រើនសាហើយ ហើយនៅតែហាក់ដូចជានៅតែដដែល អត់មានអីដែលមានការផ្លាស់ប្តូរទេ។

[១៤:០១:២៨]

**លោក ឃីត រេយ៉ន័រ៖**

សូមអរគុណលោកប្រធាន និងលោក លោកស្រីចៅក្រម។ ខ្ញុំគិតថា ចាំបាច់ត្រូវបញ្ជាក់បំភ្លឺនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ លោក លោកស្រីចៅក្រមស្តាប់អំពីសក្ខីកម្មពាក់ព័ន្ធទៅនឹងអំណាចគ្រប់គ្រង អ្នកណាជាអ្នកបញ្ជា? នៅពេលណា? មានភស្តុតាងជាច្រើនពាក់ព័ន្ធទៅនឹងប្រព័ន្ធទាក់ទង។ ភស្តុតាងគឺថាវាស្ថិតនៅក្នុងប្រភេទតែមួយ។ ភស្តុតាងដែលបង្ហាញអំពីរចនាសម្ព័ន្ធគ្រប់គ្រង ដែលវាជា

គោលការណ៍ពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១។ ប្រព័ន្ធទំនាក់ទំនង គឺជាចំណុចគោលការណ៍មួយផងដែរ ដែលស្ថិតនៅក្នុងសំណុំរឿងនេះ។ ខ្ញុំសូមលើកឧទាហរណ៍ជូនអង្គជំនុំជម្រះ យើងឃើញថាមានឯកសារបង្ហាញអំពីប្រព័ន្ធទាក់ទងគ្របដណ្តប់លើសម័យនោះតែម្តង មិនត្រឹមតែឆ្នាំ៧៥, ៧៦, ៧៧ នោះទេ។ សំណួរជាច្រើនបានសួរក្នុងពេលជំនុំជម្រះនេះ ជាពិសេសការចាប់ខ្លួនដែលបញ្ជូលទៅក្នុង ស-២១។ សំណួរទាំងអស់នេះ គឺថាសហព្រះរាជអាជ្ញាបានសួរ។ ចៅក្រម ឡាវែន៍ ជាឧទាហរណ៍បានសួរអំពីបញ្ហាសារទូរលេខទៅដល់សាក្សី ជាពិសេសសាក្សី នង សុផង់។ នៅក្នុងនោះបានបង្ហាញសារទូរលេខជាច្រើនចាប់ពីឆ្នាំ៧៧ ដល់ ឆ្នាំ៧៨។ ដូច្នេះគោលបំណង -- នេះគឺជាគោលបំណងមួយស្របច្បាប់ ដែលយើងអាចសួរអំពីរចនាសម្ព័ន្ធគ្រប់គ្រង និងប្រព័ន្ធទំនាក់ទំនង។

ដូច្នេះ យើងខ្ញុំសូមលើកឡើងដោយគោរពថា របៀបតាំងសួរសំណួរនេះ គឺមានលក្ខណៈសមស្របទាំងស្រុងតែម្តង។

[១៤:០៣:១៦]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។

សូមអរគុណ។ ខ្ញុំសូមលើកឡើងថា ខ្ញុំមិនលើកឡើងជាបញ្ហាទូទៅនោះទេ ក៏ប៉ុន្តែការធ្វើសេចក្តីសន្និដ្ឋានរបស់គាត់នេះ គឺថាតើយើងអាចទទួលយកនូវការប្រឌិតនេះបានដែរឬទេនៅក្នុងវិសាលភាពសំណុំរឿង០០២/០១។ នេះជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំ។ គោលការណ៍ ឬក៏អ្វីដែលគាត់ហៅថា បញ្ហាពាក់ព័ន្ធសំខាន់នេះ គឺវាពង្រីកទៅលើវិសាលភាពពេលវេលាទូលំទូលាយពេក មិនស្ថិតនៅក្នុងក្របខ័ណ្ឌសំណុំរឿង០០២/០១ របស់យើងនោះទេ។ វាជាការប្រឌិតរបស់គាត់តែប៉ុណ្ណោះ។ លោក ខេលី បានលើកឡើងហើយថា ក្រៅពីសំណុំរឿងទៅ គឺគ្មានអ្វីទេ សំណុំរឿងណាមួយដែលត្រូវយកមកជំនុំជម្រះនោះឡើយ។

[១៤:០៤:១២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៤:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញតតាំងសំណួរ!

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោក សួន កានិល ខ្ញុំនឹងសួរសំណួរចុងក្រោយទៅលោកម្តងទៀត។ នៅពេលដែលអ្នកស៊ើបអង្កេតបានសួរលោកថា អ្នកណាជាអ្នកសម្រេចថា មនុស្សមួយណាត្រូវចាប់ខ្លួននោះ? លោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា អ្នកដែលត្រូវចាប់ខ្លួននៅភូមិភាគកណ្តាលទាំងអស់ គឺត្រូវសម្រេចដោយមជ្ឈិម។ ហើយលោកបានឆ្លើយថា លោករក្សាចម្លើយនោះនៅដដែល។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា ការសម្រេចចាប់ខ្លួននៅភូមិភាគកណ្តាលទាំងអស់ហ្នឹង តើមានករណីលើកលែងទេថាអត់មានសម្រេចដោយមជ្ឈិម?

**លោក សួន កានិល៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ ក្នុងការចាប់ខ្លួននេះ គឺធម្មតាខាងខ្ញុំនៅធ្វើការក្នុងសារទូរលេខ ពេលដែលមានហៅថា ពេលខ្លះក៏គេឲ្យខ្ញុំទៅផែក ជួយមើលសំណុំរឿងហ្នឹង។ សំណុំរឿងហ្នឹងធម្មតានៅក្នុងមន្ទីរលោក កែ ពក គាត់បានមានប្រសាសន៍ថា "ពីព្រោះថាការចាប់ខ្លួនហ្នឹង ដូចជាគណៈតំបន់ ឬគណៈអីហ្នឹង គាត់ថាទាល់តែមានសំណុំរឿងបានគាត់ចាប់ បើអត់មានសំណុំរឿងគាត់អត់ចាប់ទេ" គាត់ៗនិយាយអ៊ីចឹងតែម្តង។ ហើយសួរថា តើគាត់មានសម្រេចថា ឲ្យលែងមនុស្សនុ៎ងបានឬអត់? គាត់ថាៗបើត្រឹមក្នុងភូមិភាគដែលគាត់មើលការខុសត្រូវ គាត់ថា គាត់អាចធានាខុសត្រូវ។ ដូចអ៊ីចឹងគាត់ ដូចវាមានពីរបញ្ហា។ បញ្ហាមួយ គឺទាក់ទងនឹងឪពុកក្មេកខ្ញុំផ្ទាល់ កាលហ្នឹងខ្ញុំមិនទាន់រៀបការទេ។ ដល់ពេលហ្នឹងទៅគេរាយការណ៍មកថា "ឪពុកក្មេកអ្នកឯងត្រូវគេចាប់ខ្លួនហើយ យកទៅហ្នឹង"។ ដល់ពេលខាងគាត់ គាត់សួរមកៗអ្នកចាប់ហ្នឹងថា "តើចាប់ៗខ្លួនគេនោះរឿងអី?" គេថា "គ្រាន់តែរឿងបន្តិចបន្តួចគាត់ធ្វើឈ្លប" បានគាត់ថា "គ្រាន់តែធ្វើឈ្លបប៉ុណ្ណឹងឯង ក៏ចាប់ខ្លួនគេដែរ? មិនមានទៅកំហុសអី" ទៅក៏គាត់ប្រាប់ទៅក៏គាត់បញ្ជាឲ្យខាងលេខាតំបន់មកដោះភ្លាម ពេលដែលយកមកដាក់នៅសាលាស្រុកស្ទោងអារឿងៗហ្នឹង។ អាហ្នឹងវារឿងហ្នឹង វាៗជាក់ស្តែងអ៊ីចឹង ប៉ុន្តែថ្ងៃខែខ្ញុំភ្លេចហើយ។

[១៤:០៧:៣៨]

បាទ រឿងមួយទៀត ស្រាប់តែមិនបាន ប្រហែលជា៥ថ្ងៃ នៅខាងកំពង់ចាមហ្នឹងមានប្អូនថ្លៃខ្ញុំមួយទៀត។ ដល់អ៊ីចឹងទៅក៏ ស្រាប់តែម៉ែចៗឃើញយំពព្រៀកមកប្រាប់ខ្ញុំថា " អ្ហឺ! គេចាប់ប្តីខ្ញុំបាត់"

ខ្ញុំសួរថា "ចាប់រឿងអី?" គេថា "អ្ហឺ! អត់ដឹងដែរ"។ ដល់ពេលអ៊ីចឹងទៅ ខ្ញុំទៅ ពេលណាខ្ញុំយកអាសារទូរលេខទៅឲ្យគាត់ ខ្ញុំៗក៏សួរគាត់។ បានន័យថា ដូចថាខ្ញុំហ្នឹងដូចឪពុកនិងកូនអ៊ីចឹង ខ្ញុំចេះតែសួរ "ម៉េចបានគេចាប់ហ្នឹង?" គាត់ៗឆ្លើយមកថា "យី! អញអត់ដឹងដែរ"។ អ៊ីចឹងអ្នែងទៅហៅប្រធានសន្តិសុខមក។ ខ្ញុំក៏ -- ប្រធានសន្តិសុខហ្នឹង ខ្ញុំស្គាល់ដែរ។ ខ្ញុំថា "យី! អ្នែងចាប់មនុស្សអត់មានច្បាប់ទម្លាប់ អ្នែងចាប់មកដែរ"។ ខ្ញុំថាឥឡូវបងហៅឲ្យទៅហើយ។ ដល់ទៅដល់ទៅ ពួកគាត់អាងតែស្គាល់គ្នា ក៏គាត់ជេរតែម្តង "អ្នែងគ្រាន់តែប៉ុណ្ណឹងៗ ក៏ចាប់គេមកដែរ" ទៅគេដោះលែង ដោះលែងបានពីរនាក់ហ្នឹង។ បើក្រៅពីហ្នឹងខ្ញុំអត់ៗដឹងដែរ បើការដោះលែង គឺមានៗពីរនាក់ហ្នឹង។ នេះនៅក្នុងភូមិភាគ បើថាមានៗមកពីលើគឺអត់ទេ គាត់ថាអ៊ីចឹង។ សូម្បីតែប្អូនថ្លៃក៏ដោយ គឺត្រូវតែចាប់ បើសិនមានមកពីខាងលើ។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវទេមានន័យថា ប្រសិនបើមានបញ្ជាមកពីថ្នាក់លើ អ៊ីចឹងដាច់ខាតត្រូវតែចាប់តែម្តង?

**ឆ៖** បាទ បញ្ហាហ្នឹងជាការត្រឹមត្រូវ។ បើមានបញ្ជាមកថ្នាក់លើសូម្បីតែប្តី និងប្រពន្ធ ឬក៏ប្អូនថ្លៃ បងថ្លៃក៏ត្រូវតែចាប់ ឲ្យតែមានចម្លើយមកពីលើត្រូវតែចាប់។

[១៤:០៩:២៣]

**ស៖** ចង់ឲ្យលោកបញ្ជាក់ពេលវេលាបន្តិចថា លោកដឹងថាមានការចាប់ខ្លួនហ្នឹងនៅក្នុងឆ្នាំណាតាមដែលបានដឹងផ្ទាល់?

**ឆ៖** តាមខ្ញុំដឹងគឺថាវាវឹកវរ នៅឆ្នាំប្រហែលឆ្នាំចុងឆ្នាំ៧៧ ចូលដើម៧៨។

**ស៖** តើនៅក្នុងករណីដែលមានការចាប់ខ្លួនហើយ តើ កែ ពក ត្រូវរាយការណ៍ឲ្យថ្នាក់លើរបស់គាត់ទៀតទេ?

**ឆ៖** សូមសួរម្តងទៀត។

**ស៖** ជាក់ស្តែងនៅពេលដែលមានបញ្ជាពីថ្នាក់លើមកមានការចាប់ខ្លួន។ ដល់ពេលចាប់ខ្លួនបានហើយតើ កែ ពក ត្រូវរាយការណ៍ឲ្យថ្នាក់របស់គាត់គឺមជ្ឈិមវិញអត់ទេ?

**ឆ៖** កាលណាចាប់ខ្លួនហើយគឺថា មានៗហៅថា ដូចថាឯកសារគេយកមកហើយ គេចាប់ហើយ គឺគេដាក់ឡានយកទៅភ្នំពេញ អត់មានមកគាត់ទៀតទេ។

[១៤:១០:៥៥]

**ស៖** ចាស សូមអរគុណ។ ឆ្លងចូលដល់ទៅបញ្ហាមួយទៀតគឺហៅឲ្យទៅរៀនសូត្រ។ ការបញ្ជូន

មនុស្សឲ្យទៅរៀនសូត្រ ឬហៅមនុស្សឲ្យទៅរៀនសូត្រហ្នឹង លោកដឹងទេតើមានន័យថាយ៉ាងដូចម្ដេចដែរ?

**ឆ៖** ការហៅឲ្យមនុស្សទៅរៀនសូត្រ ហើយបាត់ខ្លួនអីចឹង ឬក៏ម៉េច? គឺការបាត់គេមាន ដែលខ្ញុំដឹងហ្នឹងគឺថាមានតែពីរ មួយគឺថាហៅទៅរៀនសូត្រ មួយគឺថាហៅឲ្យទៅផ្លាស់ប្ដូរទីកន្លែង។

**សៈ** តើវាខុសគ្នារបៀបម៉េច រឿងហៅឲ្យទៅរៀនសូត្រ ហើយហៅឲ្យផ្លាស់ប្ដូរទីកន្លែងនោះ សូមលោកជួយពន្យល់ឲ្យបានលម្អិតលើបញ្ហានេះ?

[១៤:១១:៤៥]

**ឆ៖** ដែលគេហៅទៅរៀនសូត្រ ប៉ុន្តែក្នុងការរៀនសូត្រហ្នឹងគេ បើមិនហៅទៅរៀនសូត្រ បើប្រាប់ថាហៅទៅចាប់ខ្លួន គឺមនុស្សមិនទៅទេ។ អាហ្នឹងហៅទៅរៀនសូត្រមនុស្សចេះតែទៅហើយ។ ហើយបើថា អូ! ផ្លាស់ទីកន្លែង បើគេថា អូ! ផ្លាស់អ្នកឯង ឥឡូវគេឲ្យទៅនៅសហករណ៍ហើយ។ ដូច្នេះនេះទៅ ដល់ពេលនេះក៏គេចាប់ខ្លួនទៅ បញ្ជូនទៅ គេចាប់តាមផ្លូវ ឬគេយកទៅដាក់នៅកន្លែងពន្ធនាគារ។ អាហ្នឹងជាវិធីសាស្ត្រមួយ។

**សៈ** ចុះវិធីសាស្ត្រដែលគេហៅមនុស្សទៅរៀនសូត្រនោះ គឺគេចេញជាលិខិតអញ្ជើញ ឬក៏គេប្រាប់មនុស្សឲ្យមកហៅផ្ទាល់ៗតែម្ដង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញបាទ លោកមេធាវី។

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់សាជាថ្មី ទាក់ទងទៅនឹងសំណួរ ប៉ុន្មានសំណួរចុងក្រោយនេះ ដែលតំណាងសហព្រះរាជអាជ្ញាជាតិលើកអំពីការរៀនសូត្រ ឬក៏ពាក់ព័ន្ធនឹងការចាប់ខ្លួននេះ ហើយដែលចំណុចនេះមិនជាប់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃការធ្វើទំនាក់ទំនងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។ បាទ សូមអរគុណ។

[១៤:១៣:២៨]

**កញ្ញា សុង ឆវន្ត៖**

ចាស លោកប្រធានសូមឆ្លើយតបដោយសង្ខេបថា សំណួរមួយនេះគឺចង់បង្ហាញអំពីទំនាក់ទំនងដែលបានធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ថាតើគេហៅមនុស្សទៅរៀន គេប្រើមធ្យោបាយ

អីដើម្បីហៅមនុស្ស។ អ៊ីចឹងសំណួរនេះវាប្រាកដជាស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការមួយនេះ។ សូមលោកប្រធានអនុញ្ញាតឲ្យនាងខ្ញុំសួរសំណួរនេះ។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតប! សេចក្ដីជំទាស់មិនសមស្របទេ។

**លោក សួន កានិល៖**

**ឆ៖** ខ្ញុំសូមឆ្លើយបញ្ហានេះ។ បញ្ហាហៅទៅរៀនសូត្រហ្នឹង បើសិនជា -- គេមានហៅពីរ។ គេអញ្ជើញតាមសារទូរលេខ ឬគេអញ្ជើញតាមសំបុត្រ។ វាមានពីរយ៉ាង។ ពីព្រោះថាសម័យរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងគឺថា មនុស្សគឺថាវាបាក់ផ្ទត់ ខ្លាច។ ដូច្នេះតែគេហៅទៅ ត្រូវតែទៅ ព្រោះថា ខ្លួនម្នាក់ៗមិនដឹងជាមានកំហុសអីទេ ដល់ពេលហ្នឹងគឺត្រូវតែទៅ។ ដល់ទៅៗវាមានបញ្ហា ដូចខ្ញុំថាអ៊ីចឹងវាមានឯកសារអីៗមកអ៊ីចឹងក៏--គេអ៊ីចឹង។ ចង់បញ្ជាក់ប៉ុណ្ណឹង។

[១៤:១៥:០០]

**ស៖** លោកថាមានលិខិតអញ្ជើញ គឺតាមរយៈទូរលេខ និងសំបុត្រ។ សួរថាអ្នកណាជាអ្នកចេញទូរលេខ និងសំបុត្រហ្នឹង? ចេញមកពីថ្នាក់ណា?

**ឆ៖** គឺសំបុត្រហ្នឹងចេញពីថ្នាក់ខាងភូមិភាគ។

**ស៖** ចុះទូរលេខ?

**ឆ៖** ទូរលេខក៏ដូចគ្នា។

**ស៖** ចង់ឲ្យលោកបញ្ជាក់បន្តិចថា ទាំងទូរលេខ ទាំងសំបុត្រហ្នឹងមានដែលផ្ញើពីថ្នាក់មជ្ឈិមមកផ្ទាល់ដែរឬទេ?

**ឆ៖** សំបុត្រដែល-- គឺឯកសារមកពីខាងមជ្ឈិម ដូចខ្ញុំបញ្ជាក់ខាងដើមអ៊ីចឹង បើមានបញ្ហាអីឯកសារមកពីខាងមជ្ឈិម ដល់មកដល់ខាងភូមិភាគ ភូមិភាគថា បើមានឈ្មោះនៅក្នុងឯកសារហ្នឹងភូមិភាគអ្នកសរសេរ អ្នកហៅ។ ខាងទូរលេខអ៊ីចឹងដែរ គេឲ្យមកខាងអ្នកបកប្រែទៅ អ្នកបកប្រែយកសំបុត្រមកឲ្យខាងខ្ញុំទៅ។ ខ្ញុំអត់ដឹងទេសំបុត្រនោះ ខ្ញុំជាអ្នកវៃ ខ្ញុំដឹងតែវៃលេខទេ។

[១៤:១៦:៤៤]

**ស៖** ចាស សូមអរគុណ។ នៅក្នុងឯកសារ E3/411 លោកបានឆ្លើយប្រាប់ទៅអ្នកស៊ើបអង្កេតថា នៅត្រង់ ERN ជាភាសាខ្មែរគឺ 00373511 ដល់ 12, ជាភាសាអង់គ្លេស 00390078 និងជាភាសា

បារាំង 00424038។ ដកស្រង់ "ការហៅឲ្យចូលមកចូលរួមប្រជុំនៅទីក្រុងភ្នំពេញ គឺធ្វើឡើងដោយមានមន្ទីរ៨៧០ នៅភ្នំពេញដែលបញ្ជូនតាមរយៈទូរលេខ។ ខ្ញុំដឹងពីបញ្ហានេះតាមរយៈនីរសាររបស់ភូមិភាគ"។ ចង់សួរបញ្ជាក់ថា លោកនៅតែរក្សាចម្លើយដដែលនេះ ឬយ៉ាងណា?

**ផ៖** បញ្ហានេះ ខ្ញុំសូមរក្សានូវចម្លើយដដែល។

**ស៖** ចាស អរគុណ។ អ៊ីចឹង ចង់ឲ្យលោកបញ្ជាក់បន្តិចថា តើនីរសាររបស់ភូមិភាគ ដែលប្រាប់លោកពីបញ្ហានេះ គាត់មានឈ្មោះអ្វី?

**ផ៖** នីរសាររបស់ភូមិភាគនោះ គឺឈ្មោះ ហែម។

**ស៖** តើមានមនុស្សច្រើនទេ ដែលត្រូវគេហៅឲ្យទៅរៀនសូត្រនៅភ្នំពេញ ហៅដោយមន្ទីរ៨៧០ហ្នឹង?

**ផ៖** គឺមិនមានច្រើនទេ។

[១៤:១៨:៣៨]

**ស៖** ប្រសិនបើលោកអាចជួយរៀបរាប់បាន សូមជួយរៀបរាប់ឲ្យបានឈ្មោះពីរបីនាក់ ឬក៏លោកចាំបានចំនួនប៉ុន្មាននាក់ហ្នឹង ហើយតួនាទីរបស់គាត់នោះ សូមជួយលើកឧទាហរណ៍ផង ថាប៉ុន្មាននាក់ដែលទៅភ្នំពេញ ហៅដោយមន្ទីរ៨៧០ហ្នឹង?

**ផ៖** បញ្ហានេះ ខ្ញុំអាចរៀបរាប់បាន ប៉ុន្តែអារឿងរៀបរាប់នេះវាជាគេហៅថា ដោយខ្ញុំឃើញមតិសត្យានុម័តមកខាងក្រោយទេ មកខាងក្រោយដែលគេសួរខ្ញុំ ដែលចុះទៅស៊ើបអង្កេតសួរហ្នឹង ដូចជាឈ្មោះ ស៊ី កងពល១១៧។ គេសួរថា "ស្គាល់ឈ្មោះហ្នឹងទេ? ខ្ញុំថាស្គាល់" គ្រាន់ថា ស្គាល់ ព្រោះគេ គេយកមកគ្រាន់គេបញ្ជាក់ប្រាប់ខ្ញុំថា ស្គាល់ក៏អត់? ខ្ញុំថាខ្ញុំស្គាល់។ ហើយឈ្មោះ វៃ រាប វរសេនាធំទៅមួយទៀត ហើយឈ្មោះ លី គឺភ័ស្តុភារកងពល បី -- បាទ ចាំមិនអស់ទៀតទេប៉ុណ្ណឹង សូមប៉ុណ្ណឹង។

**ស៖** ចាស អរគុណ។ នៅឯកសារដដែល គឺឯកសារ E3/411 ដែលនៅត្រង់ ERN 003715 13, ERN ជាភាសាអង់គ្លេសគឺ 00390072 ដល់ 82, និង ERN ជាភាសាបារាំង 00423039 ដល់ 43។ ខ្ញុំសូមអាន ERN ជាភាសាខ្មែរម្តងទៀត 00373512 ដល់ 16។ នៅក្នុងឯកសារនេះ នៅក្នុងចម្លើយដែលអ្នកស៊ើបអង្កេតបានសួរលោក នៅពេលដែលអ្នកស៊ើបអង្កេតបានបង្ហាញនូវបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខស-២១ ដែលបញ្ជីនោះមាន ERN 00333779 ដល់ 00333795 គឺចាប់ពីទី១ រហូតដល់លេខរៀង ៣៦០ លោកបានប្រាប់អ្នកស៊ើបអង្កេតនូវឈ្មោះមួយចំនួនដែលត្រូវបានចាប់ខ្លួន ឬ

បានបាត់ខ្លួន។ តើលោកនៅរក្សាចម្លើយដដែលឬទេ?

[១៤:២១:២០]

**ឆ៖** ខ្ញុំសូមឆ្លើយ។ គឺខ្ញុំនៅរក្សាចម្លើយដដែល។

**ស៖** ចាស ខ្ញុំនឹងសួរសំណួរចុងក្រោយមួយទៀត នៅពេលដែលអ្នកស៊ើបអង្កេតសួរលោក គឺត្រង់ឯកសារដដែលនេះ ប៉ុន្តែលោកបានរំឭកដល់មានការផ្ទុះគ្រាប់បែកមួយ គឺពេលនោះលោកបានប្រាប់ថាដកស្រង់ "មានហេតុការណ៍ផ្ទុះគ្រាប់បែកធំមួយនៅខេត្តកំពង់ចាម ដែលធ្វើឲ្យផ្ទះមួយចំនួននៅក្បែរកងពលត្រូវបានឆេះខ្មោចខ្មី ហើយកញ្ចក់អគារត្រូវបានបែកបាក់។ បន្ទាប់ពីមានការផ្ទុះបែកនោះ មានមនុស្សមួយចំនួនត្រូវបានចាប់ខ្លួន ក្នុងនោះរួមមានទាំងប្អូនថ្លៃរបស់ កែ ពក ឈ្មោះ ឃុល ឃិន ហៅ យាន"។ ហើយនិងបន្ទាប់មកនៅខាងក្រោមហ្នឹងបន្តិច គឺមានមនុស្សមួយចំនួនទៀតបន្ទាប់ពីការចាប់ខ្លួនឈ្មោះ យាន។ តើលោកនៅរក្សាចម្លើយដដែលហ្នឹងឬទេ?

**ឆ៖** ខ្ញុំនៅរក្សាចម្លើយហ្នឹងដដែល។

[១៤:២២:៣៩]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស អរគុណលោក សួន កានិល។ ខ្ញុំបានបញ្ចប់សំណួររបស់ខ្ញុំ ហើយសហភាតាអន្តរជាតិរបស់ខ្ញុំគឺលោក ឃីត រេយ៉ន័រ គាត់នឹងមានសំណួរមួយចំនួន ដើម្បីបន្តសាកសួររូបលោក។

សូមអរគុណប្រធាន សូមផ្តល់វេទិកាបន្តទៅដល់សហភាតា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងតាំងសំណួរ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ តើអាចប្រាប់អង្គសវនាការបានទេ អំពីការបែងចែកពេលវេលារវាងតំណាងសហព្រះរាជអាជ្ញាជាមួយក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

[១៤:២៣:២៨]

**លោក ឃីត រេយ៉ន័រ៖**

ជាការពិត យើងខ្ញុំអាចជម្រាបបាន យើងបានពិភាក្សាជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី។ ខាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានសំណួរច្រើននោះទេ។ ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា នៅក្នុងព្រឹកនេះតំណាងសហព្រះរាជអាជ្ញានោះ គឺចាប់ផ្តើមនៅម៉ោងដប់មួយដប់នាទី ហើយតំណាងសហព្រះរាជអាជ្ញា

គឺថានឹងមានរយៈពេលសួរ១ថ្ងៃ។ ដូច្នេះ ខ្ញុំមានសំណួរត្រូវការសួរទៅកាន់សាក្សី ហើយយើងខ្ញុំត្រូវការរហូតទៅដល់ថ្ងៃចន្ទ ដើម្បីសួរសំណួរសាក្សីនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះកំណត់ជូនថា ថ្ងៃចន្ទ តែមួយពេលទេ គឺពីព្រឹករហូតដល់សម្រាកប៉ុណ្ណោះ ទាំងពីរភាគី។

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំសូមថ្លែងអំណរគុណ។ ខ្ញុំគិតថាពេលវេលាផ្តល់ជូននេះ គឺគ្រប់គ្រាន់ហើយ។

[១៤:២៤:៣៦]

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោកសាក្សី ខ្ញុំឈ្មោះ ឃីត រេយ៍ន័រ ខ្ញុំគឺជាតំណាងសហព្រះរាជអាជ្ញាអន្តរជាតិមួយរូបនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា។ សួស្តីលោកសាក្សី។ ខ្ញុំសូមសួរសំណួរមួយចំនួនឲ្យលោកឆ្លើយបញ្ជាក់អំពីមធ្យោបាយក្នុងការធ្វើទំនាក់ទំនង ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លេខ ERN ដែលពាក់ព័ន្ធអង់គ្លេសគឺលេខ 00384433, បារាំងមានលេខ ERN 00426154, ខ្មែរគឺ 00373503។ នៅពេលដែលគេសួរលោកអំពីប្រព័ន្ធទាក់ទង អំពីការចាប់ខ្លួននោះ គឺថាលោកបាននិយាយដូចតទៅ ខ្ញុំសូមដកស្រង់សម្តី "ប្រព័ន្ធទំនាក់ទំនងពាក់ព័ន្ធទៅនឹងការចាប់ខ្លួន គឺមិនមែនធ្វើឡើងតាមរយៈសារទូរលេខនោះទេ ក៏ប៉ុន្តែតាមរយៈសារលិខិត ៗសំបុត្របញ្ជូនតាមនីរសារ ប្រសិនបើមានការចាប់ខ្លួននៅក្នុងភូមិភាគ គឺខ្ញុំនឹងដឹងអំពីការចាប់ខ្លួននេះ"។ តើចំណុចដែលលោករៀបរាប់ដូច្នេះនេះ គឺត្រឹមត្រូវដែរឬទេ?

**លោក សួន កានិល៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ ចំណុចដែលខ្ញុំរៀបរាប់ហ្នឹង គឺខ្ញុំសូមរក្សានៅដដែល ប៉ុន្តែគ្រាន់តែ បើឲ្យខ្ញុំបញ្ជាក់អាហ្នឹងក៏ខ្ញុំបញ្ជាក់ថែម។ ខ្ញុំសូមបញ្ជាក់ថែម កាលដែលហៅថា ធ្វើតាមសំបុត្រ ឬតាមនីរសារហ្នឹងគឺថា ដែលមកពីខាង -- សូមម្តងទៀតទៅ អត់ច្បាស់។

[១៤:២៦:៥៨]

**ស៖** ខ្ញុំនឹងបំបែកសំណួរដែលខ្ញុំសួរនេះឲ្យដាច់ចេញពីគ្នា។ សូមដកស្រង់សម្តីលោកដែលលោកបានឆ្លើយ "ប្រសិនបើគេធ្វើការចាប់ខ្លួននៅក្នុងភូមិភាគ គឺខ្ញុំនឹងដឹងអំពីការចាប់ខ្លួននោះ"។ តើធ្វើម៉េច

លោកដឹងទៅ? ប្រសិនបើមានការចាប់ខ្លួននៅក្នុងភូមិភាគរបស់លោកនោះ លោកដឹងដោយរបៀបណាដែរ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ គឺខ្ញុំដឹងតាមរយៈនីរសាររបស់ភូមិភាគ ពីព្រោះនីរសាររបស់ភូមិភាគ និងកន្លែងទូរលេខនេះវានៅជាមួយគ្នា។ ដូច្នេះការងារអី គឺអាចនីរសារហ្នឹងវាអាចទាក់ទឹងមកខាងខ្ញុំ ថា "អ្ហ៎! ស្អែកគេឲ្យទៅភ្នំពេញទៀតហើយ" ដឹងរបៀបអ៊ីចឹង។ តែទៅភ្នំពេញ គឺវាមានបញ្ហាហ្នឹង។ គឺខ្ញុំដឹងដោយសារអ៊ីចឹង ឬក៏នីរសារមកលេងទៅ វាប្រាប់អ៊ីចឹង។ ព្រោះខ្ញុំមិនអ្នកដេញដោលអីទេ ព្រោះខ្ញុំរវល់ការងារខាងផ្នែកទាក់ទង។

**ស៖** យើងនឹងនិយាយអំពីការចាប់ខ្លួន និងកាលៈទេសៈជាក់លាក់ដែលលោកបានឆ្លើយប្រាប់ ហើយមានការកត់ត្រានៅក្នុងកំណត់ហេតុរបស់លោក។ លោកបានរៀបរាប់ៗ អំពីមន្ទីរសន្តិសុខមជ្ឈិមនៅក្នុងខេត្តកំពង់ចាម នៅពេលដែលលោកបានឮអ្នកយាមមកពីមជ្ឈិមនោះ មកមន្ទីរសន្តិសុខនោះ ដើម្បីមកធ្វើការចាប់ខ្លួនទៅលើបុគ្គលម្នាក់ឈ្មោះ អ៊ុម តើលោកអាចជម្រាបបានដែរឬទេ? តើលោកដឹងអ្វីខ្លះអំពីមន្ទីរសន្តិសុខនេះ?

[១៤:២៩:១៩]

**ឆ៖** បញ្ហានេះ គឺខាងខ្ញុំហ្នឹងគឺបានៗដឹងដែរ បញ្ហាឈ្មោះ អ៊ុម ហ្នឹងគឺថា ជាប្រធានសន្តិសុខចុងក្រោយបង្អស់នៅក្នុងហៅថា ខេត្តកំពង់ចាម។ ពេលនុ៎ងគឺខាងមជ្ឈិមជិតមានគោលការសន្តោសហើយ គេហៅថាមានគោការណ៍សន្តោស គឺឈប់ឲ្យនេះហើយ ដល់អ៊ីចឹងទៅដល់ពេលខាងមជ្ឈិមគេមកឆែកៗ មើលអ្នកទោសនៅខាងកំពង់ចាមហ្នឹង ដល់មកឆែក គេឆែករួចហើយដល់ពេលឈ្មោះ អ៊ុម ហ្នឹងដល់គេឆែកឡើងមើលហើយគាត់ចុះទៅ គាត់ប្រធានសន្តិសុខ ចុះទៅដល់ពេលខាងសន្តិសុខមជ្ឈិមគេឃើញគេថា ឈ្មោះ អ៊ុម នេះឃុបឃិតជាមួយដែលហៅថាអ្នកទោស។ ដល់អ៊ីចឹងទៅគេ ពួកហ្នឹងគេទៅរាយការណ៍ឲ្យ កែ ពក។ ដល់ កែ ពក ព្រោះគេខាងមជ្ឈិមហើយ គាត់ខ្លាចដែរ។ ដល់គាត់ខ្លាចទៅក៏គាត់សម្រេចឲ្យចាប់ឈ្មោះ អ៊ុម នេះទៅ។ គាត់សម្រេច គាត់អ្នកសម្រេចឲ្យ។ ពីព្រោះខាងមជ្ឈិមគេមកហើយ គាត់ខ្លាចមជ្ឈិមដែរ។ ថ្នាក់គាត់តូចជាង។ បាទ ខ្ញុំចង់បញ្ជាក់ប៉ុណ្ណឹងទេ មកពី--។

**ស៖** ពាក់ព័ន្ធទៅនឹងបញ្ហាចាប់ខ្លួននេះ តើការចាប់ខ្លួននេះកើតឡើងញឹកញាប់ប៉ុនណា? តើកម្មាភិបាលមកពីមជ្ឈិមនេះ មកមន្ទីរសន្តិសុខនៅក្នុងភូមិភាគរបស់លោកនេះញឹកញាប់ប៉ុនណាដែរ?

[១៤:៣១:១៦]

**ឆ៖** ខ្ញុំសូមឆ្លើយ គឺបញ្ហាដែលកើតឡើងថាចាប់ខ្លួនហ្នឹង គឺមាននៅចុង ហៅថានាទីចុងក្រោយហើយ ដែលជានាទីចុងក្រោយបំផុតនៃរបបខ្មែរក្រហម -- របបកម្ពុជាប្រជាធិបតេយ្យនោះ ដែលខ្ញុំដឹង។ វាជានាទីចុងក្រោយបំផុត មិនសូវមានញឹកញាប់ទេ ទើបតែ -- និយាយរួមដែលខាងខ្ញុំដឹងហ្នឹង ខ្ញុំដឹងតែម្ដងហ្នឹងបាទ។

**ស៖** លោកសាក្សីខ្ញុំចង់សូមសួរលោកអំពីសារទូរលេខ។ លោកបានជម្រាបរួចហើយថា មជ្ឈិមគឺនៅដាក់ខាងលើគេបំផុត បន្ទាប់មកគឺមានភូមិភាគ ចុះមកគឺមានភូមិភាគ ចុះមកទៀតតំបន់ ចុះមកទៀតស្រុក។ នៅក្នុងកំណត់ហេតុដែលលោកបានផ្ដល់ជូនអ្នកស៊ើបអង្កេត ERN ជាភាសាអង់គ្លេសគឺ 00384429, បារាំង ERN គឺមានលេខ 00426148, ខ្មែរគឺមានលេខ 00373498 លោកបានឆ្លើយដូចតទៅថា "សារទូរលេខនីមួយៗ ជាទូទៅរៀបរាប់អំពីស្ថានភាពរបស់មន្ទីរនីមួយៗ ដែលត្រូវបញ្ជូនសារទូរលេខទៅតាមទីតាំងរៀងៗខ្លួន"។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** សំណួរនេះ ខ្ញុំមិនៗយល់។ សូមម្ដងទៀត។

[១៤:៣៣:៤៨]

**ស៖** គឺមានសារទូរលេខបញ្ជូនពីកន្លែងមួយទៅកន្លែងមួយ យើងឃើញមានអ៊ីចឹង។ នៅក្នុងកំណត់ហេតុរបស់លោក លោកបានឆ្លើយថា "បុគ្គលដែលជាអ្នកផ្ញើសារទូរលេខនោះ គឺគាត់សរសេររៀបរាប់ទាក់ទងគ្នានៅក្នុងសារទូរលេខនោះ គឺប្រាប់អំពីស្ថានភាពរបស់កន្លែងរៀងៗខ្លួន"។ តើគេបញ្ជូនរៀបរាប់អ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ គឺខ្ញុំនៅរក្សាចម្លើយហ្នឹងដដែល។

**ស៖** សូមអរគុណលោក កានិល។ ខ្ញុំសូមសួរបន្ទាប់ទៀត សារទូរលេខផ្ញើពីមជ្ឈិមមក ឬក៏ផ្ញើពីបងៗពីលើមក។ គឺសារលិខិត សារទូរលេខទាំងអស់នោះ គឺថាផ្ញើមកភូមិភាគថ្នាក់ក្រោមៗ បន្ទាប់មកថ្នាក់ភូមិភាគនោះបញ្ជូនបន្តៗមកឲ្យតំបន់។ នៅក្នុងកំណត់ហេតុរបស់លោក នៅពេលដែលលោកនិយាយអំពីសារទូរលេខផ្ញើពីតំបន់លោកបានឆ្លើយដូចតទៅ ERN ជាភាសាអង់គ្លេសគឺ 00384429 គឺទំព័រដូចតែគ្នាទេទៅនឹងលេខមុន។ "នៅពេលមជ្ឈិមផ្ញើមកភូមិភាគ ភូមិភាគនឹងផ្ញើបន្តមកតំបន់ ដើម្បីចែកជូនបន្ត។ សារទូរលេខទាំងអស់នោះគឺមានការផ្ញើ និងផ្សព្វផ្សាយទៅតាមភូមិភាគ ឬក៏តំបន់រៀងៗខ្លួន" តើអ៊ីចឹងដែរឬទេ?

[១៤:៣៦:០០]

**ឆ៖** គឺខ្ញុំនៅរក្សាចម្លើយហ្នឹងដដែល គឺអ៊ីចឹង។

**ស៖** ពាក់ព័ន្ធទៅនឹងសារទូរលេខផ្ញើពីមជ្ឈិមមកដល់ភូមិភាគរបស់លោក។ តើមន្ទីរ ឬក៏អង្គភាពនៅមជ្ឈិមនោះដែលកាន់កាប់បញ្ហាសារទូរលេខនោះមានឈ្មោះអ្វីដែរ?

**ឆ៖** ខ្ញុំសូមឆ្លើយ គឺអ្នកដែលកាន់កាប់នៅមជ្ឈិមហ្នឹងគឺខ្ញុំៗអត់ដឹងទេបញ្ហាហ្នឹង អត់ ព្រោះរបបហ្នឹងគេៗអត់ គេមិនបញ្ចេញឈ្មោះតែម្តងខ្ញុំនិយាយឲ្យចំ។ គឺការងារខ្ញុំៗដឹង ការងារគេៗដឹង។ គឺថានៅក្នុងឯកសារនេះ។

**ស៖** តើមានឈ្មោះមន្ទីរនៅមជ្ឈិមនោះដែរឬទេ?

**ឆ៖** សូមម្តងទៀត ខ្ញុំ -- សំណួរខ្លី។

**ស៖** បាទ ខ្ញុំនឹងសួរសំណួរ។ ឥឡូវនេះ បន្តិចទៀតខ្ញុំនឹងបង្ហាញសារទូរលេខ។ ឥឡូវនេះ យើងនិយាយតំបន់នៅក្នុងភូមិភាគ យើងនិយាយភូមិភាគកណ្តាល បន្ទាប់ពីការបែងចែកភូមិភាគឧត្តរចាស់ កែ ពក គាត់ជាលេខាភូមិភាគ តើត្រឹមត្រូវដែរឬទេ?

[១៤:៣៨:០៥]

**ឆ៖** បាទ ចម្លើយរបស់គឺខ្ញុំនៅរក្សាដដែល។ វាត្រឹមត្រូវ។

**ស៖** នៅក្នុងក្រុមការងារសារទូរលេខរបស់លោកថា មានសមាជិកប្រាំនាក់ ត្រូវដែរឬទេ?

**ឆ៖** គឺត្រឹមត្រូវ។

**ស៖** ការងាររបស់លោកគឺថា លោកជាអ្នកធ្វើប្រតិបត្តិការ ធ្វើការងារខាងម៉ាស ដើម្បីទាក់ទងនឹងសារទូរលេខ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ គឺអ៊ីចឹង។

**ស៖** នៅក្នុងការសម្ភាសរបស់លោក លោកនិយាយអំពីការ -- អ្នកបកទូរលេខដែលមានឈ្មោះថា ជឿន តើលោកបានបញ្ជាក់បែបនោះទេ?

**ឆ៖** គឺត្រឹមត្រូវ ខ្ញុំបញ្ជាក់អ៊ីចឹងមែន។

[១៤:៣៩:១១]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាអរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្ត

កិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះក្នុងអំឡុងពេលសម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០០:៣៥]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ផ្តល់វេទិការជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឃីត វេយ៉ន័រ៖**

លោកប្រធានសូមអរគុណ។

**សួរដោយលោក ឃីត វេយ៉ន័រ៖**

**ស៖** លោក សួន កានិល នៅក្នុងមន្ទីរមជ្ឈិម តើលោកជាមួយនឹង ឈាន អ្នកបកប្រែសារទូរលេខនោះគឺ អ្នកទាំងពីរលោក ហើយនិងគាត់ហ្នឹងធ្វើការនៅក្នុងមន្ទីរតែមួយ ឬក៏យ៉ាងម៉េច?

**លោក សួន កានិល៖**

**ឆ៖** បាទខ្ញុំសូមឆ្លើយ។ គឺ ឈាន និងខ្ញុំគឺនៅក្នុងមន្ទីរតែមួយ ក៏ប៉ុន្តែវា តួនាទីខុសគ្នា។ ខ្ញុំអ្នកវាយម៉ាស៊ីន គេអ្នកបកសារ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ នៅពេលនេះខ្ញុំសូមលើកឡើង អំពីសារទូរលេខបញ្ជូនពីមជ្ឈិមមកភូមិភាគ

ឯកសារលេខ E3/344 ERNជាភាសាអង់គ្លេសគឺ 00384429, បារាំងមានលេខERN 00426148, ខ្មែរគឺ 00373498។ លោកបានលើកឡើងថា មានកាលវិភាគតែខាងមជ្ឈិមនោះជាអ្នកកំណត់ថាត្រូវផ្ញើសារទូរលេខនោះមកថ្ងៃណាថ្ងៃណី? កាលវិភាគដែលខ្ញុំដឹងមកពីមជ្ឈិមនោះគឺមានកំណត់តារាងពេលវេលាអ៊ីចឹង តើមែនដែរឬទេដែលថាគេមានកំណត់តារាងពេលវេលា?

[១៥:០៣:១១]

**ឆ៖** ខ្ញុំសូមឆ្លើយ បើតាមហៅថា បច្ចេកទេសរបស់ទូរលេខគឺថា ការផ្ញើគឺសុទ្ធតែមានហៅថាច្បាប់របស់ទូរលេខ។ ឧទាហរណ៍ថា ការទាក់ទងពីភូមិភាគទៅមជ្ឈិម មួយថ្ងៃគេឱ្យទាក់ទងតែពីរដងទេ គឺនៅម៉ោងប្រាំព្រឹក និងម៉ោងប្រាំមួយល្ងាច។ ប៉ុន្តែដោយពេលវេលា មានសភាពការណ៍មមាញឹកដូចចូលដល់ឆ្នាំ៧៨ គឺគេបង្កើតជាហៅថាវិទ្យុប្រចាំការមួយទៀត ប្រចាំការនោះបានតែពីខាងក្រោមហៅទេ ខាងលើហៅមកខាងក្រោមអត់បានទេ។ វាអ៊ីចឹងបាទ សូមមានមតិប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមផ្តោតសួរអំពីសារទូរលេខផ្ញើពីខាងមជ្ឈិមមកៗកាន់ភូមិភាគរបស់លោក។ ប្រហែលជាលោកអាច ខ្ញុំអាចលើកឧទាហរណ៍អ៊ីចេះថា ឧទាហរណ៍ថាខ្ញុំនេះមជ្ឈិម ហើយខ្ញុំបញ្ជូនសារទូរលេខពីខ្ញុំទៅកាន់លោកដែលជាភូមិភាគ តើគេដាក់ទំនាក់ទំនងយ៉ាងម៉េចដែរផ្ញើទៅខាងភូមិភាគ នោះហើយអ្នកផ្ញើនោះគេសរសេរយ៉ាងម៉េចខ្លះ? បានន័យថាអាសយដ្ឋានទាក់ទងនោះគេដាក់យ៉ាងម៉េចដែរនៅពេលដែលគេផ្ញើសារទូរលេខ?

**ឆ៖** បញ្ហាហ្នឹងវា -- ខ្ញុំឆ្លើយបានដោយស្រួល ពីព្រោះខ្ញុំជាអ្នកបច្ចេកទេសទូរលេខ។ គឺថាបច្ចេកទេសទូរលេខ មានហៅថា ក្នុងការផ្ញើៗដូច្នេះ គេមានហៅថា តារាងទាក់ទងរបស់គេ ដូចថាខាងខ្ញុំហ្នឹង ខ្ញុំគ្រាន់តែលើកឧទាហរណ៍ឱ្យខាងលោកស្តាប់ ដូចថាខាងខ្ញុំគេដាក់ឈ្មោះថា "ក" ឬក៏ខាងដៃគូម្ខាង យើងថាឈ្មោះ "ខ" អ៊ីចឹង។ អាហ្នឹងគឺថា ទាក់ទងគ្នា។ បើកាលណាគេហៅគ្នា ៥នាទីម្តងម្នាក់ដល់ឮគ្នាហើយគេថា អ្នកឯងឈ្មោះអី? បើថាឈ្មោះ "ខ" បានយើងឆ្លើយ បើអ្នកឯងឆ្លើយឈ្មោះ "គ" គេអត់ឆ្លើយទេ។ អាហ្នឹងក្នុងការទាក់ទង។ ឯខាងនែ៎-- គឺថាគេមានតារាងក្នុងការកំណត់គេច្បាស់លាស់ណាស់ បើខុសៗគឺអត់ទាក់ទងគ្នាបានទេ។ បាទ អត់មានច្រឡំគ្នាទេ ច្រើនកន្លែងណាស់ ខ្ញុំធ្វើរហូតពី -- ខ្ញុំផ្ញើកាន់វិទ្យុម្នាក់ខ្ញុំ រហូតដល់ខ្ញុំកាន់វិទ្យុទូរលេខ៥គ្រឿងម្នាក់ឯងបាទ។ សូមមានប៉ុណ្ណឹង។

[១៥:០៦:១៩]

**ស៖** ដូច្នេះ ខ្ញុំនៅមជ្ឈិមនេះ ខ្ញុំផ្ញើសារទូលេខទៅកាន់លោកនៅភូមិភាគ អ៊ីចឹងគឺថា មានការ

ទាក់ទងគ្នាជាមុនសិនថាតើយើងពិតជាអ្នកដែលត្រូវទទួល និងអ្នកបញ្ជូនទៅដែរឬទេ។ បន្ទាប់មកលោកវាយម៉ស ឌិកទិកទិកតាតា ដើម្បីទាក់ទងគ្នា ឬក៏ប្រើការទាក់ទងនេះស្រដៀងៗហ្នឹង។ ខ្ញុំនៅមជ្ឈិមផ្ញើសារទូរលេខទៅកាន់លោកនៅភូមិភាគ ហើយបន្ទាប់មកគឺបំភ័ន្តអក្ខរៈ តើអ៊ីចឹងដែរឬទេ គឺមានការបំភ័ន្តអក្ខរៈ។

**ឆ៖** ក្នុង -- ខ្ញុំសូមឆ្លើយ ក្នុងការទាក់ទងគ្នា ដូចថាពីមជ្ឈិមមកខាងខ្ញុំភូមិភាគ ដូច្នេះ ដូចខ្ញុំបានជម្រាបហើយថា វាមានម៉ោងមានពេលវេលា វាមានឈ្មោះរបស់វា ហើយបើសិនជាមានសារគេប្រាប់អ៊ីចេះទៀត គឺថាឥឡូវខ្ញុំមានសារទៅខាងលោក ដូចថាពីមជ្ឈិមវៃមកថា ខ្ញុំមានសារ។ ប៉ះត្រង់ណាទាក់ទងគ្នាទៅវាជាន់ម៉ោងគ្នា គឺថាសូមទាក់ទងនៅខាងក្រោយ-- ម៉ោងក្រោយ។ ដូច្នេះ គឺគេប្រាប់អ៊ីចឹងបើមានសារវាមានលេខសារវាទៀត បើថាសារណាប្រញាប់ គឺថាសារហ្នឹងប្រញាប់ណាស់ បើសារហ្នឹងអត់ប្រញាប់ទេ គេថាសារហ្នឹងអត់ប្រញាប់ទេ វាមានគេហៅថាៗ លេខកូដរបស់វា ឬក៏ថាមានសញ្ញាទាក់ទង អ៊ីចេះបន្តិច អាហ្នឹងពាក្យអក្សរកាត់ទេណ៎ា គេថា *អាឡាគុយហ្សិត* គេម៉េចនោះ ខ្ញុំថាអ៊ីចឹង អក្សរកាត់ នេះសញ្ញា។ គេប្រើជាសញ្ញាសកលទាក់ទងគ្នាដែរ គឺសញ្ញាសកល។ បានជាខ្ញុំថាសញ្ញានេះជាសញ្ញាសកល ព្រោះខ្ញុំឃើញគេដាក់ ពាក្យគេថា អក្សរបារាំងគឺថា អា.ដេ.ដេ គឺថាបន្ថែម។ នេះចង់និយាយប៉ុណ្ណឹង។

[១៥:០៨:២៩]

**ស៖** ដូច្នេះប្រសិនបើខ្ញុំនៅមជ្ឈិមបញ្ជូនសារទូរលេខទៅកាន់លោកនៅខាងភូមិភាគ តើសរសេរសារទូរលេខហ្នឹង តាមរយៈអ្វី? សរសេរតាមលិខិតនៅក្នុងសៀវភៅ ឬក៏យកស៊ីទៅសរសេរនៅក្នុងណាដែរ ទើបខាងនោះទទួលបាន?

**ឆ៖** ខ្ញុំសូមឆ្លើយ ពាក្យថា សារទូរលេខ វាចេញជាលេខ។ បាន-- ដូច្នេះដល់ពេលគេមានហៅថាដូចជា ដូចថានិយាយខាងខ្ញុំភូមិភាគ ខ្ញុំភូមិភាគ ដូច្នេះ បើចង់ថា ចង់ឲ្យសំបុត្រមួយទៅខាងតំបន់ដូច្នេះគេមានអ្នកលេខាគេអ្នកសរសេរអក្សរ។ លេខាគេសរសេររួចហើយ គេយកទៅឲ្យអ្នកបកប្រែ។ អ្នកបកប្រែរួចហើយបានគេយកមកឲ្យខ្ញុំអ្នកវៃ។ គេមានដំណាក់ៗគ្នាអ៊ីចឹង។ បាទ គេសរសេរៗរួចហើយបានអ្នកបកប្រែបកមកចេញជាលេខ ឯខ្ញុំអ្នកវៃម៉ស ខ្ញុំដឹងថចេះតែវៃទៅ ប៉ុន្តែអ្នកបកប្រែ អ្នកឯងបកខុស អាហ្នឹងវាគិតទៀត វាមានច្បាប់វាទៅតាមហ្នឹងទៀត។

**សៈ** ខ្ញុំសូមបំបែកសំណួរ។ គឺលោកអ្នកសរសេរលេខអ៊ីចឹងមែនទេ? គឺលេខហ្នឹង បន្ទាប់មកត្រូវយកទៅបកប្រែ ពីលេខហ្នឹងទើបបកទៅចេញជាអក្សរ តើអ៊ីចឹងដែរឬទេ?

[១៥:០៩:៥៨]

**ផៈ** អ៊ីចឹងហើយ គឺថាត្រូវ ភាសាខ្លី សរសេរជាលេខហើយបានបកប្រែ បាទអ៊ីចឹង។

**សៈ** អ៊ីចឹងអ្នកដែលសរសេរទៅជាលេខនោះ គឺមិនមែនលោកទេ គឺមានអ្នកផ្សេងមួយទៀតនៅក្នុងអង្គភាព ឬមន្ទីរហ្នឹង តើជាអ្នកណាដែរ?

**ផៈ** ដូចនៅក្នុងដែលខ្ញុំបានឆ្លើយនឹងសំណួរហ្នឹង គឺដូចឈ្មោះ ឈាន ៗហ្នឹងគាត់ជាអ្នក ហៅថាលេខា កែ ពក ផ្ទាល់ សរសេរជាអក្សរហើយ ក្រោយមកគេរើសឲ្យគាត់ហ្នឹងជាអ្នកបកប្រែបណ្ដោយ។ ខ្ញុំៗអត់ដឹងរឿងទេ គឺខ្ញុំគ្រាន់តែយក តែគេយកលេខមកឲ្យខ្ញុំមក ខ្ញុំចេះតែអ្នកវៃ ប៉ុណ្ណឹង។ គេអត់ឲ្យដឹងគ្នា អ្នកវៃនិងអ្នកបក។

**សៈ** ខ្ញុំព្យាយាមបំបែកសំណួររបស់ខ្ញុំ។ លោកជាអ្នកទទួលសារទូរលេខ ហើយបន្ទាប់មកសារទូរលេខហ្នឹង គឺបកប្រែ។ តើចំពោះ កែ ពក យ៉ាងម៉េចដែរ? តើ កែ ពក ហ្នឹងឃើញគ្រប់សារទូរលេខទាំងអស់ ឬក៏យ៉ាងម៉េច?

**ផៈ** គឺសារទូរលេខឲ្យតែមានមកដល់ ហៅថាភូមិភាគ គឺដូចថាខ្ញុំទទួលរបស់មកពីតំបន់អ៊ីចឹងថាសារហ្នឹងវាមានក្បាលសារប៉ុន្មាន ចំនួនខ្ទង់ប៉ុន្មាន អីប៉ុន្មានអ៊ីចឹងទៅ ខ្ញុំសរសេររួច ខ្ញុំមានសិទ្ធិថា ខ្ញុំយកសារហ្នឹងទៅឲ្យៗគាត់ផ្ទាល់ បានគាត់ទទួលសារទូរលេខហ្នឹងហើយ បានគាត់ឲ្យមកអ្នកបកប្រែ។ បកប្រែចេញជាអក្សរហើយ បានអ្នកហ្នឹងគេយកទៅឲ្យគាត់ គឺគ្រប់សារទូរលេខទាំងអស់។ គឺធ្វើអ៊ីចឹងអត់ឲ្យច្របូកច្របល់គ្នាទេ។

[១៥:១២:០៥]

**សៈ** ដូច្នេះនៅពេលដែលទទួលសារទូរលេខ សរសេរចេញសិន។ បានន័យថា យកឲ្យ កែ ពក មានការបកប្រែ។ ឧទាហរណ៍ថា សារទូរលេខ ខ្ញុំនៅមជ្ឈិមបញ្ជូនទៅលោក ទៅភូមិភាគ ហើយបន្ទាប់មកភូមិភាគត្រូវបញ្ជូនទៅតំបន់។ តើគេបញ្ជូនតាមមធ្យោបាយណាដែរ? បញ្ជូនពីភូមិភាគទៅតំបន់នេះដោយមធ្យោបាយណាដែរ?

**ផៈ** គឺរឿងសារទូរលេខ ដូច្នេះខ្ញុំថា ចង់និយាយថាពាក្យហ្នឹងវាខ្លី។ ដូចថា ជូនសារពីមជ្ឈិមមកភូមិភាគ គេមានតារាងៗវាផ្សេង តារាងបកហ្នឹងផ្សេង។ ហើយដល់យើងបានមកភូមិភាគហើយ យើង

បញ្ជូនទៅតំបន់ គឺមានតារាងបកគេផ្សេងទៀត អត់ឲ្យដឹងគ្នា។ តារាងបកផ្សេងៗគ្នា អត់មានឲ្យនេះទេ។ ហើយដល់ក្រោយមកនេះ គេមានអាលេខ ពិបាកបន្តិចដែរ ប៉ុន្តែអាលេខគេសងទៀតណា ដើម្បីកុំឲ្យផ្កាយរណបហ្នឹងចាប់បានទៀត។ គេសង ហើយអ្នកសងទាល់តែអ្នកលឿនដែរ បានសងទាន់។

**ស៖** យើងដឹងថា គេមានតារាងពេលវេលាត្រូវបញ្ជូនទៅពេលណាទៅពេលណី ទៅតាមភូមិភាគ ចុះប្រសិនបើភូមិភាគបញ្ជូនសារទូរលេខទៅតំបន់ តើគេមានតារាងកំណត់ពេលវេលាសម្រាប់បញ្ជូនសារទូរលេខពីភូមិភាគទៅតំបន់ដែរឬទេ?

[១៥:១៣:៤៧]

**ឆ៖** គឺខ្ញុំសូមឆ្លើយ គឺរឿងហ្នឹង គេមានកំណត់ម៉ោងគ្នា គឺថាមានកំណត់ពេលវេលា គឺមាន។ អត់ឲ្យម៉ោងហ្នឹងជាន់គ្នាទេ។ ដូចថាទាក់ទងមកតំបន់៤១ គឺចាប់ពីម៉ោងដូចថា ខាងខ្ញុំទាក់ទងទៅមជ្ឈិមម៉ោងប្រាំ។ ដូច្នេះម៉ោងប្រាំកន្លះ គឺទាក់ទងមកតំបន់៤១ អ៊ីចឹងទៅ។ ដល់ម៉ោងប្រាំមួយទាក់ទងនឹងតំបន់៤២ទៅ ខុសៗគ្នា។ បើសិនជាមានសារហ្នឹងវាវែង គឺគេបណ្ដាក់ទៀតថា ឥឡូវខ្ញុំជាប់រវល់ ខ្ញុំសូមជួបអ្នកឯងម៉ោងប្រាំបួនទៀត ព្រោះសារហ្នឹងវែង។ គេចេះតែបណ្ដាក់គ្នារហូតអ៊ីចឹង។ បើសិនជាយើងមានម៉ាស៊ីនច្រើន អត់ទេ គេផ្លាស់តែពីម៉ាស៊ីនមួយទៅម៉ាស៊ីនមួយ អត់មានពិបាកនេះម៉ោងទេ។

**ស៖** ខ្ញុំសូមលើកឧទាហរណ៍ជាក់លាក់ នៅក្នុងឯកសារចៅក្រមស៊ើបអង្កេត ឯកសារ E3/411, អង់គ្លេស ERN 00390077, បារាំង 00424036, ខ្មែរ 00373510។ លោកបាននិយាយថា "ប្រសិនបើមជ្ឈិមចង់អញ្ជើញលេខាតំបន់មកប្រជុំនៅភូមិភាគ គឺការអញ្ជើញនេះ គឺគេផ្ញើតាមសារទូរលេខ"។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** តាមសំណួររបស់លោកសួរ អាហ្នឹងវា-- បើខ្ញុំអ្នកកាន់ទូរលេខថាវាទៅតាម ហៅថាទៅតាមថ្នាក់របស់វា។ ដូច្នេះមជ្ឈិមបញ្ជោមកភូមិភាគ ភូមិភាគបញ្ជោទៅតាមតំបន់។ ឯការផ្ញើសារគេអត់ឲ្យកាត់គ្នាទេ គេអត់ឆ្លងកាត់គ្នាទេ ទៅតាមថ្នាក់របស់គេ។

[១៥:១៦:០៣]

**ស៖** នៅពេលនេះ ខ្ញុំសូមសួរអំពីការផ្ញើសារទូរលេខត្រឡប់វិញម្ដង។ បានន័យថា ប្រសិនបើមានសារទូរលេខមកពី -- ផ្ញើមកពីតំបន់វិញម្ដង ផ្ញើមកកាន់លោកនៅភូមិភាគ ដែលគេឲ្យចង់ឲ្យលោកនេះបញ្ជូនបន្តទៅឲ្យមជ្ឈិម។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយចៅក្រមស៊ើបអង្កេត ឯកសារ E3/344 អង់គ្លេស ERN គឺ 00384429, បារាំងមានលេខ 00426148, ខ្មែរមានលេខ 00373498។

លោកបានឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់សម្តីរបស់លោក "សារទូរលេខដែលផ្ញើទៅ -- ដែលមកពីតំបន់នោះ គឺថា បើសិនជាចង់ផ្ញើទៅមជ្ឈិមនោះ ត្រូវឆ្លងកាត់ភូមិភាគរបស់ខ្ញុំ"។ អ៊ីចឹងបានន័យថា សារទូរលេខផ្ញើមកពីតំបន់នោះត្រូវបញ្ជូនមកឲ្យភូមិភាគសិន ដែលនៅក្នុងភូមិភាគហ្នឹងលោកជាអ្នកចាត់ការបញ្ជូនតទៅមជ្ឈិម។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** សូមឆ្លើយ។ គឺអ៊ីចឹងមែន។

**ស៖** នៅក្នុងកំណត់ហេតុដដែលនេះ គឺលោកបានឆ្លើយថា "សារទូរលេខផ្ញើមកពីតំបន់នោះមិនបញ្ជូនទៀងទាត់នោះទេ។ រៀងរាល់ថ្ងៃនោះ គឺថាខ្ញុំទទួលសារទូរលេខតែមួយប៉ុណ្ណោះមកពីខាងតំបន់"។ ក៏ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៨ សារទូរលេខមកពីតំបន់នោះផ្ញើមកលោកញឹកញាប់ណាស់។ តើពិតជាអ៊ីចឹងដែរឬទេ?

[១៥:១៨:០៩]

**ឆ៖** ខ្ញុំឆ្លើយបាទ គឺវាអ៊ីចឹងមែន។

**ស៖** អ៊ីចឹងបានន័យថា អ្នកនៅតំបន់ហ្នឹង ហើយនិងលោកមុនដែលបញ្ជូនសារទូរលេខហ្នឹងលោកពីរនាក់នៅម្ខាងម្នាក់ហ្នឹង គឺធ្វើការទាក់ទងជាមុនសិន ដើម្បីឲ្យត្រៀមខ្លួនរួចរាល់ដើម្បីទទួល និងបញ្ជូនសារទូរលេខ តើអ៊ីចឹងដែរឬទេ?

**ឆ៖** អ៊ីចឹងមែន។

**ស៖** ដូច្នេះខាងតំបន់នោះ បញ្ជូនសារទូរលេខមកដល់ខាងភូមិភាគលោក បន្ទាប់មកបកប្រែទើបបញ្ជូនបន្ត។ អ៊ីចឹងតើ កែ ពក បានឃើញសារទូរលេខបញ្ជូនមកពីតំបន់មកឲ្យភូមិភាគដែរឬទេមុនពេលបញ្ជូនបន្តទៅឲ្យមជ្ឈិម?

[១៥:១៩:១៥]

**ឆ៖** សូមឆ្លើយ។ រាល់ការសារទូរលេខគឺ កែ ពក គឺត្រូវតែ -- មានឲ្យតែមានការបញ្ជូនមកតាមហៅថា តំបន់ មកភូមិភាគ គឺថា កែ ពត ត្រូវតែដឹងទាំងអស់។ បើសិនជា -- ពីព្រោះថា វាមានសៀវភៅគេកត់ទៀត អ្នកណាធ្វើការហ្នឹង ទទួលសារប៉ុន្មានអីប៉ុន្មាន កាលណាបាត់សារហ្នឹងគេ គឺខាងតំបន់គេមកធ្វើការ គឺគេរករឿងអ៊ីចឹង។ ឆ្លើយដោយខ្លីៗអ៊ីចឹង។

**ស៖** អ៊ីចឹងបានន័យថា សារទូរលេខដែលផ្ញើចូលមកខាងភូមិភាគលោក ហើយនិងផ្ញើចេញទៅនោះ គឺថាលោកមានកូនសៀវភៅសម្រាប់កត់ត្រាទុកថា មានសារទូរលេខអ្វីខ្លះចេញចូល។ តើអ៊ីចឹង

ដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ អ៊ីចឹងមែន។

**ស៖** ដើម្បីឱ្យយើងយល់ច្បាស់ទាំងអស់គ្នា នៅក្នុងភូមិភាគរបស់លោកនោះ គឺថាមានបីតំបន់ គឺតំបន់៤១ តំបន់៤២ និងតំបន់៤៣ ក្រោមភូមិភាគរបស់លោក។ ហើយតំបន់នីមួយៗនោះ គឺថាមានអ្នកកាន់កាប់សារទូរលេខហ្នឹង គឺមួយៗដាច់ដោយឡែកៗពីគ្នា។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** អ៊ីចឹងមែន ខ្ញុំសូមសង្ខេបខ្លី។

[១៥:២០:៥២]

**ស៖** លោក កានិល នៅពេលនេះគឺថាខ្ញុំសូមសួរលោក បង្ហាញឧទាហរណ៍ជាក់លាក់ជូនលោកសួរអំពីសារទូរលេខ។

**លោក ឃីត វេយ្យ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត សូមឱ្យសារទូរលេខលេខ E3/519 នេះជូនទៅកាន់សាក្សី។ សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ។

**លោក ឃីត វេយ្យ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចាំងសារទូលេខនេះនៅលើអេក្រង់ផងដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៥:២១:៤៧]

**សួរដោយលោក ឃីត វេយ្យ៍ន័រ៖**

**ស៖** លោក សួន កានិល សូមឱ្យលោកចំណាយពេលបន្តិចបន្តួចទៅមើលឯកសារសារទូរលេខហ្នឹង ដើម្បីឱ្យលោកស្គាល់ជាមុនសិន។ យើងអាចមើលឃើញថា នៅខាងឆ្វេង ខាងលើនោះ សារទូរលេខមានលេខ៣២ សារទូរលេខ៣២។ នៅខាងក្រោមគឺយើងមើលឃើញថា "ពក សមមិត្តពក ជាអ្នកផ្ញើសារទូរលេខ ផ្ញើថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៨ ហើយទទួលនៅថ្ងៃ២៩ ខែមីនា ម៉ោង២៣:០០យប់

ហើយមានដាក់ចម្លងជូន អ៊ំនួន, មន្ទីរ និងឯកសារ”។ ហើយសារទូរលេខនេះផ្ញើទៅកាន់ ដាក់ចំណងជើងថា “ជម្រាបមកគណ:៨៧០ ជាទីនឹករឭក”។ ដូច្នេះក្រោយពេលលោកមើលសារទូរលេខនេះ តើលោកយល់យ៉ាងម៉េចដែរគណ:៨៧០នេះ ឬក៏លេខ៨៧០នេះ លោកយល់ថា វាមានន័យយ៉ាងម៉េចសំដៅលើអ្វី?

**ឆ៖** ខ្ញុំសូមឆ្លើយ។ គឺដែលថា សំបុត្រនេះ បើតាមខ្ញុំពិនិត្យមើលច្បាស់ គឺមិនមានភ័ន្តច្រឡំអីទេ ព្រោះសំបុត្រនេះជាសំបុត្រសារទូរលេខច្បាស់លាស់ហើយ។ បានបញ្ជាក់ -- ចង់បញ្ជាក់ថាច្បាស់លាស់នៅត្រង់ចំណុចណា? ជាធម្មតាសំបុត្រសរសេរដៃផ្សេង សំបុត្រសារទូរលេខវាផ្សេង។ ខ្ញុំចង់បញ្ជាក់ថា សារទូរលេខ គេដាក់ថា “ទូរលេខ៣២” អាហ្នឹងពួកខ្ញុំ ដល់ពេលមកខ្ញុំទទួលរួច ខ្ញុំដាក់លេខ៣២។ ចំនួនខ្ទង់ប៉ុន្មាន? អានេះគេដាក់ចំនួនខ្ទង់ទៀត ២៩៥ខ្ទង់។ អាហ្នឹងពួកខ្ញុំវៃទៅ បង្គ្រប់២៩៥ខ្ទង់ទៅឲ្យគេ។ តើគេទទួលគ្រប់ឬអត់? បើគេទទួលបានតែ២៩០ ខ្វះ៥ខ្ទង់។ ដល់ពេលខ្ញុំវៃរួច គេថា -- ខ្ញុំសួរថា “ទទួលគ្រប់ឬនៅ?” បើពិនិត្យមើលថា ខុសខ្ទង់ទៀត ខ្ញុំប្រាប់ថា “អ្នកឯងទទួលហ្នឹង មានរំលងកន្លែងណាហើយ” គេដឹងទាំងអស់ទៀត។ ដល់អ៊ីចឹងទៅ អានេះគឺថាសំបុត្រនេះជាសំបុត្រសារទូរលេខ។ ហើយម៉ោងពេលវេលាកំណត់ហ្នេង គឺក៏គេដាក់អ៊ីចឹងដែរ។

[១៥:២៤:៤៥]

បើសិនជាអ្នកធ្វើការមិនត្រឹមត្រូវ ឧទាហរណ៍ថា គេដាក់ថ្ងៃប៉ុន្មាន ២៩អ៊ីចេះ -- អានេះដូចគ្រាន់តែម៉ោង រហូតដល់គេដាក់ម៉ោងទៀត។ ដូច្នេះគឺថាមិនខុសគ្នាប៉ុន្មាន។ អានេះបើពីររយ -- ២៧៥ខ្ទង់ បើអាចបញ្ជូន យើងថា១នាទីយ៉ាងអន់បំផុត ៦០ វៃបាន៦០អក្សរ។ ដូច្នេះតែ ២៩០ យ៉ាងច្រើនតែ ៤-៥ នាទីអ៊ីចេះ ថាប្រហែល៦នាទីអ៊ីហ្នឹង។ បាទ អ្នកវៃលឿន។ អ្នកវៃលឿនដែលគេធ្វើការនៅលើយន្តហោះ រហូត១នាទី ១៤០ ឬ១៥០ ប៉ុន្តែខ្ញុំៗទទួលបានតែត្រឹម៧០ទេ ខ្ញុំអត់ៗទទួលច្រើនទេ បើអ្នកវៃលឿនប៉ះចួនណារម៉ិងរមុំងទៅ វាយឺតជាងអ្នកធ្វើគឺថា ដើរសន្សឹមៗនេះ បាទ។

**ស៖** នៅពាក្យដើមដំបូងមួយចំនួននោះគឺថា កែ ពក ហ្នឹងសរសេរថា “ខ្ញុំសូមរាយការណ៍ជូនអង្គការ” អ៊ីចឹងតើអ្នកណាគេជាអ្នកទទួលសារទូរលេខនេះ?

[១៥:២៦:០៧]

**ឆ៖** សារទូរលេខនេះគឺថា “សូមរាយការណ៍ជូនអង្គការ” ដូច្នេះអាហ្នឹងវាស៊ីសងទៅលើអ្នកដែលបកសារហ្នឹង ខ្ញុំមិនមែនថានេះទេ។ ទាល់តែចេះរៀបពាក្យកាត់ខ្លះ អានេះក្រោយមកបានខ្ញុំក្លាយ

ទៅជាអ្នកបកសារ ប៉ុន្តែខ្ញុំអត់និយាយទេអារឿងបកសារ គឺខ្ញុំនិយាយតែ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលខ្ញុំអត់ចេះទេ។ បើឲ្យខ្ញុំៗអ្នកបក ខ្ញុំអត់សរសេរអ៊ីចឹង ខ្ញុំគ្រាន់ប្រាប់អ៊ីចឹង គឺគេសរសេរអក្សរកាត់ ខ្លីៗ ដើម្បីយល់ពីបញ្ហាសារទូរលេខ។ អានេះគឺថា គាត់ឲ្យមកប៉ុន្មានសរសេរនុំង អ្នកបកៗប៉ុណ្ណឹងដែរ។ ដូច្នេះគេថានៅក្នុងនេះជូនអង្គការ អានេះគឺវាប្រើពាក្យសរុបតែម្តង ពាក្យ "អង្គការ" ពាក្យសរុបតែម្តង អត់មានជូនៗម្នាក់ទេ ជាអង្គការ។ ដូច្នេះ គេដឹងថាទៅកន្លែងអង្គការទៅមន្ទីរ៨៧០ហ្នឹង គឺថា គេដឹងៗថាយកទៅដល់ទីនោះគេចែកហើយ អ៊ីចឹង។

**ស៖** នៅពេលនេះគឺយើងខ្ញុំនឹងសួរ សាកសួរ ថាតើយើងយល់អ្វីខ្លះពីសារទូរលេខនេះ គឺថាសារទូរលេខផ្ញើមកពី កែ ពក នៅខាងក្រោមៗសារទូរលេខនេះ ឃើញ យើងឃើញថា សរសេរថា "ខ្លឹមសារសំបុត្រនេះខ្ញុំចម្លងយកតាមសំបុត្រសមមិត្តអាន តំបន់៤១ ជូនអង្គការ"។ ដូច្នេះបានន័យថា សារទូរលេខនេះ គឺផ្ញើចេញពីភូមិភាគទៅឲ្យមជ្ឈិម ដោយផ្អែកទៅតាមខ្លឹមសារផ្ញើមកពីសមមិត្តអាន នៅតំបន់៤១។ តើអ៊ីចឹងដែរឬទេ?

[១៥:២៨:១៨]

**ឆ៖** រឿងនេះវាៗ ខ្ញុំសូមឆ្លើយថារឿងនេះវាត្រឹមត្រូវ ប៉ុន្តែចាំខ្ញុំសូមបកស្រាយបន្តិចបានទេ? ពីព្រោះតែរឿងហ្នឹងវាមានបញ្ហាកើតនៅតំបន់៤១ កាលណោះវាមានគេហៅថា ដូចថាមានចោរព្រៃកើតនៅខាងព្រៃរនាមអីហ្នឹង ដល់ពេលគេចាប់បានមក បានពីខាង៤១ហ្នឹង គេឲ្យទូរលេខមកតាមៗទូរលេខពី៤១ មកជូនមកភូមិភាគ ដូច្នេះភូមិភាគបានរាយការណ៍បន្តទៅខាងៗមជ្ឈិម។ គឺសារទូរលេខនេះវាមានខ្លឹមសារអ៊ីចឹង វាមានសភាពការណ៍នៅតំបន់៤១ហ្នឹង កាលណោះខ្ញុំដឹងដែរ។

**ស៖** ដូច្នេះយើងឃើញថា កែ ពក នោះចង់រាយការណ៍ឲ្យមានចំណាត់ការអ្វីខ្លះពីមជ្ឈិម ដូច្នេះយើងឃើញនៅខាងក្រោមនោះ គេដាក់ថា "អង្គការស្នើឲ្យអង្គការសាកសួរសមមិត្ត ម៉េង ផង។ បើមានឈ្មោះដូចរាយការណ៍ តើមានឈ្មោះដូចរាយការណ៍ទេ? បើមានសូមឲ្យដំណឹងមកទាក់ទងសមមិត្តអាន តំបន់៤១ ទទួលយុវជននេះផង បើគ្មានទេសូមអង្គការតបដំណឹងទៅវិញ"។ ដូច្នេះបានន័យថា អង្គការនេះ ក្រោយមកឆ្លើយតបទៅនឹងសារទូរលេខនេះដោយមានចំណារព៌ណនាំមកជាមួយផង។ តើអ៊ីចឹងដែរឬទេ?

[១៥:២៩:៥៣]

**ឆ៖** រឿងនេះ ខ្ញុំៗក្តាប់បានបញ្ហាហ្នឹង ក្តាប់បានច្បាស់។ ពីព្រោះថាមាន នៅក្នុងខ្លឹមសារហ្នឹងខ្ញុំ

សូមលើកបន្តិចចុះ ថាវាមានបញ្ហាហ្នឹងកើតឡើង មានយុទ្ធជនពីរនាក់ ដែលមកៗលេងផ្ទះ នេះខ្ញុំមសារសំបុត្រនេះ ដល់មកលេងផ្ទះទៅ ប៉ុន្តែយុទ្ធជនហ្នឹងនៅជាមួយថា ឈ្មោះ ម៉េត ទេ ម៉េត ហ្នឹងនៅខាងព្រលានយន្តហោះ។ ដូចនេះគាត់ហ្នឹងទទួលខាងព្រលានយន្តហោះទេ ដូច្នេះដល់មកលេងទៅ ប្រហែលអត់សំបុត្រ អត់សំបុត្រទៅ មិនមែនប្រហែលទេគឺអត់សំបុត្រៗ ខាងតំបន់៤១ គេឃាមកាមតាមផ្លូវថ្នល់ក៏គេអត់ ឲ្យទៅៗគេត្រូវរាយការណ៍មកភូមិភាគ បើរាយការណ៍ទៅ ម៉េត នោះគឺរាយការណ៍អត់បានទេ ព្រោះអត់មានតារាងផង ហើយវាខុសលាក់ការណ៍របស់គេផង ទៅរាយការណ៍មកភូមិភាគ ហើយភូមិភាគហ្នឹងក៏មិនអាចនឹងរាយការណ៍ទៅ តាម៉េត ហ្នឹងបានទេ ទាល់តែភូមិភាគហ្នឹងរាយការណ៍ទៅមជ្ឈិម បានមជ្ឈិមហ្នឹងរាយការណ៍ទៅឲ្យ ម៉េត ហ្នឹងបានៗអ៊ីចឹង។

**ស៖** ឥឡូវនេះបើយើងហួសពីព្រំដែនតំបន់មួយ តើ កែ ពក ចង់ជូនទូរលេខទៅផ្ទាល់ទៅ ម៉េត បាទ តើបានឬទេ?

[១៥:៣១:១៣]

**ឆ៖** បាទបើខុសពី ហៅថាបច្ចេកទេសរបស់ទូរលេខគឺថាអត់បានទេ ពីព្រោះខាង ម៉េត នោះគាត់នៅខាងក្រសួងៗរបស់មជ្ឈិម គាត់នៅខាងព្រលានយន្តហោះ។ ដូច្នេះ ខាងភូមិភាគហ្នឹងអត់មានតារាងទាក់ទងទេ បើមានការអីស្រេចតែនឹងខាងមន្ទីរចាត់ចែង ព្រោះក្រសួងនៅខាងមជ្ឈិម គឺមជ្ឈិមជាអ្នកចាត់ចែងហៅមក បាទអ៊ីចឹង។ បញ្ជូនទៅខាង ម៉េត នោះ ភូមិភាគបញ្ជូនទៅខាង ម៉េត នោះទៅអត់បានទេ អត់បានដាច់ខាត។

**ស៖** ខ្ញុំផ្ចង់អារម្មណ៍ទៅលើខាងក្រោមថាតើបង នួន នេះ ជាអ្នកណា? បាទ អ៊ំនួន?

**ឆ៖** បើអ៊ំ នួន ថែម "ជ" ដាក់ស្រះ "ា" ទៀត អ៊ំ នួន ជា។ បាទគាត់ជាអ្នកដែលមក។

**ស៖** ហេតុអ្វីបានជាគាត់ត្រូវតែដឹងអំពីរឿងនេះ បាទដែលដាក់ថា "ចម្លងជូន"នេះ?

**ឆ៖** អារឿងហ្នឹងក៏ខ្ញុំមិនអាចដឹងដែរ ព្រោះគណៈមជ្ឈិមគេអត់ប្រាប់ដែរ ខ្ញុំអត់ដឹងដែរ។ ប៉ុន្តែគេថាគេដាក់ជូន អ៊ំនួន ហ្នឹង ប្រហែលជាគាត់គណៈមជ្ឈិមដែរដឹង បានគេនេះ-- គណៈមជ្ឈិមដឹងប៉ុន្មាននាក់ ខ្ញុំអត់ដឹងដែរ គេអត់ឲ្យដឹង និយាយឲ្យចំ ព្រោះខ្ញុំអត់ដឹង ប៉ុនខ្ញុំឃើញដាក់អ៊ំ នួន ខ្ញុំស្គាល់ថាឈ្មោះហ្នឹង ប្រហែលជាហ្នឹងហើយ។

**ស៖** ដូច្នេះថាតើបញ្ហាមកពីណា ដែលមកប្រាប់លោកឲ្យបញ្ជូនផ្ញើទៅ នួន ជា នេះ?

[១៥:៣៣:១៣]

**ឆ៖** គឺបញ្ជាមកខាងភូមិភាគហ្នឹងហើយ ព្រោះខ្ញុំអ្នកវាម៉សទេ អត់មាននេះទេ តែសំបុត្រនេះបញ្ជូនមកខាង កែ ពក។ កែ ពក បញ្ជូនមកខាងមជ្ឈិម ដល់ខាងមជ្ឈិមមានប៉ះចួនណាមួយមិនទៅមួយទៅ វាមានប៉ុន្មាននាក់ទេគណៈមជ្ឈិម ខ្ញុំក្តាប់អត់បានដែរបញ្ហាហ្នឹង គេអត់ឲ្យដឹងទេ ដឹងពីណាខ្លះ? ព្រោះខ្ញុំ ឋានៈខ្ញុំតូចតាច អត់ទេ គេអត់ឲ្យដឹងទេ។ និយាយអ៊ីចឹង។

**ស៖** ប៉ុន្តែបញ្ជាឲ្យបញ្ជូនទូរលេខទៅ នួន ជា នេះ មកពី កែ ពក ពីអ្នកបកប្រែ ឬក៏អ្នកណាម្នាក់នៅក្នុងតំបន់នោះជាអ្នកបញ្ជាថាបែបនេះនោះ?

**ឆ៖** គឺដូចខ្ញុំបានជម្រាបអ៊ីចឹង គេបញ្ជូនមកតាមថ្នាក់ៗដែលកើតសភាពការណ៍ដែលកើតឡើងដូចថាកើតនៅតំបន់៤១ ខាងតំបន់៤១ គាត់អ្នកគ្រប់គ្រងហើយគាត់បញ្ជូនមកភូមិភាគ ឡើងពីភូមិ ភាគមកគឺមកមជ្ឈិមហើយ។ ហើយអ្នកដែលបញ្ជូនគឺតាមលេខាតំបន់ មកលេខាភាគៗ ទៅគណៈមជ្ឈិមទៅតាមថ្នាក់របស់វាអ៊ីចឹង។

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណ លោក សួន កានិល។

ឥឡូវនេះខ្ញុំនឹងសូមការអនុញ្ញាតពីលោកប្រធាន ដើម្បី ជូនឯកសារ ឯកសារ E3/932។

លោកប្រធាន ហើយខ្ញុំសូមអនុញ្ញាតដាក់ឯកសារនេះ លើអេក្រង់ផងដែរបាទ។

[១៥:៣៥:០៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក សួន កានិល សូមលោកចំណាយពេលបន្តិច ដើម្បីពិនិត្យមើលទូរលេខនេះ។ ហើយយើងឃើញថា ឯកសារនេះនៅខាងលើឆ្វេងដៃនោះ គឺទូរលេខ០២ ហើយខ្ទង់វ៉ាដ្បូនោះគឺថា៦៨០ ដែលមានចំណងជើងថា "សូមជម្រាបមកគណៈ៨៧០"។ នៅខាងចុងទូរលេខនោះ យើងអាចឃើញ "គឺថ្ងៃ ១២ ខែមេសា ឆ្នាំ១៩៧៨ មកពីសមមិត្តពក"។ ហើយអ្នកទទួលនោះ ទទួលនៅថ្ងៃទី៣០ ខែមេសា នៅម៉ោងម្ភៃដប់ប្រាំ។ ហើយខ្លឹមសារនៃទូរលេខនេះ គឺថាឃ្លាទីមួយ សរសេរថា "ខ្ញុំសូមរាយការណ៍បន្ថែម

អំពីសភាពការណ៍នៃសមរភូមិផ្លូវលេខ៧បន្ថែម"។ នៅខាងផ្នែកខាងចុងនៃទូរលេខនេះ កែ ពក បាននិយាយថា "ខ្ញុំបានដាក់វិធានការយ៉ាងច្បាស់ ដែលត្រូវអនុវត្ត ទាំងសមរភូមិខាងកើត និងសមរភូមិខាងលិច ហើយខ្ញុំសូមឲ្យអង្គការរាយការណ៍ អំពីសភាពការណ៍ខាងលើគ្រប់ទិសទីទាំងអស់"។ ឥឡូវនេះ លោកបាននិយាយថា ទូរលេខ -- គឺថាសកម្មភាពសារទូរលេខហ្នឹង គឺរវល់ខ្លាំងណាស់ នៅឆ្នាំ១៩៧៨ តើអ៊ីចឹងដែរឬទេ?

[១៥:៣៧:៣២]

**លោក សួន កានិល៖**

**ឆ៖** ខ្ញុំសូមឆ្លើយ គឺនៅឆ្នាំ១៩៧៨ គឺរវល់អ៊ីចឹងមែន។ ប៉ុន្តែនៅក្នុងខ្លឹមសារនេះ គឺ ឬក៏ខ្ញុំបានដឹងដែរ គឺថាពេលនោះវាមានសភាពការណ៍កើតឡើងនៅខាងភូមិភាគបូព៌ា។ ដល់អ៊ីចឹងទៅ កាលនោះ កែ ពក --ប្រហែលជាគណៈមជ្ឈិម គឺទៅរៀន គេហៅមកភ្នំពេញអស់ គាត់ឲ្យ -- គេឲ្យ កែ ពក នៅជំនួសជំនួស គាត់មានសិទ្ធិនឹងរាយការណ៍ពីបញ្ហាសភាពការណ៍ផ្សេងៗ នៅខាងត្រើយខាងកើតមេគង្គ និងខាងលិចមេគង្គ។ ដូច្នេះបានជាគាត់យក គាត់ប្រើទូរលេខរបស់គាត់ តាមពិតគាត់ទៅនៅសួងៗ សួងសព្វថ្ងៃហ្នឹង គឺមាននៅសួង។ ដល់ពេលអ៊ីចឹងទៅ បានគាត់ឲ្យ គាត់សរសេរជា ហៅថា ជាអក្សរមក បានគាត់ឲ្យអ្នកបកប្រែយកមកឲ្យខាងខ្ញុំនៅខាងកំពង់ចាម វាយទៅខាង៨៧០។ អ៊ីចឹងបានមានដាក់នៅក្នុងនេះថា ផ្ញើទៅ ដោយមានហៅថា ចុះហត្ថលេខារបស់ឈ្មោះគាត់ ហើយនិងមានសារទូរលេខច្បាស់លាស់ មាន៦៦៥ខ្ទង់ គឺថាហៅថា ខ្លឹមសារនៃសំបុត្រហ្នឹងវាអាចប៉ុណ្ណឹងឯង បើបកប្រែទៅ ហ្នឹងវាអាចវែងបន្តិច។

[១៥:៣៩:០៩]

**ស៖** នៅខាងក្រោមនៃទូរលេខនេះ បាទ នៅត្រង់ថា "ចម្លងជូន" យើងយកឈ្មោះមួយម្តងៗមកនិយាយ។ ទី១ ដាក់ថាអ៊ំ តើលោកយល់ថា អ៊ំនេះជាអ្នកណា?

**ឆ៖** អ៊ំ -- ព្រោះខ្ញុំ ថាគណៈមជ្ឈិម ខ្ញុំចាំមិនច្បាស់ទេ បើសិនណាបុគ្គលទី១ កាលណោះប្រហែលជា ប៉ុល ពត អ៊ំហ្នឹងបាទ។ បន្តៗឈ្មោះតទៅទៀត អ៊ំនួន គឺ -- ខ្ញុំអានត? បាទ ចម្លងជូនអ៊ំ អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន, មន្ទីរ ឯកសារ គឺឈ្មោះទាំងអស់នេះ ខ្ញុំៗអត់ស្គាល់ទេ អត់ស្គាល់ពីរ។ ព្រោះ អ៊ំនួន គាត់ នួន ជា ហ្នឹង, អ៊ំវ៉ាន់, អ៊ំវន ខ្ញុំអត់ស្គាល់ទេ អានេះគឺឈ្មោះៗហៅក្នុងបដិវត្តន៍ទេ។ ឈ្មោះដើមខ្ញុំអត់ស្គាល់អស់ទេ។

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោក សួន កានិល។

គឺថាឯកសារបន្ទាប់គឺឯកសារ E3/516។ បាទ សូមអនុញ្ញាតបង្ហាញឯកសារជូនសាក្សីពិនិត្យ ហើយនិងសូមអនុញ្ញាតបង្ហាញឯកសារ លើអេក្រង់កុំព្យូទ័រផងដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាស ពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១៥:៤១:២៧]

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោក សួន កានិល នេះគឺជាឯកសារមួយដែលជានៅខាងលើនោះ ខាងឆ្វេងនោះ គេសេរសេរថា "បងរ៉ាន់" ទូរលេខ១០ ខ្ទង់៣៩៣ ហើយសរសេរថា "សូមជម្រាបមកគណៈ៨៧០ ជាទីស្នេហា"។ នៅខាងចុងនៃទូរលេខនេះគឺថា គេដាក់ថា "មកពីសមមិត្ត ពក ផ្ញើនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៨ ហើយទទួលនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៨ ម៉ោងដប់"។ កែ ពក នៅក្នុងកថាខណ្ឌទី១ នៅទំព័រទី១នោះនិយាយថា នៅក្នុង -- "យើងបានមកដល់សមរភូមិនៅល្ងាចថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៨ ម៉ោងប្រាំមួយសាមសិបនាទី និងបានទទួលសំបុត្ររបស់អង្គការហើយ"។ នៅក្នុងកថាខណ្ឌទី៥ ហើយថា "បានចាកចេញពីកំពង់ចាម -- កម្លាំងយើងបានចាកចេញពីកំពង់ចាម"។ តាមការពិនិត្យលោកបានបញ្ជាក់ហើយថា ទូរលេខពីមុននោះ គឺពិតហើយ។ តើលោកពិនិត្យមើលថាតើនេះជាទូរលេខដែលពិតប្រាកដជាទូរលេខកាលសម័យនោះដែរឬទេ?

**លោក សួន កានិល៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ គឺតាមការពិនិត្យរបស់ខ្ញុំ ឃើញថាក្នុងឯកសារហ្នឹងគឺថា ជាឯកសារសារទូរលេខពិតប្រាកដ ដោយមានទូរលេខ លេខ១០ ឯចំនួនខ្ទង់៣៩៣។ គ្រាន់តែបញ្ជាប់ប៉ុណ្ណឹង គឺថា ខ្ញុំដឹងថាសារនេះជាសារទូរលេខហើយ។ បើសិនជាសំបុត្រដៃ គេអត់សរសេរអ៊ីចឹងទេបាទ។ ហើយអាហ្នឹងវាដែលមានចុះហត្ថលេខារបស់ កែ ពក នៅកន្លែងនេះ ក៏ខ្ញុំក៏សភាពការណ៍ហ្នឹងក៏កាលណោះក៏ខ្ញុំមិនបានដឹងដែរ។ គឺពេលនោះ គឺថាគេកាលនោះ ព្រោះគាត់នៅ -- គាត់ទទួលខុសត្រូវខាងភូមិភាគកណ្ដាលទេ ហេតុអីបានជាគេឲ្យគាត់ទៅនៅៗខាងណោះ? ពីព្រោះគាត់ជា ហៅថាគណៈបញ្ជាការរួមទូទាំងប្រទេស

ដែរ គឺថាផ្នែកយោធា។ ដូច្នេះប៉ះត្រង់ណាទៅ គេអត់នៅ គាត់ៗ -- ខាងលើហ្នឹងច្រើនឲ្យគាត់ទៅៗ ព្រោះនៅភូមិភាគកណ្តាលហ្នឹងទៅខាងភូមិភាគបូព៌ាហ្នឹង សភាពការណ៍ខាងណោះវាកើតឡើងអ៉ីចឹង។ ទៅគាត់ ទៅហ្នឹងបានគេខាងលើគេបញ្ជាក់មកថា តើលោកចេញទៅហើយនៅ? បានគាត់សរសេរសារទូរលេខតបហ្នឹងថា ខ្ញុំចេញមកដល់ត្រង់ណេះៗហើយ ដូចក្នុងហ្នឹង។ គឺដើម្បីគឺថាកុំឲ្យ ដូចថាបទបញ្ជាទៅ អត់ធ្វើ អាហ្នឹងគឺតាមដាននៅក្នុងសារទូរលេខហ្នឹងបាទ។ អ៉ីចឹងបានគេដាក់តាំងពីថ្ងៃ តាំងពីអីហ្នឹងទាំងអស់។ មើលពេលវេលាវាខុសគ្នាបន្តិចៗ ព្រោះថានេះវាបញ្ហាយោធាវាយ៉ាប់ដែរ។ ទាល់តែវាត្រូវការម៉ោង និងពេលវេលា ពេលខ្លះវាត្រូវការប្រញាប់ សភាពការណ៍វាប្រញាប់អ៉ីចឹងបាទ។ សូមមានមតិប៉ុណ្ណឹង។

[១៥:៤៥:០៤]

**ស៖** ខ្ញុំសូមចូលទៅមុខមួយទៀត គឺថាប្រធានបទបន្ទាប់ពីនេះ គឺនិយាយអំពីប្រព័ន្ធទំនាក់ទំនងរវាងភូមិភាគមួយ ហើយនិងភូមិភាគមួយទៀត។ នៅក្នុងចម្លើយរបស់លោកទៅ អូ.ស៊ី.អាយ.ជេ គឺឯកសារ E3/344 គឺ ERN 00384430, បារាំង ERN 00426150, ខ្មែរ ERN 00373499។ ហើយតើទំនាក់ទំនងរវាងភូមិភាគមួយនិងភូមភាគមួយបានដែរឬទេ? ខ្ញុំសូមដកស្រង់ចម្លើយរបស់លោក កាលដែលលោកឆ្លើយពេលនោះថា "អត់ទេ។ មិនអាចធ្វើទៅបានទេ ដាច់ខាត។ ការទាក់ទងរវាងភូមិភាគមួយទៅ ភូមិភាគមួយដោយមិនឆ្លងកាត់មជ្ឈិម គឺមិនអាចធ្វើទៅបានទេ"។ តើលោកប្រកាន់ចម្លើយនេះនៅដដែលឬទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ គឺចម្លើយនេះ ខ្ញុំនៅប្រកាន់ដដែល ប៉ុន្តែដើម្បីឲ្យខាងអ្នកសួរ ដើម្បីខ្ញុំប្រាប់ខ្លះ គឺថា ដូចជារឿងដែលខ្ញុំតែងតែលើកមកហើយថា ភូមិភាគនិងភូមិភាគ គឺទាក់ទងគ្នាមិនបានទេ។ អត់បាន អត់ឲ្យ -- អត់បានទេ ទាល់តែមានការអនុញ្ញាតមកពីខាង៨៧០ បានទាក់ទងបាន។

ហើយនៅកន្លែងនេះ លោកចង់សួរខ្ញុំបញ្ជាក់អំពីបញ្ហាហេតុអីបានជា កែ ពក ទៅភូមិភាគផ្សេង? បាទ បញ្ហានេះខ្ញុំអាចជម្រាបបាន គឺថាដោយពេលនោះ គឺជាពេលមួយដែលហៅថា សភាពការណ៍រួមទូទាំងប្រទេស--

[១៥:៤៧:១២]

**ស៖** សូមអភ័យទោសលោកសាក្សី។ ខ្ញុំមិនទាន់ចង់សួរដល់ចំណុចនោះអំពីមូលហេតុថា កែពកអាចទៅភូមិភាគមួយទេ គឺសូមអភ័យទោស ដោយសារថា ពេលវេលាយើងខើចណាស់។ នៅក្នុងចម្លើយ

លោកឆ្លើយទៅការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងទំព័រដដែលនោះបាននិយាយថា អ្នកស៊ើបអង្កេតសួរថា "ហេតុអ្វីបានភូមិភាគមួយមិនអាចទាក់ទងផ្ទាល់ទៅភូមិភាគមួយទៀតនោះ?" ចម្លើយនោះ ខ្ញុំសូមដកស្រង់ "ពីព្រោះគ្មានតារាង ហើយយើងមិនចង់ឲ្យមានទំនាក់ទំនងទៅវិញទៅមក ដោយផ្ទាល់ទេ"។ នៅក្នុងទំព័រមួយទៀត "គឺវាត្រូវតែឆ្លងកាត់មជ្ឈិមជាមុនសិន" តើលោកនៅប្រកាន់យកចម្លើយរបស់លោកនោះដែរឬទេ?

**ឆ៖** គឺខ្ញុំនៅតែប្រកាន់យកចម្លើយនេះដដែល។

**ស៖** ហើយនៅក្នុងការសម្ភាសមួយទៀត គឺឯកសារ E3/74 គឺ ERN 00384690, បារាំង ERN 00426163 ហើយខ្មែរ ERN 00373520។ លោកបានពិភាក្សា -- បាននិយាយអំពីការឯកភាពមកពីថ្នាក់លើ។ "យើងមិនអាចធ្វើអ្វីបានទេ បើមិនមានការឯកភាពពីថ្នាក់លើនោះ។ យើងមិនអាចធ្វើទៅបានទេ គឺជាការណែនាំមកពីថ្នាក់លើ"។ បាទ តើត្រឹមត្រូវអ៊ីចឹងដែរឬទេ?

[១៥:៤៩:១៥]

**ឆ៖** ខ្ញុំសូមឆ្លើយ គឺការ-- ខ្ញុំទី១ ខ្ញុំថារក្សានៅចម្លើយខ្ញុំដដែល។ គ្រាន់តែឆ្លើយបញ្ជាក់ថាការងារនៅពេលនោះ គឺថ្នាក់ក្រោមគោរពថ្នាក់លើ។ ចង់និយាយអ៊ីចឹង ត្រូវតែគោរព។

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត សូមឯកសារ -- បញ្ជូនសាក្សីពិនិត្យ គឺឯកសារ E3/254 ដើម្បីឲ្យសាក្សីពិនិត្យ និងសូមអនុញ្ញាតតុលាការដើម្បីបង្ហាញឯកសារលើអេក្រង់កុំព្យូទ័រផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោកអាចឃើញឯកសារ E3/254 ជាទូរលេខមួយ លេខ32 មាន២៩៥ខ្ទង់, ផ្ញើមកពី ម-៨៧០ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨។ ហើយបានចម្លងជូន បងស៊ឺ មួយច្បាប់ បងពកមួយច្បាប់មកពីមន្ទីរ៨៧០។ ទូរលេខនេះនិយាយថា "សូមជ្រាបថា ភូមិភាគបូព៌ា បានផ្ញើសេចក្ដីរាយការណ៍ពីសកម្មភាពខ្មាំងនៅខាងមុខកំពូល មួយច្បាប់មកជូនមន្ទីរ ដោយសុំឲ្យមន្ទីរផ្ញើជូនទៅខាងបង។ សូមបងតាមដានសភាពការណ៍នេះ ហើយចាត់វិធានការតាមសភាពការណ៍ពិតជាក់ស្ដែង ដោយទាក់ទងជាមួយខាងមុខកំពូលផង"។ នេះជាទូរលេខមកពីមន្ទីរ៨៧០ តើខ្ញុំត្រូវយល់ដែរឬទេ ថាភូមិភាគទាំងនេះ

គឺបានបញ្ជូនរបាយការណ៍ទៅមន្ទីរ៨៧០?

[១៥:៥២:១៩]

**ឆ៖** ខ្ញុំសូមឆ្លើយ គឺឯកសារនេះតាមខ្ញុំមើលគឺ ក៏ខ្ញុំយល់ដែរ ពីព្រោះថាមួយជូនមក គឺថាបានផ្ញើជូនទៅ បងស៊ី មួយច្បាប់, បងពក មួយច្បាប់។ ត្រង់កន្លែងនេះហើយ ដែលអ្នកផ្ញើមកនេះគឺ ម-៨៧០ បានថា ម-៨៧០ហ្នឹងគឺបានន័យថាអ្នកជំនួសឲ្យគណៈមជ្ឈិម គឺថាប្រធានមន្ទីររបស់៨៧០ទេ អត់មែនគណៈមជ្ឈិមទេ។ អ៊ីចឹងហើយបានខាងម-៨៧០ហ្នឹងសរសេរសំបុត្រហ្នឹងមក ពីព្រោះសភាពការណ៍នៅមុខកំពូល។ មុខកំពូលពេលនោះ គឺនៅក្នុងភូមិភាគកណ្តាលទេ។ អ្នករាយការណ៍ទៅឲ្យខាង ម-៨៧០។ ដូច្នេះម-៨៧០ ហ្នឹងបានឃើញឯកសារនេះ បានម-៨៧០ ឃើញសភាពការណ៍នេះ ក៏គាត់តបមកវិញៗ មិនមែនគណៈមជ្ឈិមទេ គឺប្រធានមន្ទីរ៨៧០។ ដល់អ៊ីចឹងទៅ បានគាត់ដាក់មក។ "ផ្ញើជូន បងស៊ី មួយច្បាប់" ពីព្រោះ បងស៊ី ហ្នឹង គាត់នៅក្នុងភូមិភាគកណ្តាលទេ ព្រោះគាត់នៅកាន់លេខាស្រុកមុខកំពូល។ ដូច្នេះ ដើម្បីឲ្យយល់ គេខាងនោះ គេបញ្ជាមកថា ទាល់តែទៅខាង បងស៊ី មួយច្បាប់ ឲ្យគាត់ដឹងផងថាខាងលើបានដោះស្រាយឬនៅ?

[១៥:៥៣:៣៣]

ដូច្នេះបានថា ឃើញអ៊ីចឹងទៅបានគាត់ផ្ញើមកឲ្យខាង កែ ពក បានគេឲ្យចម្លងជូនទៅខាង បងស៊ី មួយច្បាប់ និងបងពក មួយច្បាប់។ គេដាក់បញ្ជាមកពីលើម្តងបាទ។ អ៊ីចឹង ម-៨៧០ វាខុសនឹងគណៈ៨៧០ បាទខុសគ្នា។ ឃើញគេដាក់មួយ ម-៨៧០បាទ។ បើសិនជាគេឲ្យទៅគណៈ៨៧០ គេដាក់អ៊ំនួនហ្នឹងបាទ។

**ស៖** ចំណុចដែលខ្ញុំចង់ដឹងនោះ គឺលោកសាក្សី មុនពេលបញ្ជូននេះ គឺភូមិភាគបូព៌ាបានផ្ញើរបាយការណ៍អំពីសកម្មភាពខ្មាំងនៅមុខកំពូល ថាតើភូមិភាគអ្វីដែលមុខកំពូលស្ថិតនៅនោះកាលណោះ? មុខកំពូលស្ថិតនៅភូមិភាគណា?

**ឆ៖** មុខកំពូលស្ថិតនៅក្នុងភូមិភាគកណ្តាលនៅពេលនោះ។

**ស៖** បើសិនជាមានសកម្មភាពខ្មាំងនៅមុខកំពូល នៅភូមិភាគកណ្តាលនោះ តើភូមិភាគបូព៌ាជាអ្នកតាមដានសង្កេតឬ? តើភូមិភាគបូព៌ាអាចទាក់ទងទៅភូមិភាគកណ្តាលដោយផ្ទាល់ ឬក៏គេអាចទាក់ទងទៅខាងណាបាន?

[១៥:៥៥:០៥]

**ឆ៖** គឺខាងភូមិភាគបូព៌ា តាមពិតគេរាយការណ៍ទៅខាងមជ្ឈិមទេ ប៉ុន្តែនៅក្នុងសំបុត្រនេះ ពីព្រោះថាមុខកំពូល ហើយនិងៗខាងភូមិភាគបូព៌ាវានៅជាប់គ្នា ដូច្នេះដើម្បីឲ្យលឿនក៏គេរាយការណ៍មកខាងណេះមួយច្បាប់មក វារាយការណ៍ទៅខាងណោះផង។ អ៊ីចឹងបានគេខាងម-៨៧០ ដាក់មកថា "ចម្លងជូនបងស៊ី មួយច្បាប់ផងដើម្បីឲ្យគាត់ដឹង ហើយនិងខាង បងពក ហ្នឹងមួយច្បាប់"។ បើសិនជាគណៈមជ្ឈិមអត់ហៅ "បង" ទេ អានេះគេហៅ "បង" ព្រោះគាត់ប្រធានមន្ទីរនេះវាតូចជាងខាង គាត់ប្អូនខាង បងស៊ី បងពក។ បាទ វាអ៊ីចឹង ឃើញឯកសារហ្នឹងដាក់ច្បាស់លាស់តែម្តង។

**ស៖** ក្នុងការតាមដានពិនិត្យការងារខាងសារទូរលេខនៅភូមិភាគកណ្តាលនោះ គឺលោកបាននិយាយនៅក្នុងការសម្ភាស E2/411 គឺថា E3/411 គឺថា "កែ ពក បានឲ្យជួបគាត់ដើម្បីពិភាក្សាអំពីបញ្ហាទូរសារ ហើយគាត់ណែនាំឲ្យធ្វើការឲ្យមានម៉ឺងម៉ាត់ ហើយពិនិត្យមើលការងារតារាងការងារដើម្បីកុំឲ្យមានការងារយឺតយ៉ាវ ហើយរៀបចំបុគ្គលិកបន្ថែមអំពីផ្នែកខាងទូរលេខនេះ តើត្រឹមត្រូវ ពិតជាលោកបានឆ្លើយបញ្ជាក់បែបនោះដែរឬទេ?

[១៥:៥៦:៣៨]

**ឆ៖** បាទ ខ្ញុំសូមរក្សាចម្លើយហ្នឹងដដែល ប៉ុន្តែអារឿងនេះខ្ញុំសូមបញ្ជាក់តែបន្តិចទេ ខ្លី ដើម្បីឲ្យខាងហ្នឹងយល់។ ពីរថ្ងៃនុ៎ងគឺថាក្នុងការទាក់ទង ថ្ងៃនុ៎ងដូចថាស្អែក ប៉ុល ពត ត្រូវមកកំពង់ចាម។ ដល់ពេលយប់ហ្នឹងឯងសារទូរលេខហ្នឹងគេឲ្យ គេបញ្ជូនមកឲ្យខ្ញុំនេះ ម៉ោងប្រាំបី។ ដល់ម៉ោងប្រាំបី ខាងខ្ញុំនោះ ពេលនោះគឺថាធាតុអាកាសមិនអំណោយផល ដល់មិនអំណោយផល ខាងខ្ញុំម៉ាស៊ីនមួយខ្ញុំឮគេឮខាង៨៧០ បញ្ជូនមក ប៉ុន្តែខាង៨៧០ ហ្នឹងគឺបែបម៉ាស៊ីនច្រើន ម៉ាស៊ីនវាអុកគ្នា ដល់ម៉ាស៊ីនអុកគ្នាគេអត់ៗឮខ្ញុំ។ អត់ឮខ្ញុំ គឺគោលការណ៍គេវៃកន្លះម៉ោង ខ្ញុំវៃ១៥នាទី គេវៃ១៥នាទី អត់ឮ។ អត់ឮគេវៃបង្ហើរចោល វៃថា "ឥឡូវអត់ឮទេ សូមលា ជួបគ្នាស្អែក"។

[១៥:៥៧:៣១]

ដល់ព្រឹកឡើងមិនទាន់ គឺថាៗគ្រាន់តែព្រឹកឡើង កែ ពក មិនទាន់ក្រោកផង ប៉ុល ពត មកដល់កំពង់ចាម គាត់បោសផ្ទះខ្លួនឯង ផ្ទះថ្ម បោសស្អាតបន្តិច ដល់ពេលម៉ោងប្រាំពីរបាន កែ ពក ឡើងទៅដល់ថា "អ្ហ៎! បងមកពីអង្កាល់?" " អ្ហ៎! ខ្ញុំមកតាំងពីយប់។ ចុះមិត្តមានបានទទួលសារទូរលេខខ្ញុំទេ?" គាត់ថាអត់បានទទួលទេ។ អត់បានទទួលទេ ស្រាប់ដល់ពេលៗដែលថា -- កាលណោះ ប៉ុល ពត ទៅវិញទៅក៏គេហៅខ្ញុំទៅ ប៉ុន្តែហៅខ្ញុំទៅវាមានជាប់នឹងក្មួយគាត់ម្នាក់វាធ្វើការជាមួយខ្ញុំដែរ។ ដល់អ៊ីចឹងទៅ

គាត់ថា ហៅទៅៗ។ ខ្ញុំថា អ៊ើ្ហ ខ្ញុំទៅម្នាក់ខ្ញុំមិនបានទេ ទាល់តែយកសាក្សីទៅ។ ខ្ញុំក៏យកសាក្សីទៅ។ ដល់យកសាក្សីទៅ គាត់សួរថា --អើ ដូចកូនគាត់ គាត់ថា "អ្ហឺ! អ៊ែ្ហង ធ្វើការអ៊ីចឹង? មើលខាងបងសរសេរទូរលេខមកបន្ទោស អ៊ែ្ហងមិនស្រួលជាប់គុកណ៎ា"។ ខ្ញុំថា "បងកុំទាន់ ចាំខ្ញុំរាយការណ៍សិន ទាល់តែខ្ញុំរាយការណ៍បានបងយល់ពីសភាពការណ៍" គឺខ្ញុំមិនជាខ្លាចគាត់ដែរ ខ្ញុំថាអ៊ីចឹង។ ដល់ពេលខ្ញុំរាយការណ៍ទៅថា ពេលខែនេះជារដូវភ្លៀង ដូច្នេះ ខ្ញុំធ្វើការគឺខ្ញុំម៉ឺងម៉ាត់គ្រប់ម៉ោងពេលវេលា។ ខ្ញុំរ៉ៃ១៥ គេរ៉ៃ១៥ គេរ៉ៃបង្ហើរចោល ហើយខ្ញុំថា សភាពការណ៍មិនអនុគ្រោះ អ៊័ន៎! ធាតុអាកាសមិនអនុគ្រោះ។ គាត់អ៊ីចឹងឯង ដល់អ៊ីចឹងទៅគាត់ឲ្យខ្ញុំសរសេរទៅវិញថា "ទៅ! សរសេរម៉េចសរសេរទៅឲ្យតែត្រូវ"។

[១៥:៥៨:៥៨]

ទៅខ្ញុំសរសេរវិញខ្ញុំសរសេរដាក់ទៅតាមគំនិតរបស់ខ្ញុំថា "មកពីខ្ញុំឡើងធ្វើការទៀងទាត់ ប៉ុន្តែមកពីខាងខ្ញុំធាតុអាកាសវាមិនល្អ ហើយខាង គឺបងខាងបងវាម៉ាស៊ីនច្រើន។ ដូច្នេះ ខ្ញុំឮបង បងមិនឮខ្ញុំដូច្នេះសភាពការណ៍មិនអំណោយផល"។ ដូច្នេះទៅគេយកសំបុត្រហ្នឹងទៅឲ្យ ប៉ុល ពត ដល់ ប៉ុល ពតមើលរួចទៅ ហៅថា មួយដែលដូចថា កែ ពក គិតជាកសិករ ក៏គេមិនប្រកាន់ដែរ។ និយាយទៅគាត់ថា "ហ្នឹងហើយខ្ញុំឯកភាពហើយ វាសភាពការណ៍ អ៊័ន៎ ធាតុអាកាសវាមិនអនុគ្រោះ ប្រាប់ខាងទូរលេខផងគ្រាន់តែជួយណែនាំថាធ្វើម៉េចឲ្យវាម៉ឺងម៉ាត់" ទៅគាត់ណែនាំខ្ញុំថាអ៊ីចឹងបាទ។ ហ្នឹងវាអ៊ីចឹង ដែលខ្ញុំឆ្លើយនោះ គឺខ្ញុំមានឯកសារហ្នឹង ហើយនិងមាន ខ្ញុំអនុវត្តជាក់ស្ដែងអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ មន្ត្រីរដ្ឋបាលតុលាការប្រមូលឯកសារពីមុខសាក្សីយកទៅរក្សាទុក។

តំណាងសហព្រះរាជអាជ្ញាដល់ពេលសមល្មមសម្រាកហើយ។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១៧ ខែធ្នូ ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃចន្ទ សប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី សួន កានិល បញ្ចប់ និងចាប់ផ្ដើម -- អាចចាប់ផ្ដើមសក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-620 ដែលនឹងកោះអញ្ជើញមកត្រៀមបម្រុងទុក។ សូមភាគី និងសាធារណជនជ្រាប។

លោក សួន កានិល ការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹង

ធ្វើសវនាការស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃចន្ទ ទី១៧ ខែធ្នូ ឆ្នាំ២០១២ ទៀត។ ដូច្នេះអង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ ទី១៧ ខែធ្នូ ឆ្នាំ២០១២ ទៀត។ ដែលនឹងចាប់ផ្តើមនៅម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិញត្រឡប់ទៅកាន់កន្លែងគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ ទី១៧ ខែធ្នូ ឆ្នាំ២០១២ នៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ ទី១៧ ខែធ្នូ ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក អៀង សារី ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*